សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Économiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការពង្រឹងសមត្ថភាពស្ត្រីនៃយុគសម័យនីតិរដ្ឋ តាមរយៈវិស័យអប់រំ

ស្រាវជ្រាវចាប់ពីថ្ងៃទី ០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី ១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ កញ្ញា **ហ៊ីម កុត**
កញ្ញា **វៀម ម៉ារីម៉ា**

ណែនាំដោយ
**បណ្ឌិត ទូរ សុខុម៉ា**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី១៧

ចូលឆ្នាំសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

ជាបឋមនាងខ្ញុំ **ហ៊ីប កុត  និង  រៀម ម៉ារីម៉ា** ជានិស្សិតសិក្សាថ្នាក់បរិញ្ញាបត្រ  ជំនាញ រដ្ឋបាលសាធារណៈ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្តនិងវិទ្យសាស្រ្តសេដ្ឋកិច្ច ជំនាន់ទី១៧ ឆ្នាំសិក្សា ២០២០-២០២៤។ យើងខ្ញុំទាំងពីរសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖

លោកឪពុក និងអ្នកម្តាយ ដោយសេចក្តីគោរព

**លោកឪពុក ចាន់ ជឿម**　　　　**លោកឪពុក ផឹន សារ៉ន**

**អ្នកម្តាយ ចេស យែប**　　　　**អ្នកម្តាយ សំ យ៉ង់**

ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ ថែរក្សា និងផ្តល់ទូន្មានល្អៗឱ្យធ្វើជាកូនល្អ សិស្សល្អ និងពលរដ្ឋល្អ នៅក្នុងសង្គមប្រកបដោយព្រហ្មវិហាធម៌ និងឱកាសបានសិក្សាតាំងពីថ្នាក់មត្តេយ្យសិក្សា រហូតដល់អនុវិទ្យាល័យ និងបន្តមកដល់មហាវិទ្យាល័យនិងបានបញ្ចប់ថ្នាក់បរិញ្ញាបត្រប្រកបដោយជោគជ័យ។

គណៈគ្រប់គ្រង់នៅសកលវិទ្យាល័យ សាស្រ្តាចារ្យ ទាំងប្រុសទាំងស្រី លោកគ្រូអ្នកគ្រូ ៖ ខ្ញុំសូមអគុណ យ៉ាងជ្រាលជ្រៅដោយក្តីគោរពពីយើងខ្ញុំទាំងពីរពិតជាមានសេចក្តីត្រេកអរក្រៃលេងដែលបានទទួលឱកាសមក សិក្សានៅទីនេះព្រមទាំងទទួបានចំណេះដឹង បទពិសោធន៍ដើម្បីទុកជាគន្លឹះជួយឱ្យក្លាយជាពលរដ្ឋល្អនៅក្នុង សង្គមនិងជួយដល់ប្រទេសជាតិឱ្យមានភាពរីកចម្រើនជាដរាបតទៅមុខ។

**លោកស្រី បណ្ឌិត ទូរ សុខុម៉ា** ៖ ជាគ្រូបង្រៀននៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្តនិងវិទ្យាសាស្រ្ត សេដ្ឋកិច្ចជាគ្រូដឹកនាំកិច្ចការសារណាដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការណែនាំនិងកែលម្អនូវ ចំណុចខ្វះខាតដល់យើងខ្ញុំទាំងពីរនាក់យ៉ាងយកចិត្តទុកដាក់រហូតដល់បានសម្រេចនូវស្នាដៃដ៏ល្អមួយនេះ ចេញជាផ្លែផ្កាសម្រាប់ជាកិច្ចការបញ្ចប់ការសិក្សា។

មិត្តភក្តិទាំងប្រុសទាំងស្រី ៖ ជាទីស្រលាញ់រាប់អាន និងគោរពក្នុងរយៈពេលដែលបានសិក្សាជាមួយគ្នា កន្លងមកនេះមានទាំងមិត្តភក្តិចាស់ មិត្តភក្តិថ្មីដែលតែងតែធ្វើការណែនាំ ចែករំលែកចំណេះដឹង និងបទពិសោធន៍ ដើម្បីយកមកគិតពិចារណាកែលម្អចំណុចដែលខ្វះខាតដើម្បីទទួលបានបទពិសោធន៍ថ្មីៗក្នុងកំឡុងពេលសិក្សា។

ជាចុងក្រោយ ក្នុងនាមយើងខ្ញុំទាំងពីរដែលជានិស្សិតសូមជូនពរដល់លោកឪពុកនិងអ្នកម្តាយ គណៈគ្រប់គ្រង លោកគ្រូអ្នកគ្រូ សាស្រ្តាចារ្យទាំងប្រុសទាំងស្រី គ្រូដឹកនាំនិងនិស្សិតរួមជំនាន់ទាំងអស់ សូមឱ្យវត្ថុស័ក្តិសិទ្ធិជួយថែរក្សានិងការពារឱ្យរួចផុតពីទុក្ខភ័យទាំងឡាយនិងជួបតែពុទ្ធិពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# **អារម្ភកថា**

សារណាដែលលោកអ្នកកំពុងតែអាននេះគឺជាកម្មសិទ្ធរបស់យើងខ្ញុំ **ហ៊ីប កុត** និង **រៀម ម៉ារីម៉ា** ជានិស្សិតសិក្សាថ្នាក់ P៤B0១ ជំនាញបរិញ្ញាបត្ររដ្ឋបាលសាធារណៈ ជំនាន់ទី១៧ ឆ្នាំសិក្សា២០២០-២០២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ សារណាដែលបានសរសេរឡើងមកនេះគឺយើងខ្ញុំទាំងពីរបានខិតខំប្រឹងប្រែងស្រាវជ្រាវទាំងយប់ទាំងថ្ងៃគឺដើម្បីធ្វើការស្រាវជ្រាវទិន្នន័យយកមកសរសេរទុកជាចំណងដៃដល់លោកអ្នកដែលជាអ្នកអាននិងទុកជាប្រយោជន៍សម្រាប់សិក្សាដើម្បីជាចំណេះដឹងបន្ថែម។

យើងខ្ញុំបានទទួលបានការណែនាំដ៏ខ្ពង់ខ្ពស់ពី **លោកស្រី បណ្ឌិត ទូរ សុខុម៉ា** ជាគ្រូដឹកនាំសារណាដែលមានចំណងជើងថា"**ការពង្រឹងសមត្ថភាពស្ត្រីនៃយុគសម័យនីតិរដ្ឋតាមរយៈវិស័យអប់រំ**"។ សារណាមួយនេះបានផ្តល់នូវចំណេះដឹងដ៏សំខាន់ដល់ប្រជាជនកម្ពុជានិងអ្នកស្នេហាការសិក្សាឱ្យបានដឹងច្បាស់ពីសិទ្ធិស្ត្រីដែលទទួលបានស្មើគ្នាដូចនិងបុរស យល់ដឹងអំពីច្បាប់ជាតិ ច្បាប់អន្តរជាតិ និងគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាលក្នុងការចូលរួមលើកកម្ពស់និងផ្តល់សិទ្ធិដល់ស្ត្រីក្នុងការពង្រឹងសមត្ថភាពរបស់ស្ត្រីតាមរយៈការសិក្សាដើម្បីឱ្យស្ត្រីទទួលបានភាពស្មើមុខមាត់នៅក្នុងសង្គមជាតិជាដើម។ នាពេលបច្ចុប្បន្ននេះ ស្ត្រីគឺពិតជាមានសមត្ថភាពនិងទទួលបានឱកាសពិសេសក្នុងការក្លាយជាអ្នកដឹកនាំប្រទេសជាតិដូចគ្នាទៅនិងបុរស និងធ្វើឱ្យដឹងថាស្ត្រីក្នុងសម័យនីតិរដ្ឋជាស្ត្រីដែលប្រកបដោយសមត្ថភាពក្នុងជួយប្រទេសជាតិឱ្យមានការរីកចម្រើន។

ខ្ញុំជឿជាក់ថានៅក្នុងការស្រាវជ្រាវរបស់យើងខ្ញុំទាំងពីរនេះ ទោះបីជាខិតខំព្យាយាមពិនិត្យផ្ទៀងផ្ទាត់យ៉ាងណាក៏ដោយតែងតែមានការភ្លាំងភ្លាត់ខុសឆ្គងខ្លះៗដោយមិនបានព្រាងទុកជាពុំខាន។ ដូចនេះ យើងខ្ញុំទាំងពីរសូមធ្វើការអភ័យទោសពីសំណាក់លោកអ្នកអានទុកជាមុនរាល់កំហុសខុសឆ្គងទាំងឡាយណាដែលកើតមានដោយចេតចេតនាក្តី អចេតនាក្តី សូមខន្តីអភ័យទោសដោយការគោរពយ៉ាងស្មោះស្ម័គ្រពីយើងខ្ញុំទាំងពីរ ហើយយើងខ្ញុំក៏បើកចិត្តទទួលស្វាគមន៍នូវគំនិតរិះគន់បែបស្ថាបនា ដើម្បីយកមកកែលម្អបន្ថែមនូវខ្លឹមសារថ្មីៗដើម្បីរក្សាទុកឱ្យអ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយបានយកមកសិក្សាស្រាវជ្រាវបន្តទៅមុខទៀត។ សូមអរគុណ!

# មាតិកា

ទំព័រ

**សេចក្ដីផ្ដើម** ........ ១

១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

២. ចំណោទនៃការស្រាវជ្រាវ ........ ២

៣. គោលបំណងនៃការស្រាវជ្រាវ ........ ៣

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ៣

៥. សារៈសំខាន់នៃការស្រាវជ្រាវ ........ ៤

៦. វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៥

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៦

**ជំពូកទី១**

**បទដ្ឋានគតិយុត្តក្នុងការគាំពារស្ត្រី**

១.១. ពន្យល់អត្ថន័យ ........ ៨

១.២. ការកកើត និងការអភិវឌ្ឍសមត្ថភាពស្ត្រី ........ ៨

១.៣. បទដ្ឋានគតិយុត្តក្នុងការគាំពារសមត្ថភាពស្ត្រី ........ ១៣

១.៣.១. ការគាំពារស្ត្រីតាមរយៈច្បាប់ជាតិ ........ ១៣

១.៣.២. ការគាំពារស្ត្រីតាមរយៈច្បាប់អន្តរជាតិ ........ ១៦

**ជំពូកទី២**

**ការពង្រឹងសមត្ថភាពស្ត្រីកម្ពុជានាសម័យនីតិរដ្ឋ**

២.១. ការពង្រឹងសមត្ថភាពស្ត្រីតាមរយៈគោលនយោបាយរបស់រាជរដ្ឋាភិបាល ........ ១៩

២.២. ការគាំពារស្ត្រីនៅក្នុងសកម្មភាពសង្គម ........ ២៤

២.៣. ការចូលរួមសកម្មភាពរបស់ស្ត្រីនៅក្នុងស្ថាប័នរដ្ឋ ........ ២៥

## ជំពូកទី៣
## ពិភាក្សាលើលទ្ធផលនៃការពង្រឹងសមត្ថភាពស្ត្រី


៣.១. ពិភាក្សាលើសមិទ្ធផលនៃការពង្រឹងសមត្ថភាពស្ត្រីដែលឆ្លុះបញ្ចាំងតាមរយៈវិស័យអប់រំ.................... ៣០

៣.២. ពិភាក្សាលើការពង្រឹងសមត្ថភាពស្ត្រីតាមរយៈវិស័យសាធារណៈ ....................................... ៣២

៣.៣. ពិភាក្សាលើការពង្រឹងសមត្ថភាពស្ត្រីក្នុងវិស័យឯកជន ........................................................ ៣៧

សេចក្តីសន្និដ្ឋាន ....................................................................................................... ៣៩

អនុសាសន៍............................................................................................................. ៤១

ឯកសារពិគ្រោះ

ឧបសម្ព័ន្ធ

## ទម្រង់អក្សរកាត់

- ក.ជ.ក.ស ៖ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី។
- គ.ក.ន.ក ៖ គណៈកម្មាធិការការទទួលបន្ទុកកិច្ចការនារីនិងកុមារ ឃុំ សង្កាត់។
- គ.ក.ស.ក ៖គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- គ.ជ.អ.ប ៖គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។
- ផ.អ.៣ ៖ ផែនការអនុវត្តរយៈពេល៣ឆ្នាំ។
- HRI NC ៖ ទីប្រឹក្សាធនធានមនុស្សអន្តរជាតិ (Human Resources International Consultancy).
- CEDAW ៖ អនុសញ្ញាការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ។
  (Convention on the Elimination of All Forms of Discrimination against Women).
- UN Women ៖ អង្គការសហប្រជាជាតិសម្រាប់សមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី
  (United Nation Entity for Gender Equality and the Empowerment of Women) .
- STEAM ៖វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា
  (Science technology engineering arts and mathematics).
- The Sustainable Development Goals of 2030 ៖ គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនៃឆ្នាំ២០៣០។

# ពន្យល់ពាក្យគន្លឹះ

- ការគាំពារ ៖ គឺក្លាយមកពីពាក្យថា ការការពារ ដែលមានន័យថាជាការរារាំង ការទប់ស្កាត់សកម្មភាព ឬ ការបញ្ចៀសរាល់អំពើអ្វីមួយ ឬ ហេតុកាណ៍អ្វីមួយមិនឱ្យកើតឡើងបានក្នុងការរក្សាសុវត្ថិភាពកិត្តិយសនិងសេចក្តីថ្លៃថ្នូរនៅក្នុងស្ថានភាពណាមួយ។
- ច្បាប់ជាតិ ៖ គឺជាច្បាប់ដែលមាននៅក្នុងប្រទេសមួយជាក់លាក់។
- រដ្ឋធម្មនុញ្ញ ៖ គឺជាច្បាប់គ្រឹះ ឬ ជាច្បាប់កំពូលនៃរដ្ឋដែលកំណត់រចនាសម្ព័ន្ធមុខងារមូលដ្ឋានរដ្ឋនិងស្ថាប័នសំខាន់ៗដែលកំណត់នូវសិទ្ធិនិងកាតព្វកិច្ចជាមូលដ្ឋានរបស់ប្រជាជន។
- មាតុភាព ៖ គឺជាការសម្រាកមុនពេល ឬ ក្រោយពេលដែលស្ត្រីសម្រាលកូន។
- អនុសញ្ញា ៖ គឺមានន័យថាសន្ធិសញ្ញាអន្តរជាតិដែលមានឋានានុក្រមភាពទាបជាងគេដែលចែងពីស្តង់ដារដែលមានការទទួលស្គាល់ជាសកលក្នុងមជ្ឈដ្ឋានមួយចំនួននៅក្នុងសង្គម។
- សន្ធិសញ្ញា ៖ គឺជាកិច្ចព្រមព្រៀងអន្តរជាតិដែលបានធ្វើឡើងជាលាយលក្ខណ៍អក្សររវាងរដ្ឋ និងរដ្ឋ រដ្ឋនិងអង្គការអន្តរជាតិ ឬ អង្គការអន្តរជាតិ និងអង្គការអន្តរជាតិហើយស្ថិតនៅក្រោមការគ្រប់គ្រងសាធារណៈបើទោះបីជាកិច្ចព្រមព្រៀងនោះមានឈ្មោះជាអ្វីក៏ដោយគឺដើម្បីបង្កើតអានុភាពគតិយុត្ត។
- នីតិរដ្ឋ ៖ គឺមានន័យថារដ្ឋដែលគ្រប់គ្រងដោយច្បាប់ក្នុងការបំពេញសកម្មភាពរបស់ខ្លួនរួមមានការពារសិទ្ធិសេរីភាពតម្លៃរបស់បុគ្គលនិងអំណាចរបស់រដ្ឋដែលកើតចេញពីឆន្ទៈរបស់ប្រជាពលរដ្ឋ។
- យុទ្ធសាស្ត្រ ៖ គឺជាសិល្បៈនៃការរៀបចំ ឬ ការដឹកនាំដើម្បីសម្រេចកិច្ចការឱ្យស្របតាមគោលបំណងនិងគោលដៅដែលបានកំណត់។
- ស្ត្រី ៖គឺក្លាយពីពាក្យថាសិរីមានន័យថាជាមង្គល ប្រភពនៃសិរីសួស្តី មានសេចក្តីសុខមានភាពទន់ភ្លន់ ជាពន្លឺ ជានិម្មិតរូបនៃទឹកសន្សើម។
- ការរើសអើង ៖ គឺជាការប្រកាន់យកនូវការបែងចែក ការរឹតត្បិត ឬ ការនិយមផ្អែកលើពូជសាសន៍ពណ៌សម្បុរ បុព្វជាតិ ឬ ដើមកំណើត ឬ ជាតិពន្ធដែលមានទិសដៅបន្ថយការទទួលស្គាល់សិទ្ធិសេរីភាពមូលដ្ឋានខាងវិស័យនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។
- ច្បាប់អន្តរៈជាតិ ៖ គឺជាប្រព័ន្ធនៃវិធានស្តីពីសិទ្ធិ និងភារកិច្ចរបស់រដ្ឋនានានៅក្នុងទំនាក់ទំនងរបស់ពួកគេ ឬ ផ្អែកទៅលើទស្សនទាននៃសមភាពអធិបតេយ្យភាពរបស់រដ្ឋ និងការព្រមព្រៀងរបស់រដ្ឋនានា។

- កតិកាសញ្ញា ៖ ជាកិច្ចព្រមព្រៀងដែលត្រូវបានបង្កើតឡើងរវាងភាគីពីរ ឬ ច្រើនដែលមានទាំងរដ្ឋ ផ្លូវការនិងមិនផ្លូវការដើម្បីធ្វើកិច្ចការមួយរួមគ្នាក្នុងគោលបំណងបម្រើផលប្រយោជន៍គ្នាទៅវិញទៅមក។
- សមភាពយេនឌ័រ ៖ មានន័យថាគ្មានការរើសអើងរវាងបុរស និងស្ត្រីមានលក្ខខណ្ឌនិងទទួលបាននូវសិទ្ធិស្មើៗគ្នាគឺជាការឱ្យតម្លៃដោយសង្គមទៅលើភាពដូចគ្នា និងភាពខុសគ្នាត្រូវបានគេផ្តល់ឱកាសឱ្យភេទទាំងពីរបានទទួលផលប្រយោជន៍ស្មើៗគ្នា។
- គោលនយោបាយ ៖ ជាផែនការសកម្មភាពមួយដែលបានអនុម័ត ឬ ស្នើឡើងដោយរដ្ឋាភិបាល ស្ថាប័ន គណបក្ស ក្រុមហ៊ុន ឬ បុគ្គល។
- កាលានុវត្តភាព ៖ គឺជាកាលៈទេសៈមួយដែលសមគួរ ឬ ដំណើរវិវត្តន៍អ្វីមួយឱ្យត្រូវតាមពេលវេលាដែលអនុគ្រោះ ឬ ឱកាសសម្រាប់យកប្រយោជន៍អំពីកិច្ចការអ្វីមួយ ឬ គុណសម្បត្តិអ្វីមួយកំពុងលេចឡើង ប៉ុន្តែការទាញយកប្រយោជន៍នោះគឺអាចប្រឈម និងហានិភ័យ ហើយចាំបាច់ត្រូវប្តេជ្ញាចិត្តយ៉ាងមុតមាំនិងមានធនធានគ្រប់គ្រាន់ទើបអាចទាញយកប្រយោជន៍នោះបាន។
- លិខិតបទដ្ឋានគតិយុត្ត ៖ ជាអត្ថបទច្បាប់ទាំងឡាយណាដែលអង្គការនីតិបញ្ញត្តិ ឬ អាជ្ញាធររបស់រដ្ឋដែលបានតាក់តែងឡើងដោយផ្អែកទៅលើរដ្ឋធម្មនុញ្ញជាគោលដើម្បីយកទៅអនុវត្តន៍នៅក្នុងការគ្រប់គ្រងប្រទេសជាតិ ។
- យុទ្ធសាស្រ្តចតុកោណ ៖ គឺជារបៀបវារៈគោលនយោបាយក្នុងកម្មវិធីនយោបាយសម្រាប់នីតិកាលទី៣ របស់រាជរដ្ឋាភិបាលនៃរដ្ឋសភាដែលត្រូវយកមកលម្អិតបន្ថែមដោយអន្លើរ និងត្រូវសម្រិតសម្រាំងឱ្យចេញជាកញ្ចប់អាទិភាពទៅតាមបណ្តាវិស័យសំខាន់ៗដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងជាប្រព័ន្ធស៊ីចង្វាក់គ្នាដែលយោគយល់ឱ្យគ្នាទៅវិញទៅមកងាយគ្រប់គ្រង និងអនុញ្ញាតដោយរាជរដ្ឋាភិបាលនិងដៃគូរអភិវឌ្ឍន៍ដែលពាក់ព័ន្ធអាចប្រើប្រាស់ជាឧបករណ៍គ្រប់គ្រង់ការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជា គឺជាប្រទេសដែលកំពុងធ្វើការផ្លាស់ប្ដូរខ្លួនពីប្រទេសដែលកំពុងអភិវឌ្ឍន៍សំដៅទៅជាប្រទេសអភិវឌ្ឍន៍មួយដូចទៅនិងបណ្ដាប្រទេសនានាលើពិភពលោក។ មួយវិញទៀត ប្រទេសកម្ពុជាបានកំពុងប្រតិបត្តិការពង្រឹងលើគ្រប់វិស័យទាំងអស់និងធ្វើការលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងសង្គមដែលជាធនធានដ៏មានតម្លៃសម្រាប់ប្រទេសជាតិ និងផ្ដល់នូវភាពក្លាហានដល់យេនឌ័រក្នុងការបំពេញតួនាទីនិងភារៈកិច្ចរបស់ខ្លួនឱ្យបានល្អប្រសើរ។

យ៉ាងណាមិញ រាជរដ្ឋាភិបាលកម្ពុជាបានកំពុងតែយកចិត្តទុកដាក់ក្នុងការពង្រឹងសមត្ថភាពធនធានទាំងពីរភេទនៅក្នុងប្រទេសឱ្យកាន់តែមានសមត្ថភាពខ្ពស់ ជាពិសេសគឺស្ត្រីនិងក្មេងស្រីដោយសារតែបច្ចុប្បន្នស្ត្រីនិងក្មេងស្រីបានទទួលការគាំទ្រនិងការការពារនៅក្នុងសង្គមដែលធ្វើឱ្យស្ត្រីមានសិទ្ធិក្នុងការពង្រឹងសមត្ថភាពតាមការទទួលបានការអប់រំគ្រប់រូបភាពទាំងអស់ស្មើនិងបុរសដែលធ្វើឱ្យការអប់រំរបស់ស្ត្រីនិងក្មេងស្រីមានការកើនឡើងជាបន្តបន្ទាប់ពីមួយឆ្នាំទៅមួយឆ្នាំ។ ដោយសង្កេតឃើញតាមរយៈឆ្នាំសិក្សា (២០១៧-២០១៨) ចំនួនសិស្សស្រីដែលបានប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមាន (៥២,៣៨ ភាគរយ) ថ្នាក់ឧត្តមសិក្សាថ្នាក់បរិញ្ញាបត្ររងមានស្រី (៤៩ ភាគរយ) ថ្នាក់បរិញ្ញាបត្រមានស្រី (៤៥,៩ ភាគរយ) ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានស្រី (២១,៦ ភាគរយ) ថ្នាក់បណ្ឌិតមានស្រី (៥,១ ភាគរយ) និងវិទ្យាសាស្ត្រ បច្ចេកទេស វិស្វកម្ម គណិតវិទ្យា (STEM) មានស្រី (២៩,៨ ភាគរយ) ។[1] បើប្រៀបធៀបពីមួយសម័យកាលទៅមួយសម័យកាលដែលស្ត្រីត្រូវបានសង្គមចាត់ទុកជាភេទមួយដែលទន់ខ្សោយភាគច្រើនទទួលបន្ទុកកិច្ចការងារផ្ទះសម្លៀងនិងអាចនិយាយបានយ៉ាងសាមញ្ញថាការងារចង្ក្រានចានឆ្នាំងមើលថែកូនចៅ ទុកដាក់ទ្រព្យសម្បត្តិ មើលថែឪពុកម្ដាយជាដើម។

ការលើកកម្ពស់ស្ត្រីដែលផ្អែកតាមការពង្រឹងសមត្ថភាពតាមរយៈវិស័យអប់រំជាគឺការបង្កើននូវធនធានដែលពោពេញដោយចំណេះដឹង និងលុបបំបាត់ការរើសអើងចំពោះស្ត្រីជួយឱ្យស្ត្រីមានភាពក្លាហានក្នុងការដើរចេញពីស្ត្រីជាភេទទន់ខ្សោយមកក្លាយជាស្ត្រីដែលជាឆ្អឹងខ្នងរបស់ប្រទេសជាតិពុំអាចខ្វះបានដែលមានទាំងការអប់រំ ចំណេះជំនាញ សមត្ថភាព មានភាពរឹងមាំអាចក្លាយជាអ្នកដឹកនាំព្រមទាំងអាចដើរតួនាទីធ្វើសេចក្ដីសម្រេច និងចូលរួមកសាងសង្គមជាតិឱ្យមានការរីកចម្រើនដូចនិងបុរសដែរ។ ដើម្បីពង្រឹងសមត្ថភាពនិងសម្រេចបាននូវការលើកកម្ពស់ដល់ស្ត្រីហើយកម្ពុជាក៏បានផ្ដល់សច្ចាប័នលើកតិកាសញ្ញាស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនិងស្ត្រីភេទនៅក្នុងឆ្នាំ១៩៩២។ រាជរដ្ឋាភិបាលក៏បានបង្កើតក្រសួងកិច្ចការនារី និងក្រុមប្រឹក្សាជាតិដើម្បីស្ត្រីដែលជាយន្តការជាតិសម្រាប់លើកកម្ពស់យេនឌ័រ និងបង្កើតភាព

[1] Ministry of information (05,03,2019)

ក្លាហានដល់ស្ត្រី។ មួយវិញទៀតក្រសួងកិច្ចការនារីបានបង្កើតផែនការយុទ្ធសាស្ត្ររយៈពេល ៥ ឆ្នាំ ដែលហៅថានារីរតនៈ ក្រោយមករាជរដ្ឋាភិបាលបានបង្កើនការយកចិត្តទុកដាក់ក្នុងការពង្រឹងសមត្ថភាព និងចំណេះជំនាញរបស់ស្ត្រីនិងក្មេងស្រីដោយបានបង្កើតយុទ្ធនាការសិទ្ធិស្ត្រី ការរៀបចំផែនការ គោលនយោបាយ និងសហការជាមួយស្ថាប័នកិច្ចការនារីរួមទាំងមន្ត្រីក្រោមឱវាទតាំងពីស្ថាប័នថ្នាក់ជាតិរហូតដល់ថ្នាក់ក្រោមជាតិ និងសហការជាមួយអង្គការក្រៅរដ្ឋាភិបាលនៅក្នុងការលើកកម្ពស់ស្ត្រីឱ្យស្មើភាពនិងបុរសនៅក្នុងសង្គមជាតិប្រកបដោយគុណភាព និងសមធម៌ ។

អង្គការសង្គមស៊ីវិល អង្គការអន្តរជាតិ និងអង្គការសហប្រជាជាតិដែលគាំទ្រសមភាពយេនឌ័របានផ្តល់ភាពក្លាហានដល់ស្ត្រីប្រចាំកម្ពុជា ឬ ហៅកាត់ថា UN Women ធនាគារអភិវឌ្ឍន៍អាស៊ីនិងមួយចំនួនផ្សេងៗទៀតដែលបានចូលរួមយ៉ាងសកម្មក្នុងការជួយលើកកម្ពស់ស្ត្រីកម្ពុជានៅក្នុងវិស័យអប់រំ។ ចំពោះការលើកកម្ពស់នេះបានធ្វើឡើងតាមរយៈការគាំទ្រមតិ ការផ្តល់មូលិធិការបង្កើតគម្រោងនិងកម្មវិធីផ្សេងៗដើម្បីគាំទ្រស្ត្រី ព្រមទាំងសិក្សាស្រាវជ្រាវពីបញ្ហាប្រឈម ការចូលរួមបង្កើតគោលនយោបាយលើកកម្ពស់ស្ត្រី និងការតាមដានវាយតម្លៃការអនុវត្តក្របខ័ណ្ឌកតិកាសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនិងស្ត្រីភេទ និងការអនុវត្តផែនការយុទ្ធសាស្ត្ររបស់ក្រសួងកិច្ចការនារី។

## ២. ចំណោទនៃការស្រាវជ្រាវ

ក្រសួងកិច្ចការនារីដែលស្ថិតនៅក្រោមរាជរដ្ឋាភិបាលបានធ្វើការសហការជាមួយស្ថាប័នដែលពាក់ព័ន្ធគ្រប់ជាន់ថ្នាក់បានខិតខំប្រឹងប្រែងចូលរួមលើកកម្ពស់សមត្ថភាពស្ត្រី និងក្មេងស្រីនៅគ្រប់វិស័យទាំងអស់នៅក្នុងសង្គមដើម្បីពង្រឹងសមត្ថភាពស្ត្រីជាពិសេសនោះគឺតាមរយៈវិស័យអប់រំ។ ចំពោះការខិតខំប្រឹងប្រែងនេះពិតជាទទួលបានលទ្ធផលគួរឱ្យកត់សម្គាល់ផងដែល។ ប៉ុន្តែចំពោះលទ្ធផលល្អក៏តែងតែមាននូវបញ្ហាដែលតាមរាំងដល់ស្ត្រីក្នុងការសិក្សាដដែល។ ដោយសារបញ្ហាប្រឈមទាំងអស់នេះបាននាំឱ្យស្ត្រីនិងក្មេងស្រីនៅកម្ពុជាបានបាត់ឱកាសសម្រាប់ពង្រឹងសមត្ថភាព និងភាពរឹងមាំនៃចំណេះដឹងក្នុងការបញ្ចេញនូវសក្តានុពលរបស់ខ្លួនដែលនាំឱ្យមានវិសមភាពរវាងបុរសនិងស្ត្រីក្នុងការទទួលបានការអប់រំ។ ដើម្បជាមគ្គុទេសន៍ក្នុងការបកស្រាយប្រធានបទខាងលើនេះក្រុមយើងខ្ញុំមានសំណួរចោទសួរជាគន្លឹះនៃការបកស្រាយប្រធានបទដូចខាងក្រោម៖

តើអ្វីជាបញ្ហាដែលរារាំងដល់ការអភិវឌ្ឍសមត្ថភាពស្ត្រីនៅកម្ពុជា?

តើបទដ្ឋានគតិយុត្តមានអានុភាពឆ្លើយតបគ្រប់គ្រាន់នៅក្នុងការគាំពារការអភិវឌ្ឍសមត្ថភាពស្ត្រីកម្ពុជាដែរឬទេ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះមានគោលបំណងសំខាន់គឺស្វែងយល់ពីស្ថានភាពរបស់ស្ត្រីក្នុងការពង្រឹងសមត្ថភាពនៅគ្រប់វិស័យទាំងអស់ជាពិសេសតាមរយៈវិស័យអប់រំនាពេលបច្ចុប្បន្ននេះហើយការសិក្សាស្រាវជ្រាវទៅលើការចូលរួមលើកកម្ពស់ស្ត្រីនិងការពង្រឹងសមត្ថភាពស្ត្រីនៅក្នុងវិស័យអប់រំនេះគឺមានច្បាប់ជាតិ ច្បាប់អន្តរជាតិ គោលនយោបាយស្ថាប័នដែលពាក់ព័ន្ធចូលរួមដោះស្រាយបញ្ហារបស់ស្ត្រីនៅក្នុងវិស័យអប់រំនិងការត្រួតពិនិត្យទៅលើលទ្ធផលដែលទទួលបានពីការខិតខំប្រឹងប្រែងរបស់ស្ថាប័នដែលពាក់ព័ន្ធនានាក្នុងការព្យាយាមលើកកម្ពស់ស្ត្រីកម្ពុជានៅក្នុងវិស័យអប់រំ និងឱ្យមានការយល់ដឹងអំពីស្ថានភាពស្ត្រីនៅក្នុងវិស័យអប់រំនៃយុគសម័យនីតិរដ្ឋនេះគឺមានសារៈសំខាន់ក្នុងការអភិវឌ្ឍសមត្ថភាពនិងឱ្យដឹងពីបញ្ហាប្រឈមជាកត្តានាំឱ្យមានភាពយឺតយ៉ាវសម្រាប់ការអភិវឌ្ឍសមត្ថភាពរបស់ស្ត្រីនៅក្នុងការចូលរួមក្លាយជាអ្នកដឹកនាំស្មើមុខមាត់និងបុរស។ ទទួលបានការសិក្សាស្វែងយល់ឱ្យច្បាស់ពីបញ្ហានេះគឺនាំឱ្យមានការផ្តល់អនុសាសន៍ជារួមមួយ និងដំណោះស្រាយដែលមានប្រសិទ្ធភាពដើម្បីកាត់បន្ថយបញ្ហាប្រឈម និងមានគោលបំណងជួយជំរុញការលូតលាស់ធនធាននៅក្នុងសង្គមឱ្យមានការរីកចម្រើន និងមានសមត្ថភាពសម្រាប់ជាសសរយុវជនកម្ពុជា ការកាត់បន្ថយវិសមភាព ការលើកកម្ពស់ស្ត្រី និងការលុបបាត់ការរើសអើងស្ត្រីភេទ។

## ៤. ទំហំនិងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើសារណាមួយនេះត្រូវបានធ្វើក្នុងឆ្នាំសិក្សា ២០២៣-២០២៤ គឺផ្តោតសំខាន់តែទៅលើការពង្រឹងសមត្ថភាពស្ត្រីនៃយុគសម័យនីតិរដ្ឋតាមរយៈវិស័យអប់រំតែប៉ុណ្ណោះទេ។ ចំពោះការសិក្សាស្រាវជ្រាវទៅលើប្រធានបទសារណាមួយនេះគឺប្រើប្រាស់ទិន្នន័យបទដ្ឋានគតិយុត្តណាដែលមានសុពលភាពនៅក្នុងឆ្នាំសិក្សា(២០២៣-២០២៤) រួមមាន៖ ទី១.ច្បាប់ជាតិ ៖ (រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា១៩៩៣, ច្បាប់ស្តីពីការងារ,១០,មករា,១៩៩៧,ជស/រកម/០៣៩៧/០១/, ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ,លេខនស/រក/០៧១១/០១៣,០៤.កក្កដា.២០១១)។ ទី២.ច្បាប់អន្តរជាតិ ៖ (អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ (CEDAW) ខែមករា ឆ្នាំ ២០១០, សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ១០ ធ្នូ ឆ្នាំ ១៩៤៨)។ ទី៣.គោលនយោបាយនិងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល (ផែនការយុទ្ធសាស្ត្រអភិឌ្ឍន៍ជាតិឆ្នាំ ២០១៤-២០១៨, ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនៅក្នុងវិស័យអប់រំឆ្នាំ ២០២១-២០២៥,ផែនការយុទ្ធសាស្ត្រនារីរតនៈទី៤(២០១៤-២០១៨)និងផែនការយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ប្រធានបទការពង្រឹងសមត្ថភាពស្ត្រីនៃយុគសម័យនីតិរដ្ឋតាមរយៈវិស័យអប់រំជាកាសិក្សាស្រាវជ្រាវនេះមានសារៈសំខាន់ចំពោះខ្ញុំទាំងពីរដែលជាអ្នកស្រាវជ្រាវបញ្ចប់ការសិក្សា និងអ្នកសិក្សាផ្សេងៗរួមទាំងអ្នកដែលចូលចិត្តអាននិងប្រជាជនក្នុងសង្គមដូចជា៖

**សង្គមជាតិ** ៖ ធ្វើឱ្យរាជរដ្ឋាភិបាលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិបានដឹងពីបញ្ហាដែលជាចំណុចខ្វះខាតនិងបង្កើនការត្រួតពិនិត្យពីចំណុចខ្វះខាតចំពោះការលើកកម្ពស់ស្ត្រីគ្រប់វិស័យទាំងអស់ជាពិសេសវិស័យអប់រំនិងខិតខំស្វែងរកដំណោះស្រាយធ្វើឱ្យស្ត្រីនិងបុរសមានភាពសមាមាត្រគ្នាចំពោះការចូលរួមក្នុងសង្គមនិងលុបបំបាត់ការរើសអើងស្ត្រី។

**ក្រសួងមុខងារ និងក្រសួងការងារ** ៖ ទុកជាឯកសារស្រាវជ្រាវមួយដែលអាចផ្ដល់ជាជំនួយក្នុងការឆ្លើយតបទៅនិងភាពខ្វះខាតដែលរាជរដ្ឋាភិបាលអនុវត្តន៍មិនសូវបានល្អ និងបន្ថែមការរឹតបន្តឹងនូវចំណុចដែលមិនល្អចំពោះការលើកកម្ពស់ស្ត្រី និងត្រួតពិនិត្យពីលទ្ធភាពការងាររបស់ស្ត្រីដោយផ្ដល់អាទិភាពចំពោះស្ត្រីដែលជាមន្ត្រីរាជការ និងលើកទឹកចិត្តឱ្យស្ត្រីមានតួនាទី និងតំណែងខ្ពស់ក្នុងការចូលរួមធ្វើសេចក្ដីសម្រេចក្នុងគោលបំណងឱ្យស្ត្រីបញ្ចេញពីសមត្ថភាពក្នុងការធ្វើជាអ្នកដឹកនាំឱ្យស្មើនិងបុរស។

**វិស័យឯកជន** ៖ ធ្វើឱ្យដឹងពីការរីកចម្រើនរបស់ស្ត្រីនាពេលបច្ចុប្បន្នដែលមានគាំទ្រ និងលើកកម្ពស់សមត្ថភាពស្ត្រីយ៉ាងខ្លាំងនិងមានច្បាប់ហាមឃាត់មិនឱ្យវិស័យឯកជនមានរើសអើងចំពោះស្ត្រីដោយគិតថាមិនមានចំណេះដឹង សមត្ថភាព គំនិតច្នៃប្រឌិតពុំបានស្មើនិងបុរសនិងបើកឱកាសឱ្យស្ត្រីចូលរួមធ្វើការដើម្បីអភិវឌ្ឍន៍សមត្ថភាពទទួលបានកម្រៃដែលសមរម្យមានឱកាសធ្វើការក្នុងដំណែងខ្ពស់។

**ចំពោះស្ត្រី** ៖ គឺយល់ដឹងពីសារៈសំខាន់របស់ខ្លួនក្នុងការចូលរួមក្នុងសង្គម និងការងារផ្សេងៗទៀតស្មើនិងបុរសដែរនិងចេះបើកឱកាសទទួលយកចំណេះដឹងដោយខិតខំតស៊ូរៀនសូត្រ និងការពង្រឹងសមត្ថភាពគឺចូលរួមនៅក្នុងសង្គមចេះប្រើប្រាស់សិទ្ធិ និងឱកាសរបស់ខ្លួនឱ្យបានពេញលេញដើម្បីកាត់បន្ថយនូវការរើសអើង និងជួយអភិវឌ្ឍន៍ខ្លួនឱ្យក្លាយជាស្ត្រីអង់អាចក្លាហ៊ាននិងជាឆ្អឹងខ្នងនៃប្រទេសជាតិ។

**ចំពោះខ្លួនឯង** ៖ គឺបង្ហាញឱ្យដឹងថាបញ្ហានេះមានសារៈសំខាន់ក្នុងការចូលរួមអភិវឌ្ឍន៍សមត្ថភាពស្ត្រីនិងផ្ដល់ជាប្រភពចំណេះដឹងដ៏សំខាន់ក្នុងការស្វែងយល់ឱ្យបានច្បាស់ពីស្ថានភាពរបស់ស្ត្រីនៅក្នុងសង្គម និងលទ្ធភាពដែលស្ត្រីទទួលបានតម្លៃនៅក្នុងសង្គម និងជាទិន្នន័យសំខាន់សម្រាប់បញ្ចប់ការសិក្សាផងដែរ។

**សិស្សនិងនិស្សិត ៖** ទុកជាឯកសារជំនួយស្មារតីដ៏សំខាន់សម្រាប់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយៗធ្វើការសិក្សាបន្តដើម្បីទទួលបានចំណេះដឹងថ្មីនិងចង្អុលបង្ហាញពីសិទ្ធិក្នុងការទទួលបានអប់រំរបស់ស្ត្រីស្មើភាពគ្នាទៅនិងបុរសដែល។ លើសពីនេះ បញ្ហានេះគឺជាបញ្ហាមួយថ្មីដែលសំខាន់នៅក្នុងសង្គមកម្ពុជានាពេលបច្ចុប្បន្ននិងបន្តទៅពេលខាងមុខទៀត។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវប្រធានមួយនេះ "**ការពង្រឹងសមត្ថភាពស្ត្រីនៃយុគសម័យនីតិរដ្ឋតាមរយៈវិស័យអប់រំ**" ក្រុមយើងខ្ញុំបានប្រើប្រាស់ប្រភពព័ត៌មានដែលកើតចេញពីទិន្នន័យដែលមានស្រាប់។ ចំពោះទិន្នន័យដែលយកមកប្រើប្រាស់ទាំងនោះមាន៖ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់អន្តរជាតិ ច្បាប់ជាតិ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល លិខិតបទដ្ឋានគតិយុត្តនៅថ្នាក់ជាតិ រហូតដល់ថ្នាក់ក្រោមជាតិនិងប្រភពដែលកើតចេញពីទិន្នន័យចម្បងលើការចូលរួមជាក់ស្តែងរបស់រាជរដ្ឋាភិបាលសង្គមស៊ីវិលនៅក្នុងការអភិវឌ្ឍសមត្ថភាពរបស់ស្ត្រីនាពេលបច្ចុប្បន្ន។

### ក. ការកំណត់អថេរ

ការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើនេះដើម្បីឱ្យមានភាពងាយស្រួល និងមានលក្ខណៈវិទ្យាសាស្ត្រក្រុមយើងខ្ញុំបានធ្វើការកំណត់អថេរ។ ការកំណត់អថេរនេះមានចែកពីរគឺ៖

**ទី១ អថេរមិនឯករាជ** "ការពង្រឹងសមត្ថភាពស្ត្រីនៃយុគសម័យនីតិរដ្ឋតាមរយៈវិស័យអប់រំ" គឺដោយសារបច្ចុប្បន្នសមត្ថភាពស្ត្រីនៅមានកម្រិតទាបនៅឡើយនៅមិនទាន់ឆ្លើយតបនិងយេនឌ័រ ជាពិសេសសមត្ថភាពស្ត្រីក្នុងការចូលរួមដែលមានតួនាទីកម្រិតថ្នាក់ដឹកនាំដូចជាស្ថាប័ននានាមិនទាន់ឆ្លើយតបពាក្យយេនឌ័រនៅឡើយ។

**ទី២ អថេរឯករាជ** យើងដាក់ចូលអថេរឯករាជមួយចំនួនដើម្បីធ្វើការប្រែប្រួលអថេរមិនឯករាជខាងលើដែលធានាបាននូវការពង្រឹងសមត្ថភាពស្ត្រី និងឱ្យស្ត្រីមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការចូលរួមតួនាទីជាអ្នកដឹកនាំដើម្បីឆ្លើយតបពាក្យយេនឌ័រ។ អថេរឯករាជទាំងនោះគឺយើងសម្លឹងមើលពីលទ្ធភាពនៃបទដ្ឋានគតិយុត្តដើម្បីគាំពារស្ត្រីដែលឆ្លងកាត់តាមរយៈវិស័យអប់រំ។ អថេរឯករាជទាំងនោះរួមមាន៖ ច្បាប់ជាតិ ច្បាប់អន្តរជាតិ និងគោលនយោបាយ យុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាលដែលបានចូលរួមលើកកម្ពស់ស្ត្រីជាដើម។

### ខ. ការប្រមូលទិន្នន័យ

ការប្រមូលទិន្នន័យនេះសម្រាប់កិច្ចការមួយនេះដោយមើលទៅលើការកំណត់អថេរដូចជា៖ ការប្រមូលទិន្នន័យចម្បងដោយដកស្រង់ការសម្ភាសន៍សំណេះសំណាលប្រមូលបាននូវបច្ចុប្បន្នភាពនៃការពង្រឹងសមត្ថភាពស្ត្រីនៅក្នុងសង្គមស៊ីវិលនិងក្នុងមូលដ្ឋាន និងស្វែងរកទិន្នន័យដែលបានស្រាវជ្រាវស្រាប់ជាឯកសារគតិយុត្តមកឆ្លើយតបជាមួយការពង្រឹងសមត្ថភាពស្ត្រីក្នុងសម័យនីតិរដ្ឋមួយនេះ។

**ការប្រមូលទិន្នន័យចម្បង**

ផ្អែកតាមការផ្តល់កិច្ចសម្ភាសន៍របស់អភិបាលខេត្តបន្ទាយមានជ័យគឺ លោក អ៊ុំ រាត្រី ក្នុងឱកាសសំណេះសំណាលជាមួយស្ត្រីដែលជាអ្នកដឹកនាំមកពីស្ថាប័នគ្រូពេទ្យ គ្រូបង្រៀន និស្សិត នៅខេត្តបន្ទាយមានជ័យជាមួយនិងគេហទំព័រសារព័ត៌មាន EAC News Cambodia ចេញផ្សាយកាលពីថ្ងៃទី ០៧ ខែឧសភា ឆ្នាំ ២០២២។

លើសពីនេះ ក៏បានដកស្រង់សម្តីរបស់ស្ត្រីម្នាក់ដែលបានធ្វើការផ្តល់បទសម្ភាសន៍នៅក្នុងគេហទំព័រភ្នំពេញប៉ុស្តិ៍ គឺអ្នកស្រី ស៊ុយ សុខា ដែលជាដៃគូរគ្រប់គ្រងក្រុមហ៊ុន HRINC (Cambodia) Co Ltd ដែលទាក់ទងសកម្មភាពនិងសមត្ថភាពស្ត្រី នៅក្នុងបទសម្ភាសន៍"ស្ត្រីគឺជាកម្លាំងការងារដ៏សំខាន់ខណៈពេលស្ត្រីជួយជំរុញកំណើនសេដ្ឋកិច្ចនិងទីផ្សារប្រើប្រាស់" ចេញផ្សាយកាលពីថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ២០២២។

**ការប្រមូលទិន្នន័យដែលមានស្រាប់**

ជាឯកសារដែលរកបានតាមបណ្ណាគារនានា តាមគេហទំព័រ សៀវភៅច្បាប់នានាដែលពាក់ព័ន្ធ និងឯកសារពាក់ព័ន្ធធនធានមនុស្សផងដែរ។ មិនត្រឹមតែប៉ុណ្ណោះ ក៏មានឯកសារជាច្រើនដែលជាស្នាដៃរបស់សាស្ត្រាចារ្យ សាស្ត្រាបណ្ឌិត លោកគ្រូអ្នកគ្រូ ជាមូលដ្ឋានយកធ្វើជាអថេរឯករាជដើម្បីយកមកគាំពារការពង្រឹងសមត្ថភាពស្ត្រីក្នុងសម័យនីតិរដ្ឋ។ ក្រៅពីនេះនៅមានការប្រមូលព័ត៌មានពីកាសែតនៅតាមទស្សនាវដ្តីចុះផ្សាយ និងខ្សែវីឌីអូជាដើមដែលបង្ហាញពីសកម្មភាពស្ត្រីនិងយេនឌ័រ។

**គ. វិភាគទិន្នន័យ**

ទិន្នន័យដែលប្រមូលបានមកគឺយកមកវិភាគដោយធ្វើការប្រៀបធៀបរវាងទ្រឹស្តីនិងច្បាប់ដែលកំពុងតែមានសុពលភាពដែលបានដាក់ចេញនិងការអនុវត្តជាក់ស្តែងលើការពង្រឹងសមត្ថភាពស្ត្រីក្នុងសម័យនីតិរដ្ឋតាមរយៈការអប់រំក្នុងគោលបំណងសិក្សាកឱ្យឃើញនូវភាពខ្លាំង និងភាពខ្សោយដើម្បីឆ្ពោះទៅរកការសន្និដ្ឋានរួមព្រមទាំងចូលរួមផ្តល់អនុសាសន៍នូវចំណុចដែលខ្វះខាតក្នុងគោលបំណងធ្វើឱ្យមានភាពប្រសើរជាងមុននៃការអភិវឌ្ឍសមត្ថភាពស្ត្រីក្នុងយុគសម័យនីតិរដ្ឋ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

**ជំពូកទី១ បទដ្ឋានគតិយុត្តក្នុងការគាំពារស្ត្រី** ៖ គឺលើកពីលិខិតបទដ្ឋានគតិយុត្តដែលគាំពារស្ត្រីនិងក្មេងស្រីនាពេលបច្ចុប្បន្នកំពុងទទួលបានការគាំទ្រនៅក្នុងសង្គមជាច្រើនរួមមាន៖ច្បាប់ជាតិ ច្បាប់អន្តរៈជាតិជាច្រើនដែលបានចូលរួមលើកកម្ពស់សិទ្ធិសេរីភាពស្ត្រីឱ្យចូលរួមនៅក្នុងសង្គមដោយគ្មានការរើសអើងឡើយ។

**ជំពូកទី២ ការពង្រឹងសមត្ថភាពស្ត្រីកម្ពុជានាសម័យនីតិរដ្ឋ** ៖ គឺបានលើកឡើងពីការពង្រឹងសមត្ថភាពស្ត្រីកម្ពុជានាយុគ្គសម័យនីតិរដ្ឋដែលផ្អែកតាមគោលនយោបាយ ផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលបានចូលរួមចំណែកលើកកម្ពស់សមត្ថភាពស្រ្តនិងការទទួលបានការអប់រំឱ្យល្អប្រសើរជាងមុន។

**ជំពូកទី៣ ពិភាក្សាលើលទ្ធផលការពង្រឹងសមត្ថភាពស្ត្រី ៖** គឺយើងពិភាក្សាលើលទ្ធផលនៃការពង្រឹងសមត្ថភាពរបស់ស្ត្រីដែលទទួលបានពីការគាំពារពីច្បាប់ជាតិ ច្បាប់អន្តរជាតិ គោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលដែលបានផ្តល់សិទ្ធិសេរីភាពស្មើគ្នាក្នុងការចូលរួមរបស់ស្ត្រីនៅក្នុងសង្គមគ្រប់វិស័យនិងគ្រប់ជាន់ថ្នាក់។

# ជំពូកទី១
# បទដ្ឋានគតិយុត្តក្នុងការគាំពារស្ត្រី

ជំពូកទី១ គឺលើកពីលិខិតបទដ្ឋានគតិយុត្តដែលគាំពារស្ត្រី និងក្មេងស្រីនាពេលបច្ចុប្បន្នកំពុងទទួលបានការគាំទ្រនៅក្នុងសង្គមជាច្រើនរួមមាន ច្បាប់ជាតិ និងច្បាប់អន្តរៈជាតិជាច្រើនដែលបានចូលរួមលើកកម្ពស់សិទ្ធិសេរីភាពស្ត្រីឱ្យចូលរួមក្នុងសង្គមដោយគ្មានការរើសអើងឡើយ។

## ១.១. ពន្យល់អត្ថន័យ

នាយុគសម័យនីតិរដ្ឋកម្ពុជាបានចូលរួមយ៉ាងសកម្មជាមួយច្បាប់អន្តរជាតិ និងការគោរពតាមកតិកាសញ្ញាស្តីពីការទប់ស្កាត់គ្រប់ទម្រង់នៃការរើសអើងស្ត្រីតាមរយៈការពង្រឹងសមត្ថភាពស្ត្រីនៅក្នុងការចូលរួមសកម្មភាពសង្គមដូចនិងបុរសផងដែរ។ ជាក់ស្តែងការបង្ហាញពីសកម្មភាពស្ត្រីជាឆ្អឹងខ្នងសំខាន់របស់ប្រទេសជាតិដែលមិនអាចអត់បាន។ ស្ត្រីជាឆ្អឹងខ្នងរបស់ប្រទេសជាតិដោយសារការចូលរួមរបស់ស្ត្រី គឺជាតម្រូវការចាំបាច់ក្នុងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងការរួមចំណែកដល់អភិបាលកិច្ចល្អដែលស្ត្រីបានចូលរួមក្នុងការអភិវឌ្ឍសង្គមកម្ពុជាតាំងពីបាតដៃទទេរហូតដល់មានការរីកចម្រើនលើគ្រប់វិស័យដល់បច្ចុប្បន្ន។ ម្យ៉ាងទៀត ស្ត្រីគឺជាមាតាដ៏ល្អរបស់កូនៗជាអ្នកជំនួញដ៏ឆ្លាតវៃ ជាភរិយាដ៏ល្អរបស់ស្វាមី ជាអ្នកប្រកាន់ខ្ជាប់នូវគោលការណ៍សីលធម៌របស់ព្រះពុទ្ធសាសនា ជាកងកម្លាំងដ៏មានថាមពលក្លាហានរបស់ជាតិ ជាអ្នកទាមទារសេរីភាពដ៏សកម្មរបស់ជាតិ ជាក្តីសង្ឃឹមរបស់បុរស ជាកម្លាំងដ៏មុតស្រួចរបស់សហគមន៍ក៏ដូចជាប្រទេសជាតិ ជាគ្រូបង្រៀនរបស់ជាតិ ជាមនុស្សស័ក្តិសមទីមួយនៅក្នុងវិស័យអប់រំនៅបឋមសិក្សា ជាអ្នកឈានមុខគេនៅក្នុងកិច្ចថែរក្សាវប្បធម៌។ សរុបជារួមមក ស្ត្រីគឺពិតជាមានតម្លៃដ៏ធំធេងណាស់សម្រាប់ប្រទេសជាតិក៏ដូចជាពិភពលោកទាំងមូល។ ទន្ទឹមនិងនេះ ស្ត្រីក៏មានលទ្ធភាពកាន់តែច្រើនក្នុងការទទួលបានការសិក្សាអប់រំ។[2]

## ១.២. ការកកើត និងការអភិវឌ្ឍសមត្ថភាពស្ត្រី

តាំងពីសម័យបុរាណកាលមកជាយូរហើយយើងតែងតែឮនូវពាក្យមួយឃ្លាថា «ស្ត្រីបង្វិលចង្ក្រានមិនជុំ» ពាក្យនេះបានឆ្លាក់ជាប់នៅក្នុងក្រអៅបេះដូងរបស់ស្ត្រីខ្មែរស្ទើរតែមិនអាចលុបជ្រះបានបាត់ទៅហើយវានៅតែបន្តជាឥទ្ធិពលមួយធ្វើឱ្យមានការបង្អាក់ដំណើរនៃការអភិវឌ្ឍសមត្ថភាពរបស់ស្ត្រីដែលបានកំណត់គោលដៅជីវិតរបស់ស្ត្រីថាស្ត្រីត្រឹមជាមេផ្ទះហើយពុំចាំបាច់រៀនច្រើនពេកឡើយ។ ប៉ុន្តែចំណេរក្រោយមកផ្នត់គំនិតទាំងនេះត្រូវបានលុបបំបាត់ជាបណ្តើរៗទៅហើយដោយសារតែបច្ចុប្បន្ននេះស្ត្រីគឺបានខិតខំការស្វែងរកចំណេះដឹងសម្រាប់អភិវឌ្ឍន៍ខ្លួនឯងជាបន្តបន្ទាប់ហ៊ានប្រឈមនិងបញ្ហាក្នុងការសម្រេចបំណងប្រាថ្នារបស់ខ្លួនដើម្បីចាប់យកក្តី

---

[2] គេហទំព័រ (https://eacnews.asia/home/details/12223)(ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០២២)

ស្រមៃ។ នៅក្នុងសង្គមបច្ចុប្បន្នស្រ្តីមិនមែនជាស្រ្តីមេផ្ទះតែមួយមុខប៉ុណ្ណោះទេតែជាបុគ្គលស្វែងរកប្រាក់ចំណូលសម្រាប់ផ្គត់ផ្គង់គ្រួសារជាអ្នកបណ្តុះបណ្តាលនិងជាអ្នកចូលរួមក្នុងការអភិវឌ្ឍសង្គមជាតិថែមទៀតផង។[3]

ចាប់តាំងពីថ្ងៃរំដោះថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ រហូតដល់ពេលបច្ចុប្បន្ននេះរាជរដ្ឋាភិបាលកម្ពុជាតែងតែយកចិត្តទុកដាក់ក្នុងការលើកកម្ពស់ស្រ្តីក្នុងសង្គមហើយបានចាត់ទុកការលើកកម្ពស់សមភាពយេនឌ័រគឺជាប្រធានបទដ៏មានអត្ថន័យល្អបំផុតដែលបង្ហាញឱ្យឃើញពីការដើរតួនាទីយ៉ាងសំខាន់របស់សុខសន្តិភាពក្នុងសង្គម ជាពិសេសគឺសុខសន្តិភាពដែលកម្ពុជារកបានយ៉ាងលំបាកបំផុតក្នុងរយៈពេលកន្លងមកនេះដែលជាលក្ខខ័ណ្ឌមិនអាចប្រកែកបានឡើយក្នុងការចូលរួមចំណែកជួយដល់ការលើកកម្ពស់សិទ្ធិសេរីភាពរបស់ស្រ្តីជួយឱ្យស្រ្តីមានតម្លៃកាន់តែខ្ពស់ឡើងនៅក្នុងសង្គម។ ក្រសួងស្ថាប័នពាក់ព័ន្ធដៃគូអភិវឌ្ឍន៍សង្គមស៊ីវិល វិស័យឯកជននិងជនរួមជាតិទាំងអស់បានអនុវត្តន៍នូវចំណុចសំខាន់ៗត្រូវរួមគ្នាយកចិត្តទុកដាក់តាមរយៈការផ្តល់អាទិភាពចំពោះការបង្កើនចំនួនស្រ្តីឱ្យមានតួនាទីជាថ្នាក់ដឹកនាំនៅគ្រប់វិស័យទាំងអស់ក្នុងសង្គម។

ក្រសួងអប់រំ យុវជន និងកីឡារ ជាតួរអង្គដ៏សំខាន់មានតួនាទីធ្វើការណែនាំដល់ប្រជាពលរដ្ឋទូទាំងប្រទេសក្នុងការផ្តល់ឱកាសដល់ស្រ្តីនិងក្មេងស្រីគ្រប់រូបទាំងអស់ឱ្យទទួលបានចំណេះដឹង និងសីលធម៌សង្គម។ ក្រសួងអប់រំបានធ្វើការវិនិយោគលើការសិក្សារបស់ក្មេងស្រីនៅគ្រប់កម្រិតសិក្សាទាំងអស់ជាពិសេសគឺក្នុងជំនាញវិទ្យាសាស្រ្ត បច្ចេកវិទ្យាដើម្បីធ្វើឱ្យដើរទាន់សម័យបច្ចេកវិទ្យាជឿនលឿននៃសង្គមជាតិ។ ការលើកកម្ពស់សិទ្ធិនិងសេចក្តីថ្លៃថ្នូរក៏ដូចជាគុណតម្លៃសម្រាប់ស្រ្តីមិនអាចមានប្រសិទ្ធភាពត្រឹមតែជាការថ្លែងសារតាមរយៈមាត់ប៉ុណ្ណោះនោះទេហើយក៏មិនអាស្រ័យលើការវិនិច្ឆ័យរបស់សង្គមក្នុងការដាក់គំនាប ឬ បន្ទោសបង្អាប់បន្ថែមមកលើស្រ្តីដែលជាជនរងគ្រោះពីការរើសអើងនេះបានទេ ប៉ុន្តែការទាមទារនូវការគោរពនិងការគាំពារជាក់ស្តែងដោយធានាថាសិទ្ធិពលរដ្ឋនិងសិទ្ធិស្រ្តីគ្រប់រូបអាចចូលរួមយ៉ាងសកម្មក្នុងជីវភាពសង្គម វប្បធម៌សេដ្ឋកិច្ចនិងនយោបាយ។[4]

[3] ឯកសារស្រ្តីក្នុងភាពជាអ្នកដឹកនាំរបស់លោកបណ្ឌិត ទុយ យូឃីម និងលោកស្រីបណ្ឌិត ជា វណ្ណី នៃវិទ្យាស្ថានមនុស្សសាស្រ្តសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា (ទំព័រទី ១៣)

[4] ឯកសារស្រ្តីក្នុងភាពជាអ្នកដឹកនាំ របស់លោកបណ្ឌិត ទុយ យូឃីម និងលោកស្រីបណ្ឌិត ជា វណ្ណី នៃវិទ្យាស្ថានមនុស្សសាស្រ្តសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា (ទំព័រទី ១៤)

**ក.សមត្ថភាពស្ត្រីខ្មែរមុនសម័យសង្គមរាស្ត្រនិយម( ពីសម័យបុរាណរហូតមកដល់ក្រោយចប់សង្គ្រាមលោកលើកទី១ )**

តាមប្រវត្តិសាស្ត្ររបស់កម្ពុជាបង្ហាញឱ្យឃើញថាស្ត្រីពិតជាបានចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពសង្គមតាំងពីសតវត្សទី១រហូតដល់សម័យអង្គរមកហើយបានឆ្លុះបញ្ចាំងឱ្យឃើញតាមរយៈអរិយធម៌របស់ប្រជាជនកម្ពុជាដែលបានឱ្យដឹងថាស្ត្រីខ្មែរមានតួនាទីសំខាន់ណាស់នៅក្នុងសង្គមជាតិហើយស្ត្រីខ្មែរមានសិទ្ធិចូលរួមក្នុងជីវភាព នយោបាយ សេដ្ឋកិច្ច និងវប្បធម៌ តាំងពីចាប់ផ្ដើមកកើតទឹកដីខ្មែរមកម្ល៉េះ។

បើយោងតាមប្រវត្តិសាស្ត្រជាក់ស្ដែងរបស់កម្ពុជានាសម័យនគរភ្នំនៅសតវត្សទី១ ដែលបានបញ្ជាក់ថាមានស្ដេចស្រីខ្មែរមួយអង្គគឺព្រះនាងលីវយី ឬ ព្រះនាងសោមា ជាអ្នកដឹកនាំគ្រប់គ្រងប្រទេសជាតិឱ្យមានការរីកចម្រើនក្រៃលែងដោយសារតែព្រះនាងបានបង្កើតស្ថាប័ននានាដែលធានានូវស្ថេរភាពនយោបាយ និងរៀបចំរបបនៃការគ្រប់គ្រងតាមរបបមាតាធិបតេយ្យដែលជារបបមួយឱ្យតម្លៃទៅលើស្ត្រីជាធំ ស្ត្រីជាមេដឹកនាំស្ត្រីជាមេគំនិតក្នុងការដោះស្រាយបញ្ហាគ្រួសារនិងសង្គមជាតិ។ ក្រោយមកនៅសម័យអង្គរពីសតវត្សទី៩ដល់ទី១៤ ចំពោះការផ្ទេររាជ្យសម្បត្តិគឺធ្វើតាមរយៈការប្រកាន់យកខ្សែរខាងម្ដាយដោយផ្អែកតាមរូបភាពចម្លាក់លឹបមួយផ្ទាំងនៃប្រាសាទបាយ័នដែលបានបង្ហាញឱ្យឃើញពីគ្រួសារកងទ័ពមួយដែលចេញទៅធ្វើចម្បាំងជាមួយចាមទាំងគ្រួសារៗហើយរូបចម្លាក់នេះក៏បានបង្ហាញឱ្យឃើញពីការទទួលខុសត្រូវយ៉ាងច្រើនរបស់ស្ត្រីដោយដៃម្ខាងកណ្ដៀតកូននិងដៃម្ខាងកាន់លំពែងដើម្បីប្រយុទ្ធ ដៃម្ខាងទ្រទំនួល(ស្បៀង)។ ចំណែកករុំបង្វេចសម្លៀក ឬ ស្បៀង។ នៅឆ្នាំ ១២៩៥ ស្ត្រីមានសិទ្ធិពេញលេញក្នុងជីវភាពសង្គមដូចនៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ ព្រះអង្គបានប្រគល់តួនាទីដល់ព្រះរាជអគ្គមហេសីព្រះនាមឥន្ទ្រទេវី នៅក្នុងមុខងារជួយរៀបចំកម្មវិធីនយោបាយសង្គមកិច្ចវប្បធម៌ការគ្រប់គ្រងការពារជាតិ ការអប់រំបណ្ដុះបណ្ដាលចំណេះដឹង និងបណ្ដុះស្មារតីប្រជាពលរដ្ឋរហូតធ្វើឱ្យសម័យអង្គរស្គាល់នូវភាពរុងរឿងដ៏ល្បីល្បាញដោយសារតែមានព្រះនាងឥន្ទ្រទេវីជាទីប្រឹក្សាផ្ទាល់របស់ព្រះស្វាមីនេះឯង។ សរុបមក តាំងពីសម័យបុរាណតរៀងមកសង្គមខ្មែរឱ្យតម្លៃទៅលើស្ត្រីនិងទទួលយកលទ្ធិមាតេយ្យការដោយហេតុផលដ៏សក្តិសមបំផុត។[5]

កន្លងមកស្ត្រីត្រូវបានបែងចែកដោយព្រំដែនមួយដែលផ្អែកទៅលើជាតិពន្ធខុសគ្នាខាងភាសា វប្បធម៌ សេដ្ឋកិច្ច និងនយោបាយជាដើម។ បន្ទាប់មកស្ត្រីក៏បានចាប់ផ្ដើមក្រោកឈរដោយផ្ដើមចេញពីចលនាតស៊ូរបស់ស្ត្រីនៅសហរដ្ឋអាមេរិកកាលពីចុងសតវត្សទី១៩ ក្នុងការរំដោះខ្លួនចេញពីការកេងប្រវ័ញ្ចនានាក្នុងវិស័យឧស្សាហកម្ម ប៉ុន្តែក្រោយមកនារីត្រូវបានគេទទួលស្គាល់ និងផ្ដល់សិទ្ធិយ៉ាងពេញលេញនៅក្នុងការងារ និងសង្គមជាបន្តបន្ទាប់ចំពោះការខិតខំតស៊ូ ការសាមគ្គីរបស់នារីទូទាំងពិភពលោកដើម្បីសេរីភាពប្រជាធិបតេយ្យដោយភ្ជាប់

[5] គេហទំព័រ ៖ https://www.facebook.com/cambodiantemple/posts/) (ចេញផ្សាយថ្ងៃទី ២៧.៤.២០១៥)

នូវពាក្យស្លោកថាមួយថ្ងៃធ្វើការប្រាំបីម៉ោងធ្វើការស្មើគ្នាប្រាក់បៀវត្សស្មើគ្នាដើម្បីការរស់នៅក្នុងសង្គមដោយស្មើភាពជាមួយបុរស។[6]

### ខ. តួនាទីស្ត្រីនៅសម័យសង្គមរាស្ត្រនិយម

នៅក្នុងសម័យសង្គមរាស្ត្រនិយមនេះជាការគ្រប់គ្រង់លើកទីមួយរបស់ព្រះបាទនរោត្តមសីហនុ ឬព្រះរាជាណាចក្រទី១ ឬ សម័យសង្គមរាស្ត្រនិយមពីឆ្នាំ ១៩៥៣-១៩៧០ គឺជាដំណាក់កាលសំខាន់ពិសេសមួយនៅក្នុងប្រវត្តិសាស្ត្ររបស់កម្ពុជា។ លើសពីនេះ នៅក្នុងសម័យសង្គមរាស្ត្រនិយមមួយនេះស្ត្រីគឺមិនសិទ្ធិសេរីភាពច្រើននោះទេមានសិទ្ធិត្រឹមតែធ្វើការងារជាមេផ្ទះ ដេរប៉ាក់ ត្បាញហូល និងធ្វើសម្ភារៈប្រើប្រាស់ ជាអ្នកមើលថែរក្សាក្រុមគ្រួសារ មិនមានសិទ្ធិធ្វើការងារខាងក្រៅដើម្បីរកចំណូលនិងមិនអាចសិក្សារៀនសូត្របានខ្ពង់ខ្ពស់ដូចក្មេងបុរសឡើយ។ ចំណេរក្រោមមកគ្រប់យ៉ាងក៏ត្រូវបានផ្លាស់ប្តូរដោយសារតែមានការចូលរួមក្រោកឈរតស៊ូមតិក្នុងការផ្តល់សិទ្ធិសេរីភាពនិងភាពស្មើគ្នារវាងបុរសនិងស្ត្រី និងទាមទារឱ្យមានការលើកកម្ពស់ស្ត្រីឱ្យមានសិទ្ធិចូលរួមក្នុងសង្គមមានសិទ្ធិការទទួលបានភាពយុត្តិធម៌ស្ត្រីក៏មានសិទ្ធិចូលរួមទទួលបាននូវការសិក្សាគ្រប់កម្រិតដូចទៅនិងបុរសទទួលបានការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈមានសិទ្ធិចូលរួមក្នុងដំណើរការសេដ្ឋកិច្ចនិងការទទួលបានការងារមួយដែលសមរម្យមានប្រាក់បៀវត្សស្មើគ្នាទៅតាមមុខតំណែងដូចគ្នាស្ត្រីក៏មានសិទ្ធិធ្វើជាកងកម្លាំងការការពារទឹកដី មានឱកាសក្លាយជាអ្នកដឹកនាំ និងតួនាទីធ្វើសេចក្តីសម្រេចស្មើនិងបុរសដោយគ្មានការរើសអើងភេទឡើយ។ [7]

ជាក់ស្តែងដូចជាព្រះមហាក្សត្រយានី ស៊ីសុវត្ថិ កុសុមៈ នារីរ័ត្នសេរីវឌ្ឍនា (ទ្រង់ប្រសូតនៅថ្ងៃទី៩ ខែ មេសា ឆ្នាំ១៩០៤ គឺជាព្រះមហាក្សត្រយានីនិងសម្តេចព្រះរាជអគ្គមហេសី នៃព្រះបាទសម្តេចព្រះនរោត្តមសុរាម្រិតព្រះមាតានៃព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ និងជាព្រះរាជាធីតារបស់ព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិ មុនីវង្ស និងសម្តេចព្រះរាជអគ្គមហេសីនរោត្តម កាន វិមាននរល័ក្ខទេវី។ ព្រះអង្គជាស្ត្រីមួយរូបដែលមានចំណេះដឹង មានសមត្ថភាព និងចូលរួមនៅក្នុងការងារសង្គមដោយបានចំណាយពេលវេលា និងកម្លាំងកាយចិត្តក្នុងការងារសប្បុរសធម៌ជួយដល់ប្រជាជនដែលមានទុកលំបាកនិងខិតខំប្រឹងប្រែងរបស់ព្រះអង្គក្នុងការលើកកម្ពស់ការអប់រំរបស់ប្រជាជនឱ្យទទួលបានដំណេះដឹងគ្រប់ៗគ្នានិងមានភាពស្មើៗគ្នាមានសុខុមាលភាពនៅក្នុងសង្គម។ ម្យ៉ាងទៀត ព្រះអង្គក៏ជាអ្នកដែលចូលរួមការតស៊ូមតិដ៏រឹងមាំ

[6] គេហទំព័រ ៖ រាជ្យបណ្ឌិតសភាកម្ពុជា (ចេញផ្សាយថ្ងៃទី២២,៣,២០២០)

[7] វីឌីអូ ស្ត្រីខ្មែរសង្គមរាស្ត្រនិយម ១៩៥៨

សម្រាប់ការទាមទារការផ្តល់សិទ្ធិដល់ស្ត្រីមិនឱ្យមានរើសអើងស្ត្រី និងបានដើរតួនាទីយ៉ាងសកម្មក្នុងការលើកកម្ពស់ការអប់រំ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រីឱ្យស្មើគ្នានិងបុរស។[8]

**គ. ស្ត្រីក្រោយសម័យសង្គមរាស្ត្រនិយម(សម័យបច្ចុប្បន្ន)**

នាពេលបច្ចុប្បន្នស្ត្រីនិងក្មេងស្រីទទួលបានការគាំទ្រ និងការគាំពារនៅក្នុងសង្គមជាច្រើនពីមួយសម័យកាលទៅមួយសម័យកាលដោយកន្លងមកស្ត្រីត្រូវបានសង្គមចាត់ទុកជាភេទមួយដែលទន់ខ្សោយ និងភាគច្រើនទទួលបន្ទុកកិច្ចការងារផ្ទះសម្បែង ឬ និយាយសាមញ្ញថាការងារចង្ក្រានចានឆ្នាំង ការមើលថែកូនចៅទ្រព្យសម្បត្តិ និងឪពុកម្តាយជាដើម។ ប៉ុន្តែងាកមកមើលស្ត្រីក្នុងសង្គមកម្ពុជាសព្វថ្ងៃគ្រប់យ៉ាងហាក់បីដូចជាមានការប្រែប្រួលជាបន្តបន្ទាប់ហើយរាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងជំរុញលើកទឹកចិត្តគាំទ្រយ៉ាងខ្លាំងចំពោះស្ត្រីទាំងការទទួលបានការអប់រំ ការងារ និងតួនាទីសំខាន់ដែលទាក់ទងក្នុងការធ្វើសេចក្តីសម្រេចចិត្តការងារនៅក្នុងសង្គម។ មួយវិញទៀត បើក្រឡេកមកមើលស្ត្រីខ្លួនឯងផ្ទាល់ក៏មិនដូចពីមុនដែលស្ត្រីតែងតែមានការខិតខំសិក្សារៀនសូត្រនិងស្វែងរកចំណេះដឹងសម្រាប់អភិវឌ្ឍន៍ខ្លួនដើម្បីចាប់យកឱកាសល្អៗក្នុងការបំពេញការងារហើយសង្គមបានកំពុងបើកឱកាសយ៉ាងពេញលេញចំពោះស្ត្រីដើម្បីទទួលបានការអភិវឌ្ឍសមត្ថភាពបន្ថែមទៀត។ ការងារមួយចំនួនដែលកម្របានឃើញស្ត្រីចាប់អារម្មណ៍ធ្វើនិងមិនសូវទទួលបានការគាំទ្រនិងការលើកទឹកចិត្តតែជាការពេញចិត្តរបស់ស្ត្រីផ្ទាល់ទើបជំរុញចិត្តឱ្យស្ត្រីមានការខិតខំប្រឹងប្រែងព្យាយាមបំពេញការងារឱ្យបានល្អប្រសើរមិនចាញ់បុរសនោះទេ។ បើគិតចាប់តាំងពីថ្ងៃរំដោះរហូតដល់ពេលបច្ចុប្បន្នរាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ក្នុងការលើកកម្ពស់ស្ត្រីរហូតបង្កើតបានជាពាក្យស្លោកថា "ស្ត្រីជាឆ្អឹងខ្នងប្រទេសជាតិ" ដោយសាស្ត្រីបានចូលរួមចំណែកក្នុងកិច្ចការងារជាច្រើនវិស័យមានដូចជាវិស័យអប់រំ វិស័យនយោបាយ និងវិស័យសេដ្ឋកិច្ចហើយស្ត្រីក៏បានក្លាយជាកម្លាំងចលករដែលបានរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចជាតិ និងជួយអភិវឌ្ឍន៍សង្គមជាតិទាំងមូលផងដែរ។[9]

---

[8] គេហទំព័រ ៖ https://km.m.wikipedia.org/ (ចេញផ្សាយថ្ងៃទី ២៧/៣/២០២៤)

[9] គេហទំព័រ ៖ (Radio Veritas Asai KHMER )( ចេញផ្សាយថ្ងៃទី 20,3,2023)

## ១.៣. បទដ្ឋានគតិយុត្តក្នុងការគាំពារសមត្ថភាពស្ត្រី

### ១.៣.១. ការគាំពារស្ត្រីតាមរយៈច្បាប់ជាតិ

#### ក.ការគាំពារស្ត្រីតាមរយៈរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

នាពេលបច្ចុប្បន្ននេះការផ្លាស់ប្តូរមុខមាត់របស់ស្ត្រីនៅកម្ពុជាក្នុងសម័យនីតិរដ្ឋនេះគឺរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានគាំពារដោយការផ្តល់សិទ្ធិដល់ស្ត្រីក្នុងការចូលរួមនិងការពង្រឹងសមត្ថភាពស្ត្រីតាមរយៈទទួលបានការសិក្សាការអប់រំតាំងពីកុមារភាពដូចគ្នានិងក្មេងប្រុសដែរនិងលើកកម្ពស់ស្ត្រីដែលគោរពតាមគោលការណ៍យេនឌ័រមានដូចជា៖

ការគាំពារស្ត្រីដែលបានឆ្លុះបញ្ចាំតាមរយៈរដ្ឋធម្មនុញ្ញផ្អែកតាមមាត្រា ៤៥ ចែងថា"ការរើសអើងគ្រប់ប្រភេទប្រឆាំងនិងស្ត្រីត្រូវលុបបំបាត់ចោល" នេះគឺជាសញ្ញាណដែលបង្ហាញពីការគាំពារស្ត្រីយ៉ាងពេញលេញក្នុងការចូលរួមសកម្មភាពក្នុងសង្គមខុសពីជំនាន់ដើមដែលស្ត្រីមិនអាចមានសិទ្ធិចូលរួមនៅក្នុងសកម្មភាពសង្គមបាននោះទេដោយសារតែមានការគៀបសង្កត់ពីគ្រួសារ សាច់ញ្ញាតិនិងប្តី។ កាលជំនាន់សម័យសង្គមរាស្ត្រនិយម ឬ ព្រះរាជាណាចក្រកម្ពុជាទី១ ស្ត្រីដែលទៅធ្វើការងារខាងក្រៅដោយគ្មានការអនុញ្ញាតពីប្តីគឺប្តីមានសិទ្ធិទៅមោឃភាពការងាររបស់ប្រពន្ធបាន។[10] មាត្រា ៤៨ " រដ្ឋធានារក្សាការពារសិទ្ធិកុមារ ...សិទ្ធិទទួលបានការអប់រំរៀនសូត្រ" កុមារត្រង់នេះមានន័យទាំងកុមារានិងកុមារីត្រូវបានរដ្ឋធានាដល់កុមារកម្ពុជាទាំងកុមារីនូវសិទ្ធិទទួលបានការអប់រំ។[11] នៅត្រង់បញ្ញត្តិមួយនេះគឺបានបង្ហាញពីចំណុចចាប់ផ្តើមនៃការពង្រឹងសមត្ថភាពស្ត្រីពីកុមារភាពប្រកៀកស្មាជាមួយបុរស។ គោលនយោបាយរបស់រាជរដ្ឋាភិបាលគឺរដ្ឋផ្តល់ការអប់រំផ្នែកបឋមសិក្សា និងមធ្យមសិក្សាដល់កុមារគ្រប់រូបទាំងអស់នៅសាលារៀនសាធារណៈដោយឥតបង់ថ្លៃ។ ប្រជាពលរដ្ឋត្រូវបានទទួលការអប់រំយ៉ាងតិចប្រាំបួនឆ្នាំ។[12] ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិជ្រើសរើសមុខរបរឱ្យសមស្របទៅតាមសមត្ថភាពរបស់ខ្លួនតាមសេចក្តីត្រូវការរបស់សង្គម។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នាចំពោះការងារដូចគ្នា។[13]

---

[10] ច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មាត្រា ៤៥

[11] ច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ (មាត្រា ៤៨)

[12] ច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ (មាត្រា៦៨ កថាខណ្ឌទី១,២)

[13] ច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ (មាត្រា ៣៦ កថាខណ្ឌទី១,២)

តាមរយៈការទទួលស្គាល់និងការគោរពសិទ្ធិមនុស្សដូចដែលមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សនិងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយដែលបានទាក់ទងទៅនិងសិទ្ធិមនុស្ស សិទ្ធិនារីនិងសិទ្ធិកុមារ។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិចូលរួមយ៉ាងសកម្មនៅក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ។ [14]

ចំពោះច្បាប់អង្គការផ្សេងៗទៀតក៏មិនមានច្បាប់ណាមួយដែលបានបិទសិទ្ធិសេរីភាពស្ត្រីមិនឱ្យចូលរួមនៅក្នុងសង្គមឡើយដែលផ្ទុយកាលពីសម័យកាលមុនដែលបានបង្ហាញឱ្យដឹងតាមរយៈច្បាប់ និងប្រវត្តិសាស្ត្រជាក់ស្តែងនៅសម័យសង្គមរាស្ត្រនិយមដែលមានការរឹតត្បិតពីសកម្មភាពស្ត្រីចូលរួមសកម្មភាពសង្គម។

**ខ.ការគាំពារស្ត្រីតាមរយៈការងារ**

នៅក្នុងវិស័យការងារនេះបានបង្ហាញឱ្យដឹងពីសិទ្ធិនិងអត្ថប្រយោជន៍របស់ស្ត្រីដែលទទួលបានពីការគាំពារដើម្បីលើកកម្ពស់ និងជម្រុញឱ្យស្ត្រីមានភាពក្លាហានក្នុងការចូលរួមសកម្មភាពនិងបញ្ចេញសមត្ថភាពរបស់ខ្លួនឱ្យបានទូលំទូលាយនិងមានប្រសិទ្ធភាពជាងមុន។ ការចូលរួមរបស់ស្ត្រីក្នុងវិស័យការងារបានផ្តល់ឱ្យស្ត្រីមកវិញនូវសិទ្ធិនិងអត្ថប្រយោជន៍ជាច្រើនរួមមានសមភាពការងារភាពស្មើគ្នានិងកម្មករនិយោជិតទាំងជាបុរសដែលស្ត្រីត្រូវទទួលបានពីសហគ្រាស ឬ គ្រឹះស្ថានដែលខ្លួនបំពេញការងារ ស្ត្រីទទួលបានប្រាក់កម្រៃស្មើគ្នា ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការតម្លើងថ្នាក់ ឬ ឋានន្តរសក្តិ ការកំណត់បែងចែកការងារ និងលក្ខខណ្ឌការងារផ្សេងៗដូចនិងបុរស។[15]

លើសពីនេះ ច្បាប់ការងារបានធានានូវសិទ្ធិស្មើគ្នារវាងបុរសនិងស្ត្រីក្នុងការធ្វើការងារនៅក្នុងវិស័យឯកជនមានក្រុមហ៊ុន ឬ អង្គភាពមួយដោយមិនអាចប្រើប្រាស់បញ្ហាភេទធ្វើជាលេសដើម្បីសម្រេចអំពីការជួល ឬ កំណត់និងការបែងចែកការងារ ការបណ្តុះបណ្តាល ការតម្លើងថ្នាក់និងឋានន្តរសក្តិ ការទទួលបានប្រាក់កម្រៃដែលសមរម្យស្មើនិងបុរស ការផ្តល់អត្ថប្រយោជន៍សង្គមនិងវិន័យ ឬ ការផ្តាច់កិច្ចសន្យាដោយមានការរើសអើងស្ត្រីបាននោះទេ។ ប៉ុន្តែក្នុងករណីការបែងចែក និងការបដិសេធ ឬ ការព្រមទទួលដែលផ្អែកលើលក្ខណៈសម្បត្តិជាកំណត់សម្រាប់មុខងារណាមួយមិនត្រូវបានចាត់ទុកជាការរើសអើងឡើយ។[16]

[14] ច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ (មាត្រា ៣៥ វាក្យខណ្ឌទី១)

[15] កម្មវិធីយល់ដឹងផ្នែកច្បាប់របស់អង្គភាពព័ត៌មាន Fresh News សហការជាមួយក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ (https://m.freshnewsasia.com/ )(ចេញផ្សាយថ្ងៃទី ២៩/៤/២០១៩)

[16] ច្បាប់ស្តីពីការងារ ១៩៩៣ (មាត្រ១៨៣)

ច្បាប់ស្តីពីការងារក៏ធានាសុខមាលភាពរបស់ស្ត្រីនៅពេលសម្រាលកូន គឺមានន័យថាស្ត្រីទាំងឡាយត្រូវមានសិទ្ធិឈប់សម្រាកចំនួន ៩០ថ្ងៃ ឬ ច្រើនជាងនេះតាមការព្រមព្រៀងរបស់ស្ថាប័ន ឬ អង្គភាពដើម្បីសម្រាលកូន។ និយោជកមិនអាចបញ្ឈប់ស្ត្រីនៅពេលសម្រាលកូន ឬ នៅក្នុងថ្ងៃណាមួយនៅពេលឈប់សម្រាកបើទោះបីដោយវិធីឱ្យដំណឹងមុនក៏ដោយ។ កំឡុងពេលឈប់សម្រាលលំហែមាតុភាពស្ត្រីមានសិទ្ធិទទួលបានប្រាក់ឈ្នួលពាក់កណ្តាលគិតទាំងប្រាក់បន្ទាប់បន្សំ។[17] នៅក្នុងរយៈពេលមួយឆ្នាំចាប់ពីថ្ងៃដែលសំរាលកូនរួចស្ត្រីដែលឱ្យកូនបៅដោះអាចមានពេលមួយម៉ោងក្នុងមួយថ្ងៃដើម្បីបំបៅកូនរបស់ខ្លួនក្នុងពេលម៉ោងធ្វើការរយៈពេល១ ម៉ោង ឬ អាចចែកចេញជាពីរវគ្គដែលក្នុងមួយវគ្គមាន ៣០នាទី គឺពេលធ្វើការព្រឹកម្តងនិងពេលធ្វើការរសៀលម្តង ឬ នៅម៉ោងណាដែលស្ត្រីបានព្រមព្រៀងជាមួយនិយោជក ឬ ម្ចាស់សហគ្រាស។ ប្រសិនបើគ្មានការព្រមព្រៀងទេត្រូវយកម៉ោងនៅពាក់កណ្តាលពេលនៃរយៈពេលម៉ោងធ្វើការនីមួយៗ។[18] ក្នុងពេលសម្រាកលំហែមាតុភាពកិច្ចសន្យាការងារមិនត្រូវបានកាត់ផ្តាច់ទេ ដូចនេះកម្មករនិយោជិតគួរតែទទួលបាននូវការឈប់សម្រាកប្រចាំឆ្នាំពេញលេញបើទោះបីជាមិនមានវត្តមាននៅកន្លែងធ្វើការក៏ដោយ។ បើតាមច្បាប់ការងារក្រុមហ៊ុននិងវត្ថុអំណោយផ្សេងៗអង្គភាពមួយត្រូវឱ្យតម្លៃស្មើគ្នាទៅនិងបុរសក្នុងការធ្វើការនិងមិនអាចប្រើប្រាស់បញ្ហាភេទមកធ្វើជាលេសដើម្បីឱ្យស្ត្រីធ្វើការស្មើគ្នាទៅនិងបុរសម្រេចចិត្តអ្វីមួយនិងធ្វើការបញ្ឈប់ស្ត្រីពីការងារនៅពេលសម្រាកសម្រាលកូន។

**គ. ការគាំពារស្ត្រីតាមរយៈបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ**

ដើម្បីស្របនិងការចែងតាមមាត្រា ៣៤ នៃច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ ដែលបានចែងថា" ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឱ្យគេបោះឆ្នោតបាន" នៅត្រង់ចំណុចនេះមានន័យថាប្រជាពលរដ្ឋគ្រប់រូបទោះបីជាស្ត្រីក៏ដោយគឺមានសិទ្ធបោះឆ្នោតជ្រើសរើសតំណាងរបស់ខ្លួនដោយសេរីនិងមានសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតដូចគ្នានិងបុរសដោយគ្មានការរើសអើងភេទឡើយ។[19] ច្បាប់បោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនេះគឺមានគោលបំណងលើកកម្ពស់ការចូលរួមរបស់ស្ត្រីឈរតំណាងរបស់ប្រទេសផងដែរដោយបានលើកឡើងថាបេក្ខជនទាំងពីរភេទគឺបុរសនិងស្ត្រីមានសិទ្ធិឈរឈ្មោះជាតំណាងរាស្ត្រឱ្យគេបោះឆ្នោតឱ្យបើសិនជាបំពេញទៅតាមលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ។ ការឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រមួយនេះគឺមិន

[17] ច្បាប់ស្តីពីការងារ ១៩៩៣ (មាត្រ១៨២)

[18] ច្បាប់ស្តីពីការងារឆ្នាំ ១៩៩៧ (មាត្រា១៨៤)

[19] ច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ (មាត្រា៣៤)

អាចប្រើប្រាស់បញ្ហាភេទជាស្ត្រី ឬ បុរសមកធ្វើជាលេសដើម្បីហាមឃាត់មិនឱ្យសមាជិកគណៈបក្សដែលជាស្ត្រីឈរឈ្មោះបានឡើយ។ សរុបមក បេក្ខជនទាំងពីរភេទបុរសនិងស្ត្រីមានសិទ្ធិស្មើគ្នាក្នុងការឈរឈ្មោះជាតំណាងរាស្ត្រឱ្យគេបោះឆ្នោតឱ្យប្រសិនបើអាចបំពេញទៅតាមលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ។[20]

## ១.៣.២.ការគាំពារស្ត្រីតាមរយៈច្បាប់អន្តរជាតិ

នៅព្រះរាជាណាចក្រកម្ពុជាបានធ្វើការចុះហត្ថលេខា និងផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិដែលស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនិងស្ត្រីភេទនៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩២ និងផ្តល់សច្ចាប័នក្លាយទៅជារដ្ឋភាគីនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២។ នៅក្នុងពិធីសារតាមជម្រើសនៃអនុសញ្ញាបានចុះហត្ថលេខានៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ ២០០១ និងផ្តល់សច្ចាប័ននៅថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១០។ អនុសញ្ញានេះរួមបញ្ចូលនូវវិធានការលើកកម្ពស់ស្ថានភាពស្ត្រីនិងសិទ្ធិស្ត្រីតាមរយៈដំណើរការច្បាប់ និងការអនុវត្តរបស់រាជរដ្ឋាភិបាលកម្ពុជា។ នៅក្នុងការបំពេញកាតព្វកិច្ចជារដ្ឋភាគីកម្ពុជាបានផ្ញើរបាយការណ៍ជូនគណៈកម្មាធិការអង្គការសហប្រជាជាតិដែលទទួលបន្ទុកចំនួនពីរលើកគឺនៅឆ្នាំ ២០០៣ របាយការណ៍ជួបលើកដំបូង លើកទី២និងលើកទី៣ ហើយបានទទួលមកវិញនូវយោបល់សន្និដ្ឋានចំនួន ៤២ ចំណុចនៅឆ្នាំ ២០០៦។ នៅឆ្នាំ ២០១០ កម្ពុជាបានផ្ញើរបាយការណ៍ជួបលើកទី៤និងលើកទី៥ ហើយបានទទួលមកវិញនូវសេចក្តីសង្កេតសន្និដ្ឋានចំនួន ៥២ចំណុចនៅឆ្នាំ ២០១៣។ នៅក្នុងផែនការនារីរតនៈទី ៤ របស់ក្រសួងកិច្ចការនារីក៏បានបញ្ចូលនូវសេចក្តីសន្និដ្ឋានទាំងនោះផងដែរ។ រាជរដ្ឋាភិបាលកម្ពុជាបានចូលរួមក្នុងសន្និសីទស្តីពីស្ត្រីពិភពលោកលើកទី៤ ដែលប្រារព្ធឡើងនៅក្នុងទីក្រុងប៉េកាំងដែលបានអនុម័តនូវផែនការសកម្មភាពទីក្រុងប៉េកាំង និងបានរៀបចំរបាយការណ៍រីកចម្រើនចាប់ពីឆ្នាំ ១៩៩៥ មក។[21]

### ក.ការទទួលបានការគាំពារតាមរយៈការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនិងស្ត្រីភេទ(CEDAW)

ប្រទេសកម្ពុជាបានផ្តល់សច្ចាប័ននៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២ នៅក្នុងចំណោមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិជាច្រើនមានតែអនុសញ្ញា (CEDAW) នេះតែប៉ុណ្ណោះដែលបានផ្តោតយ៉ាងជាក់លាក់ទៅលើកិច្ចការពារសិទ្ធិស្ត្រី។ អនុសញ្ញានេះទាមទារឱ្យរដ្ឋភាគីពង្រឹងការអនុវត្តសិទ្ធិស្ត្រីឱ្យបានទៀងទាត់និងធ្វើការ

[20] ច្បាប់ស្តីពីវិសោធន៍កម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ,លេខនស/រកម/០៧១១/០១៣, ថ្ងៃទី០៤.កក្កដា.២០១១ (មាត្រា៥)

[21] សេចក្តីសង្ខេបសម្រាប់គោលនយោបាយ១ ការបញ្ជ្រាបយេនឌ័រ បរិបទគោលនោបាយ ស្ថាប័ន និងភាពជាដៃគូ ការប៉ាន់ប្រម៉ាណអំពីយេនឌ័រនៅកម្ពុជា ២០១៤(ទំព័រ ៥)

ចោលទោសរាល់ទម្រង់ទាំងអស់នៃការរើសអើងលើស្ត្រីដូចជាអនុវត្តន៍នូវរាល់វិធានការដែលសមស្រប ទាំងអស់។ អនុសញ្ញានេះក៏បានចែងថាការរើសអើងលើស្ត្រីមានន័យថាជាការបែងចែក ការផាត់ចេញ ឬ ការរឹតត្បិតដែលធ្វើឡើងដោយសារតែភេទដែលធ្វើឱ្យមានផលប៉ះពាល់ ឬ មានគោលបំណងធ្វើឱ្យខូច ឬ លុបចោលការទទួលស្គាល់ ការទទួលបានការអនុវត្តសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋានរបស់ស្ត្រីនៅក្នុង វិស័យនយោបាយ សេដ្ឋកិច្ច សង្គម វប្បធម៌ ស៊ីវិល ឬវិស័យផ្សេងៗទៀត។ រដ្ឋភាគីត្រូវដាក់បញ្ចូលគោលការណ៍ សមភាពរវាងបុរសនិងស្ត្រីទៅក្នុងរដ្ឋធម្មនុញ្ញជាតិរបស់ខ្លួន ឬ ច្បាប់ផ្សេងៗទៀតដែលសមស្រប។[22] ការធានា ឱ្យមានការអភិវឌ្ឍនិងការលើកកម្ពស់ស្ត្រីឱ្យបានពេញលេញក្នុងគោលបំណងដើម្បីផ្តល់ការធានាឱ្យពួកគេ អាចប្រតិបត្តិ និងទទួលបានសិទ្ធិមនុស្សសេរីភាពជាមូលដ្ឋានដោយស្មើភាពគ្នាជាមួយនិងបុរសរួមទាំងបាន លើកឡើងអំពីកិច្ចការពារ និងការលើកកម្ពស់សិទ្ធិស្ត្រីឱ្យស្មើភាពគ្នាជាមួយបុរស។[23] ក្រៅពីច្បាប់ក្នុងស្រុក ដែលផ្តល់សិទ្ធិស្មើគ្នាដល់បុគ្គលទាំងអស់នៅចំពោះមុខច្បាប់ និងកិច្ចការពារសិទ្ធិរបស់ស្ត្រីដែលត្រូវទទួល រងការរំលោភបំពានដោយខុសច្បាប់ហើយអនុសញ្ញានេះក៏អាចយកទៅអនុវត្តន៍ដោយផ្ទាល់ផងដែរដើម្បី ការពារសិទ្ធិស្ត្រីនៅក្នុងប្រទេសកម្ពុជា។

**ខ. សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស**

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សនេះគឺមានសុពលភាពចំពោះប្រទេសទាំងអស់ដែលជា សមាជិករបស់អង្គការសហប្រជាជាតិ។ មនុស្សគ្រប់រូបកើតមកមានសេរីភាពនិងសមភាពនៅក្នុងផ្នែកនៃ សេចក្តីថ្លៃថ្នូរ និងសិទ្ធ។[24] មនុស្សគ្រប់រូបមានសិទ្ធិធ្វើការងារដោយជ្រើសរើសការងារដោយសេរីនិងធ្វើការងារ ក្នុងលក្ខខណ្ឌត្រឹមត្រូវនិងពេញចិត្តព្រមទាំងការពារប្រឆាំងនិងភាពអត់ការងារធ្វើ។ មនុស្សគ្រប់រូបមានសិទ្ធិ ទទួលប្រាក់បៀវត្សស្មើគ្នាចំពោះការងារដូចគ្នាដោយគ្មានការរើសអើង។ អ្នកធ្វើការងារមានសិទ្ធិទទួលបាន ភាគលាភការដោយសមធម៌និងពេញចិត្តដើម្បីធានាអាទិភាពរស់នៅរបស់ខ្លួននិងគ្រួសារឱ្យសមស្របទៅ និង សេចក្តីថ្លៃថ្នូររបស់មនុស្ស និងត្រូវបានបំពេញបន្ថែមទៀតតាមមធ្យោបាយផ្សេងៗនៃការការពារផ្នែកសង្គម ប្រសិនបើចាំបាច់។ មនុស្សគ្រប់រូបមានសិទ្ធិបង្កើតនិងចូលរួមសហជីព។[25] មនុស្សគ្រប់រូបមានសិទ្ធិទទួល

[22] អនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ CEDAW (មាត្រា១)

[23] អនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ CEDAW (មាត្រា២)

[24] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ១០ ធ្នូ ១៩៤៨ (មាត្រា១)

[25] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ១០ ធ្នូ ១៩៤៨ (មាត្រា ២៣)

បានការអប់រំដោយឥតបង់ថ្លៃយ៉ាងហោចណាស់សម្រាប់ការអប់រំបឋមសិក្សានិងអប់រំមូលដ្ឋាន។ ការអប់រំបឋមសិក្សាគឺជាកាតព្វកិច្ច។ ការអប់រំខាងបច្ចេកទេសនិងវិជ្ជាជីវៈត្រូវរៀបចំឱ្យមានជាទូទៅ។ ការអប់រំថ្នាក់ឧត្តមសិក្សាត្រូវបើកឱ្យចូលរៀនស្មើភាពគ្នាដោយឈរលើមូលដ្ឋានសមភាព។ ការអប់រំត្រូវសំដៅទៅរកការរីកលូតលាស់ពេញលេញនៃបុគ្គលិកលក្ខណៈរបស់មនុស្សនិងការពង្រឹងការគោរពសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋាន។ ការអប់រំនេះគឺត្រូវលើកកម្ពស់ការយល់ដឹង ការចេះអត់ឱនអធ្យាស្រ័យគ្នានិងមិត្តភាពរវាងប្រជាជាតិ និងក្រុមពូជសាសន៍ ឬ ក្រុមសាសនារួមទាំងការអភិវឌ្ឍសកម្មភាពរបស់សហប្រជាជាតិក្នុងការថែរក្សាសន្តិភាព។[26]

[26] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស១០ ធ្នូ ១៩៤៨ (មាត្រា ២៦)

# ជំពូកទី២
# ការពង្រឹងសមត្ថភាពស្ត្រីកម្ពុជានាសម័យនីតិរដ្ឋ

ជំពូកទី២ គឺបានលើកឡើងពីការពង្រឹងសមត្ថភាពស្ត្រីកម្ពុជានាយុគ្គសម័យនីតិរដ្ឋដែលផ្អែកតាមគោលនយោបាយ ផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលបានចូលរួមចំណែកលើកកម្ពស់សមត្ថភាពស្ត្រីនិងការទទួលបានការអប់រំឱ្យល្អប្រសើរជាងមុន។

## ២.១.ការពង្រឹងសមត្ថភាពស្ត្រីតាមរយៈគោលនយោបាយរបស់រាជរដ្ឋាភិបាល

ដោយឃើញពីភាពសំខាន់នៃការចូលរួមចំណែករបស់យេនឌ័រនៅក្នុងសង្គមកម្ពុជាទើបនាពេលបច្ចុប្បន្ននេះរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ទៅលើការលើកកម្ពស់យេនឌ័រឱ្យមានភាពស្មើគ្នារវាងបុរសនិងស្ត្រីដើម្បីឱ្យស្ត្រីមានសិទ្ធិនិងកាតព្វកិច្ចចូលរួមក្នុងការងារសង្គមស្មើនិងបុរសដោយសារស្ត្រីជាឆ្អឹងខ្នងរបស់ប្រទេសជាតិ ជាកោសិកានៃសង្គមនិងជាមាតានៃពិភពលោក។ ដើម្បីបំបាត់រាល់ការរើសអើងលើស្ត្រីភេទនិងរក្សាភាពសុខសាន្តក្នុងសង្គមនិងភាពរីកចម្រើននៃសង្គមជាតិ។ ដូច្នេះការលុបបំបាត់ការរើសអើងរវាងបុរសនិងស្ត្រីគឺធ្វើឱ្យស្ត្រីទទួលបាននូវសិទ្ធិស្មើៗគ្នាដូចជាការឱ្យតម្លៃដោយសង្គមទៅលើភាពដូចគ្នានិងភាពខុសគ្នាដូចជាភេទទាំងពីរត្រូវបានគេផ្តល់ឱកាសឱ្យស្មើគ្នាបានទទួលផលប្រយោជន៍ស្មើគ្នាទោះបីជាមានភាពខុសគ្នាផ្នែកជីវសាស្ត្រយ៉ាងណាក៏ដោយពោលគឺយើងមិនត្រូវឱ្យមានភាពលំអៀងនៃយេនឌ័រនោះទេ។ ស្របពេលនិងវឌ្ឍនភាពទាំងនេះដើម្បីបន្តការលើកកម្ពស់ការចូលរួមរបស់ស្ត្រីនៅគ្រប់វិស័យនៅទូទាំងប្រទេសក្នុងការធ្វើឱ្យស្ត្រីទទួលបានសិទ្ធិនិងឱកាសស្មើគ្នាដូចចែងក្នុងច្បាប់ជាតិនិងអន្តរជាតិហើយរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ដោយចេញនូវគោលនយោបាយនិងយុទ្ធសាស្ត្រដូចជា៖[27]

### ក .ការពង្រឹងសមត្ថភាពតាមរយៈផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៤-២០១៨

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៤-២០១៨ គឺជាផែនការមួយដែលរាជរដ្ឋាភិបាលបានដាក់ចេញយ៉ាងជាក់លាក់និងបានបង្ហាញពីការបញ្ជ្រាបយេនឌ័រដែលជាបញ្ហាអន្តរវិស័យក្នុងគោលនយោបាយកម្មវិធី និងនៅតាមវិស័យនានា។ នៅក្នុងផែនការយុទ្ធសាស្ត្រនេះក៏បានបង្ហាញពីការបន្តកិច្ចខំប្រឹងប្រែងសម្រាប់បង្កើនភាពអង់អាចដល់ស្ត្រីក្នុងវិស័យអប់រំ វិស័យសេដ្ឋកិច្ច និងការធ្វើសេចក្តីសម្រេចរបស់ស្ត្រីនៅក្នុងវិស័យសាធារណៈ និងនយោបាយឱ្យមានភាពស្មើគ្នានិងបុរស។ រដ្ឋាភិបាលបានកំពុងខិតខំយកចិត្តទុកដាក់ក្នុងការបង្កើនចំនួនស្ត្រីក្នុងជួរថ្នាក់ដឹកនាំតាមរយៈផ្តល់អាទិភាពដោយមានការលើកទឹកចិត្ត និងតែងតាំងស្ត្រីជា

[27] ឯកសារ Institute of Humanities and Social Sciences (ចេញផ្សាយថ្ងៃទី ២៦/០៣/២០២០)

ថ្នាក់ដឹកនាំនៅគ្រប់ក្រសួងស្ថាប័នទាំងអស់។ រដ្ឋាភិបាលក៏បានយកចិត្តទុកដាក់ទៅលើការការពារស្ត្រីតាមរយៈចលនាអនុវត្តន៍នូវគោលនយោបាយភូមិឃុំមានសុវត្ថិភាពដែលមានការចូលរួមចំណែលើកកម្ពស់សីលធម៌សង្គមនិងតម្លៃស្ត្រីបានកំពុងស្វែងរកការគាំទ្រផ្នែកបច្ចេកទេសពីក្រសួងនានានិងដៃគូអភិវឌ្ឍន៍ស្ថាប័នពាក់ព័ន្ធបាននិងកំពុងរៀបចំបង្កើតផែនការ យុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យរបស់ខ្លួនជាបន្តបន្ទាប់។[28]

**ខ. ការពង្រឹងសមត្ថភាពតាមរយៈយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល**

នៅក្នុងយុទ្ធសាស្ត្ររាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកថាការធ្វើឱ្យមានភាពប្រសើរឡើវិញនូវប្រព័ន្ធអប់រំនិងការបណ្តុះបណ្តាលសមភាពយេនឌ័រជាគន្លឹះដ៏សំខាន់ណាស់សម្រាប់ការអភិវឌ្ឍសង្គមជាតិដែលមានមូលដ្ឋានទូលំទូលាយនិងមើលឃើញពីការកែប្រែប្រព័ន្ធអប់រំ និងការបណ្តុះបណ្តាលជាប្រធានបទចម្បងសម្រាប់ការកសាងជាតិទាំងមូលព្រមទាំងប្រជាធិបតេយ្យនិងសេរីភាពក្នុងការផ្លាស់ប្តូររួមបញ្ចូលគ្នានិងឯករាជ្យភាពនៃប្រព័ន្ធសេដ្ឋកិច្ច និងវប្បធម៌នៃប្រទេសទូទាំងសកលលោក។ ដោយសង្កេតឃើញថាស្ត្រីបានដើរតួនាទីសំខាន់នៅក្នុងសង្គមបន្ទាប់ពីបុរសដោយសារតែការទទួលរងនូវការរើសអើងភេទពីសម័យមុនធ្វើឱ្យស្ត្រីពុំបានទទួលបានការអប់រំជ្រៅជ្រះដូចជាបុរសឡើយ និងដោយសារតែផែនការនយោបាយមិនទាន់មានលក្ខណៈល្អប្រសើរពេញលេញដែលនាំឱ្យរាជរដ្ឋាភិបាលកម្ពុជានៅតែបន្តខិតខំរកដំណោះស្រាយដោយផ្អែកតាមយុទ្ធសាស្ត្រក្នុងការពង្រឹងសមត្ថភាពស្ត្រីមានរួមមាន៖

**យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២៖** នៅក្នុងដំណាក់កាលទី២ នេះគឺរាជរដ្ឋាភិបាលបានអនុវត្តន៍នូវយុទ្ធសាស្ត្រ "អប់រំសម្រាប់ទាំងអស់គ្នា" តាមរយៈការធានានូវការទទួលបានភាពស្មើគ្នាក្នុងការអប់រំមូលដ្ឋានរយៈពេល ០៩ ឆ្នាំសម្រាប់កុមារគ្រប់រូប។ ដំណាក់កាលទី២ នេះគឺរាជរដ្ឋាភិបាលបានទទួលសមិទ្ធផលដែលសម្រេចបានរួមមានចំនួនសាលារៀន និងគ្រូបង្រៀនព្រមទាំងអាត្រាចុះឈ្មោះចូលរៀននៅគ្រប់កម្រិតសិក្សានៃចំណេះទូទៅបានកើនឡើងជាលំដាប់ជាពិសេសនៅតាមជនបទ សាលាអនុវិទ្យាល័យត្រូវបានបង្កើតឡើងនៅស្ទើរគ្រប់ឃុំសង្កាត់ទូទាំងប្រទេសចំនួនគ្រឹះស្ថានមធ្យមសិក្សាបច្ចេកទេសនិងគ្រឹះស្ថានឧត្តមសិក្សាព្រមទាំងចំនួនបុគ្គលិកបង្រៀនក៏បានកើនឡើងស្របគ្នាដែរ។ ក្នុងនីតិកាលទី៣ កន្លងទៅនេះថវិកាចំណាយចរន្តសម្រាប់វិស័យអប់រំបានកើនឡើងទ្វេដងក្នុងឆ្នាំ ២០០៧ បើធៀបនិងឆ្នាំ ២០០៣ បើគិតជាភាគរយប្រមាណ ១៩,២ ភាគរយ។ រាជរដ្ឋាភិបាលសម្រេចបានជោគជ័យក្នុងការលើកកម្ពស់ភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍នៅក្នុងវិស័យអប់រំគម្រិតទាំងអស់ដែលមានទាំងដៃគូផ្លូវការ វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល។

[28] ផែនការយុទ្ធសាស្ត្រអភិឌ្ឍន៍ជាតិឆ្នាំ ២០១៤-២០១៨

លើសពីនេះ ដើម្បីឱ្យមានភាពល្អប្រសើររាជរដ្ឋាភិបាលបន្តអនុវត្តន៍នូវផែនការយុទ្ធសាស្ត្រវិស័យអប់រំបន្ថែមដែលផ្តោតទៅលើការផ្តល់សិទ្ធិសេរីភាពស្មើៗគ្នាដល់កុមារតូចៗទាំងអស់នៅក្នុងការទទួលបានការអប់រំមូលដ្ឋានក្នុងប្រព័ន្ធនិងការអប់រំក្រៅប្រព័ន្ធដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយនិងដើមកំណើត ឋានៈនៅក្នុងសង្គមឡើយ។ ទាំងអស់នេះអាចសបញ្ជាក់ឱ្យឃើញថា ទាំងស្ត្រីនិងបុរសគឺមានសិទ្ធិស្មើគ្នាក្នុងការទទួលបានការអប់រំ។

រាជរដ្ឋាភិបាលបានចាត់ទុកស្ត្រីគឺជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិទាំងមូលហើយរាជរដ្ឋាភិបាលក៏បានកំពុងកាត់បន្ថយគម្លាតយេនឌ័រក្នុងវិស័យអប់រំ ដែលជាប្រភពបញ្ហាធំរបស់ស្ត្រីសម្រាប់ទទួលបានការអប់រំតាមរយៈការបង្កើនការចុះឈ្មោះចូលរៀនរបស់កុមារី។ ម្យ៉ាងវិញទៀត បើយើងស្វែងយល់ឱ្យបានច្បាស់ពីប្រភពបញ្ហារួមមាន កត្តាតំបន់ កត្តាគ្រួសារ និងកត្តាសាលារៀនក៏ជាបញ្ហាចោទសម្រាប់នារីផងដែរ។ ដើម្បីដោះស្រាយរាល់បញ្ហាទាំងនេះមិនឱ្យកើតមានបន្តទៀតទេទើបរាជរដ្ឋាភិបាលបន្តការអនុវត្តគោលនយោបាយបង្កើតកាលានុវត្តភាពឱ្យសិស្ស និស្សិតស្រីចូលរៀនឱ្យបានកាន់តែច្រើនតាមរយៈការបង្កើនអាហារូបករណ៍សម្រាប់សិស្ស-និស្សិតស្ត្រីដែលមានកម្មវិធីបំប៉ននៅគ្រឹះស្ថានសិក្សាការផ្តល់កន្លែងស្នាក់នៅ ការធានាសុវត្ថិភាពសិស្ស-និស្សិតនារី និងការបង្កើនចំនួនគ្រូបបង្រៀនជាស្ត្រី ។[29]

**គ. ការពង្រឹងសមត្ថភាពតាមរយៈផែនការយុទ្ធសាស្ត្រនារីរតនៈ**

តាំងពីឆ្នាំ ១៩៩៩ ក្រសួងកិច្ចការនារីបានរៀបចំនិងអនុវត្តន៍នូវផែនការយុទ្ធសាស្ត្ររយៈពេល៥ ឆ្នាំដែលហៅថា នារីរតនៈ គិតមកដល់ពេលនេះផែនការយុទ្ធសាស្ត្រនារីរតនៈបានអនុវត្តន៍ដល់ដំណាក់កាលទី៤ ហើយដំណាក់កាលនីមួយៗគឺបានចូលរួមដល់កិច្ចខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់សមភាពយេនឌ័រនិងបង្កើនភាពអង់អាចដល់ស្ត្រីកម្ពុជា។ ក្រសួងកិច្ចការនារីក្នុងភាពជាដៃគូជាមួយក្រសួងស្ថាប័ននៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិបានពិនិត្យទៅលើប្រសិទ្ធភាព និងភាពសក្តិសិទ្ធិនៃការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈ។ [30]

**យុទ្ធសាស្ត្រនារីរតនៈទី៤៖** គឺផ្តោតសំខាន់ទៅលើការពង្រីកនិងពង្រឹងមុខងាររបស់ក្រសួងកិច្ចការនារីពីរបៀបនៃការអនុវត្តការងារដើម្បីឈានទៅរកការអនុវត្តការងារតាមអភិក្រមគ្រប់គ្រងទូទាំងកម្មវិធីនិងឈានជាបន្តបន្ទាប់ពីភ្នាក់ងារអនុវត្តន៍ផ្ទាល់ទៅជាអ្នកលើកកម្ពស់គណនេយ្យភាពសង្គមសម្រាប់ស្ត្រី និងអ្នកផ្តល់

[29] ចតុកោណទី៤ មុំទី១ នៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ នីតិកាលទី៤ នៃរដ្ឋសភា (ទំព័រទី៦០)

[30] ក្រសួងកិច្ចការនារី,នារីរតនៈទី៤៖ផែនការយុទ្ធសាស្ត្រដើម្បីសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី២០១៤-២០១៨ (ទំព័រទី១)

សេវាប្រឹក្សាយោបល់ផ្នែកគោលនយោបាយដល់ស្ថាប័ននានាដែលពាក់ព័ន្ធក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី។ ផែនការយុទ្ធសាស្ត្រនេះបង្ហាញពីសកម្មភាពលម្អិតក្នុងការគាំទ្រនៃការឈានទៅរករបៀបធ្វើការងារមានលក្ខណៈជាអភិក្រមគ្រប់ទូទាំងកម្មវិធីដែលផ្តោតសំខាន់លើការអភិវឌ្ឍសមត្ថភាពក្រសួង និងស្ថាប័នពាក់ព័ន្ធក្នុងការលើកកម្ពស់សមភាពយេនឌ័រ។ នារីរតនៈក៏បង្ហាញអំពីចក្ខុវិស័យបេសកកម្មរួមទាំងយុទ្ធសាស្ត្រដែលរៀបចំឡើងតាមវិស័យនិងកម្មវិធីអាទិភាពនីមួយៗ។ នារីរតនៈទី៤ នេះមានគោលបំណងដើម្បីលើកកម្ពស់សមភាពយេនឌ័រនិងបង្កើនភាពអង់អាចដល់ស្ត្រីក្នុងបរិបទកំណើនសេដ្ឋកិច្ច ការអភិវឌ្ឍសង្គម និងអភិបាលកិច្ចល្អហើយនារីរតនៈទី៤ក៏មានគោលបំណងសំខាន់ៗមួយចំនួនៈ (១) ជំរុញឱ្យមានបរិយាកាសអំណោយផលដើម្បីបង្កើនលទ្ធភាពដល់ស្ត្រីក្នុងការទទួលបាននូវជំនាញការងារ ធនធានផលិតកម្ម និងកិច្ចគាំពារសង្គមនិងការធ្វើសេចក្តីសម្រេចនៅគ្រប់កម្រិតតាមរយៈការបង្កើនចំនួនមន្ត្រីរាជការជាស្ត្រីនិងការពង្រឹងសមត្ថភាព។ (២) ការបង្កើនលទ្ធភាពរបស់ស្ត្រីនិងកុមារីក្នុងការទទួលបាននូវការអប់រំតាមរយៈការលើកកម្ពស់ ការចូលរួមការលើកកម្ពស់ការយល់ដឹងនិងបង្កលក្ខណៈងាយស្រួលដល់ស្ត្រីនិងក្មេងស្រីក្នុងការទទួលបានសេវា។ ម្យ៉ាងទៀត គឺចូលរួមធានាសុវត្ថិភាពដល់ស្ត្រីនិងក្មេងស្រីក្នុងគ្រួសារនិងសង្គមតាមរយៈបង្កើនការយល់ដឹង ការអនុវត្តផែនការសកម្មភាព ច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធនានា។[31]

**ឃ.ការពង្រឹងសមត្ថភាពស្ត្រីតាមរយៈគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព**

ផ្អែកតាមការអនុវត្តបានជោគជ័យរបស់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ឆ្នាំ ២០០០ និងឆ្នាំ ២០១៥។ អង្គការសហប្រជាជាតិក៏បានដាក់ចេញនូវគោលដៅថ្មីមួយទៀតដែលហៅថា ‘‘គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនៃឆ្នាំ ២០៣០ (The Sustainable Development Goals of 2030) ក្នុងនោះមានគោលដៅសំខាន់ៗមានចំនួន ១៧ ដែលអនុម័តដោយកិច្ចប្រជុំកំពូលជាប្រវត្តិសាស្ត្ររបស់អង្គការសហប្រជាជាតិនៅ ខែ កញ្ញា ឆ្នាំ ២០១៥ នៅក្នុងរយៈពេល១៥ឆ្នាំជាមួយនិងគោលដៅថ្មីទាំង១៧ នេះប្រទេសទាំងអស់នៅលើពិភពលោកត្រូវព្យាយាមសម្រេចឱ្យបាននូវការលុបបំបាត់ក្នុងនោះមានទម្រង់វិសមភាពយេនឌ័រផងដែរ។

គោលដៅទី ៣ នៃក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០១៦-២០៣០ បានផ្តោតសំខាន់លើការសម្រេចឱ្យបាននូវសមភាពយេនឌ័រការផ្តល់ភាពអង់អាចដល់ស្ត្រីនិងក្មេងស្រី និងផ្តល់សិទ្ធិស្មើគ្នាដល់ស្ត្រីទៅលើធនធានសេដ្ឋកិច្ច និងជំរុញឱ្យប្រទេសអនុម័តពង្រឹងការអនុវត្តគោលនយោបាយច្បាប់សម្រាប់ការលើកកម្ពស់សមភាពយេនឌ័រនិងការផ្តល់ភាពអង់អាចដល់ស្ត្រីនិងក្មេងស្រីធ្វើការផ្សព្វផ្សាយអំពីគោលនយោបាយនិងច្បាប់ទាំងនេះឱ្យទូលំទូលាយ។ ការផ្តល់សិទ្ធិអំណាចដល់ស្ត្រីមិនត្រឹមតែមានឥទ្ធិពល

[31] យុទ្ធសាស្ត្រនារីរតនៈទី៤.(ទំព័រទី១៣)

ខ្លាំងទៅលើការរីកចម្រើនដោយស្ថេរភាពនិងការអភិវឌ្ឍគ្រប់ជ្រុងជ្រោយនោះទេ។ ប៉ុន្តែគួរឱ្យកត់សម្គាល់ឃើញថាសេចក្តីលម្អិតនៅក្នុងគោលដៅទី៥ នេះគឺត្រូវបានបញ្ចូលទៅក្នុងគោលនយោបាយសាធារណៈនិងច្បាប់របស់កម្ពុជាផងដែរ។

❖ **មូលដ្ឋានគ្រឹះក្នុងការពង្រឹងសមត្ថភាពស្ត្រី**

ទោះបីជាការអប់រំកាន់តែមានការរីកចម្រើនយ៉ាងណាក៏ដោយតែការអប់រំសម្រាប់ស្ត្រីនិងក្មេងស្រីនៅមិនទាន់មានកម្រិតដែលល្អប្រសើរនោះទេគឺដោយសារមិនទទួលបានភាពស្មើគ្នារវាងបុរសនិងស្ត្រីនៅឡើយទេ។ កាលណាមិនទទួលបានភាពស្មើគ្នាគឺធ្វើឱ្យមានវិសមភាពយេនឌ័រក្នុងសង្គមកាលណាមានវិសមភាពយេនឌ័រនៅក្នុងសង្គមធ្វើឱ្យសង្គមអភិវឌ្ឍន៍មិនបានជឿនលឿនទៅមុខដោយរលូននោះទេ។ ដូចនេះទើបមានការទាមទារឱ្យមានភាពស្មើគ្នារវាងបុរសនិងស្ត្រី ប៉ុន្តែការទាមទារភាពស្មើគ្នាអាចជោគជ័យបានត្រូវតែមានការផ្លាស់ប្តូរចាប់ផ្តើមពីឪពុកម្តាយដោយឱ្យគាត់ឈប់ប្រកាន់ខ្ជាប់នូវគំនិតពីសម័យបុរាណដោយបញ្ជូនកូនស្រីឱ្យទៅចូលរៀនបានគ្រប់ៗគ្នា។

រាជរដ្ឋាភិបាលនៅតែបន្តការអនុវត្តនូវវិធានការចម្បងៗសំខាន់សម្រាប់ការលើកកម្ពស់យេនឌ័រនៅក្នុងវិស័យអប់រំតាមរយៈការដាក់ចេញយុទ្ធសាស្ត្រនិងអន្តរាគមន៍ដោយផ្ទាល់ និងដោយប្រយោលក្នុងគោលបំណងលើកកម្ពស់កុមារីនិងស្ត្រី។ ការអន្តរាគមន៍របស់រាជរដ្ឋាភិបាលមានដូចជា៖ (១) ការសាងសង់សាលារៀននៅកាន់តែជិតផ្ទះប្រជាជនដើម្បីបង្កជាលក្ខណៈងាយស្រួលឱ្យសិស្សមកពីគ្រួសារក្រីក្របានចូលរៀនជាពិសេសគឺកុមារីដើម្បីកាត់បន្ថយចំណាយនិងសុវត្ថិភាពនៃការធ្វើដំណើរ។ (២) ការសាងសង់អន្តេវាសិកដ្ឋានសម្រាប់សិស្សនិស្សិត ឬ គរុសិស្សជានារីសម្រាប់ស្នាក់នៅ។ (៣) ការអនុវត្តកម្មវិធីសាលាកុមារមេត្រី និងការបង្កើតកម្មវិធីទីប្រឹក្សាកុមារីនៅតាមសាលារៀន ការលើកកម្ពស់ការយល់ដឹងពីសារៈសំខាន់នៃការអប់រំស្ត្រីដែលការវិនិយោគតាំងពីម្តាយរហូតដល់កូន និងយកចិត្តទុកដាក់លើផ្នត់គំនិតរបស់សង្គមចំពោះកូនស្រី។ (៤) ការផ្តល់អាហារូបករណ៍សម្រាប់សិស្សអាទិភាពទូទៅសិស្សពូកែ អាទិភាពនារី អាទិភាពក្រីក្រ អាទិភាពតំបន់ដាច់ស្រយាល និងសិស្សមានពិការភាព និងសិស្សនារីឱ្យបានយ៉ាងតិច ៦០ ភាគរយនៃចំនួនសិស្សដែលទទួលបានអាហារូបករណ៍បានចូលរៀននៅថ្នាក់ឧត្តមសិក្សា។ (៥)ការបំប៉នស្តីពីភាពចាប់អារម្មណ៍លើយេនឌ័រក្នុងការងារអប់រំជូនគ្រូឧទ្ទេស នាយក នាយករង នៅតាមសាលាគរុកោសល្យ (វិទ្យាស្ថានគរុកោសល្យ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈឹម និង

សាលាគរុកោសល្យ និងវិក្រឹតការ។ (៦) ការផ្តល់អាទិភាពដល់កុមារីនិងស្ត្រីក្នុងការប្រកួតប្រជែង និងការជ្រើសរើសនានាជាដើម។[32]

## ២.២. ការគាំពារស្ត្រីនៅក្នុងសកម្មភាពសង្គម

វត្តមានរបស់ស្ត្រី និងក្មេងស្រីនៅក្នុងការងារសង្គមកាន់តែមានចំនួនកើនច្រើនឡើងកាន់តែច្រើនគឺដោយសារស្ត្រីមានតួនាទីដ៏សំខាន់ក្នុងការចូលរួមចំណែកកសាងនិងអភិវឌ្ឍន៍សង្គម។ ការអភិវឌ្ឍសមត្ថភាពស្ត្រីជាថ្នាក់ដឹកនាំនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិការអភិវឌ្ឍសមត្ថភាពដល់ស្ត្រីដែលជាថ្នាក់ដឹកនាំនិងមន្ត្រីរាជការជានារីនៅថ្នាក់ជាតិត្រូវបានយកចិត្តទុកដាក់ខ្ពស់ពីក្រសួងកិច្ចការនារី និងគ្រប់ភាគីពាក់ព័ន្ធដោយមានគោលនយោបាយយេនឌ័រ និងផែនការជាតិយ៉ាងជាក់លាក់។ ក្រសួងកិច្ចការនារីបានធ្វើការប៉ាន់ស្មានយេនឌ័រនៅកម្ពុជាជារៀងរាល់ ៥ ឆ្នាំម្តង(ឆ្នាំ ២០០៤ ២០០៨ និងឆ្នាំ ២០១៤) ដែលផ្តល់នូវទិដ្ឋភាពដ៏ទូលំទូលាយអំពីយេនឌ័រលើគ្រប់វិស័យ។ ចំពោះឯកសារនេះបានរៀបចំឡើងក្នុងភាពជាដៃគូនិងកិច្ចសហប្រតិបត្តិការរវាងក្រសួងកិច្ចការនារី ក្រសួងស្ថាប័នដែលពាក់ព័ន្ធ សង្គមស៊ីវិលនិងដៃគូអភិវឌ្ឍន៍ដោយមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយភាគីដែលពាក់ព័ន្ធនិងបង្កើនភាពអង់អាចដល់ស្ត្រីតាមវិស័យរបស់ក្រសួងស្ថាប័ននិងជាមគ្គុទេសក៍ក្នុងការតាក់តែងគោលយោបាយ ផែនការនិងកម្មវិធីនានាដើម្បីសមភាពយេនឌ័រនិងកិច្ចអភិវឌ្ឍន៍។

**ផែនការយុទ្ធសាស្ត្រនារីរតនៈនិងគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ ៖** ក្រសួងកិច្ចការនារីគឺបានអនុវត្តន៍ផែនការយុទ្ធសាស្ត្រ៥ ឆ្នាំមានចំនួនបីដំណាក់កាលរួចមកហើយចាប់ពីឆ្នាំ ១៩៩៩-២០១៣ (នារីរតនៈទី១ ទី២ ទី៣) ដើម្បីរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់សមភាពយេនឌ័រនិងបង្កើនភាពអង់អាចដល់ស្ត្រីកម្ពុជា។ រាល់ផែនការយុទ្ធសាស្ត្រនារីរតនៈបានកំណត់ថាតួនាទីនិងភារកិច្ចរបស់ក្រសួងកិច្ចការគឺក្នុងការលើកកម្ពស់យេនឌ័រ និងការបញ្ជ្រាបយេនឌ័រនៅក្នុងស្ថាប័នរាជរដ្ឋាភិបាលដែលចាប់ផ្តើមពីនារីរតនៈទី១ (ឆ្នាំ១៩៩៩) ក្រសួងកិច្ចការនារីបានដើរតួនាទីជាកាតាលីករដើម្បីលើកទឹកចិត្តដល់ក្រសួងស្ថាប័នដែលពាក់ព័ន្ធទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងការដាក់បញ្ចូលរាល់បញ្ហាទាក់ទងនិងសមភាពយេនឌ័រទៅក្នុងគោលនយោបាយនិងកម្មវិធីរបស់ខ្លួន។ លើសពីនេះ ក្រសួងកិច្ចការនារីបានកំពុងរៀបចំបញ្ចប់ផែនការយុទ្ធសាស្ត្រនារីរតនៈនិងផ្លាស់ប្តូរពីការអនុវត្តផ្តោតលើគម្រោងតូចៗទៅជាការអនុវត្តតាមបែបអភិក្រមគ្រប់គ្រងទូទាំងកម្មវិធីនិងពីការអនុវត្តផ្តោតសំខាន់លើការផ្តល់សេវាការលើកកម្ពស់គណនេយ្យភាពសង្គមសម្រាប់ស្ត្រី និងការផ្តល់សេវាប្រឹក្សាផ្នែកគោលនយោបាយដែលជាយុទ្ធសាស្ត្រក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងក្រសួងស្ថាប័ន។ ផែនការយុទ្ធសាស្ត្រនារីរតនៈបានរៀបចំឡើងដើម្បីឆ្លុះបញ្ចាំងពីមុខងាររបស់ក្រសួងកិច្ចការ

[32] ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំឆ្នាំ ២០២១-២០២៥ (ទំព័រទី៩,១០)

នារីដែលផ្តោតទៅលើការអភិវឌ្ឍសមត្ថភាពសម្រាប់ការបញ្ជ្រាបយេនឌ័រទៅក្នុងក្រសួងស្ថាប័នពាក់ព័ន្ធដែលដឹកនាំ និងសម្របសម្រួលដោយក្រសួងកិច្ចការនារីតាមរយៈការផ្តល់សេវាប្រឹក្សា គាំទ្របច្ចេកទេស ការស្វែងរកការគាំទ្រមតិនិងការត្រួតពិនិត្យ។ ផែនការយុទ្ធសាស្ត្រនេះតម្រូវឱ្យក្រសួងកិច្ចការនារីបង្កើនការយកចិត្តទុកដាក់ទៅលើការបញ្ជ្រាបយេនឌ័រនៅក្នុងក្រសួងស្ថាប័នពាក់ព័ន្ធនិងផ្តោតលើការវិភាគ ការរៀបចំគោលនយោបាយច្រើនជាជាងការអនុវត្តគម្រោងនិងការផ្តល់សេវានៅថ្នាក់មូលដ្ឋានតាមរយៈការត្រួតពិនិត្យ ការរៀបចំផែនការនិងថវិកាការអនុវត្តគម្រោង របាយការណ៍ដាក់ចេញនូវគោលដៅនិងគោលបំណងជារួមសម្រាប់ការបញ្ជ្រាបយេនឌ័រទៅក្នុងគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងកម្រិតគោលនយោបាយ។[33]

## ២.៣. ការចូលរួមសកម្មភាពរបស់ស្ត្រីនៅក្នុងស្ថាប័នរដ្ឋ

### ការចូលរួមសកម្មភាពរបស់ស្ត្រីនៅក្នុងស្ថាប័នថ្នាក់ជាតិ

ការចូលរួមរបស់ស្ត្រីនៅក្នុងស្ថាប័នថ្នាក់ជាតិគឺរាជរដ្ឋាភិបាលកម្ពុជាបានបង្កើតរដ្ឋលេខាធិការដ្ឋានកិច្ចការនារីនៅឆ្នាំ ១៩៩៣ ដោយបានតម្លើងជាក្រសួងកិច្ចការនារីនិងអតីតយុទ្ធជននៅឆ្នាំ ១៩៩៨ ហើយបានក្លាយមកជាក្រសួងកិច្ចការនារីនៅឆ្នាំ២០០៣។ ក្រសួងកិច្ចការនារីមានតួនាទី និងភារៈកិច្ចជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់ស្ថានភាពស្ត្រីនិងការពារសិទ្ធិរបស់ស្ត្រី និងគ្រួសារតាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈ។ ក្រសួងដើរតួក្នុងការលើកកម្ពស់សមភាពយេនឌ័រនៅក្នុងច្បាប់ គោលនយោបាយការរៀបចំផែនការយុទ្ធសាស្ត្រនិងកម្មវិធីជាតិនានា។ ក្រសួងកិច្ចការនារីមានអគ្គនាយកដ្ឋានចំនួន៣ និងមាននាយកដ្ឋានចំនួន១១ ព្រមទាំងមានមន្ទីរកិច្ចការនារីរាជធានី ខេត្ត និងមានការិយាល័យកិច្ចការនារី ក្រុង ស្រុក ខណ្ឌ ទូទាំងប្រទេសនិងមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីក្នុងខេត្តចំនួន ១៣។ ក្រៅពីកម្មវិធីបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីកម្មវិធីអប់រំស្ត្រីនិងក្មេងស្រីកម្មវិធីលើកកម្ពស់សុខភាពស្ត្រីនិងក្មេងស្រី និងកិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រីនិងក្មេងស្រីព្រមទាំងការលើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងវិស័យសាធារណៈ និងនយោបាយ។ ក្រសួងកិច្ចការនារីកំពុងជំរុញការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយផែនការនិងកម្មវិធីកំណែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាលមានដូចជា៖ កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ កម្មវិធីការបញ្ជ្រាបយេនឌ័រតាមវិស័យនានារួមទាំងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនិងកម្មវិធីវិនិយោគសាធារណៈនិងគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា។

---

[33] សេចក្តីសង្ខេបសម្រាប់គោលនយោបាយ១៖ យេនដ័រការបញ្ជ្រាវយេនឌ័រ បរិបទគោលនយោបាយ ស្ថាប័ន និងភាពជាដៃគូ ការប៉ាន់ប្រមាណអំពីយេនឌ័រនៅកម្ពុជា ២០១៤ (ទំព័រ ៧,៨)

- **ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី(ក.ជ.ក.ស)**៖ បង្កើតឡើងនៅក្នុងឆ្នាំ ២០០១ គឺជាយន្តការជាតិអន្តរក្រសួងស្ថាប័នដែលមានសមាជិកថ្នាក់រដ្ឋលេខាធិការមកពីក្រសួងស្ថាប័នពាក់ព័ន្ធ។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីមានភារកិច្ចជួយរាជរដ្ឋាភិបាលក្នុងការសម្របសម្រួលតាមដាន និងវាយតម្លៃអំពីការអនុវត្តគោលនយោបាយជាតិ ច្បាប់ និងបទប្បញ្ញត្តិនានាដែលទាក់ទងនិងការលើកកម្ពស់ឋានៈតួនាទីស្ត្រីនិងសុខុមាលភាពរបស់ស្ត្រី។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីមានតួនាទីតាមដាននិងវាយតម្លៃនូវការអនុវត្តអនុសញ្ញាអន្តរជាតិដែលពាក់ព័ន្ធ និងសិទ្ធិនារីដើម្បីផ្តល់អនុសាសន៍រួមជូនដល់រាជរដ្ឋាភិបាលក្នុងគោលដៅលើកកម្ពស់ស្ថានភាពរបស់ស្ត្រីឱ្យកាន់តែប្រសើរឡើងនិងរៀបចំរបាយការណ៍ជាតិលើការអនុវត្តអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីគឺដឹកនាំដោយសម្តេចព្រះមហាក្សត្រីព្រះវររាជមាតាជាតិខ្មែរ ដែលជាព្រះប្រធានកិត្តិយសសម្តេចនាយករដ្ឋមន្ត្រីជាអនុប្រធានកិត្តិយសរដ្ឋមន្ត្រីក្រសួងកិច្ចការនារីជាប្រធានប្រតិបត្តិតំណាងក្រសួងស្ថាប័នពាក់ព័ន្ធជាសមាជិកនិងសមាជិកា។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីមានផែនការយុទ្ធសាស្ត្រ ៥ ឆ្នាំ (២០១០-២០១៤) របស់ខ្លួនមិនចំណុះផែនការយុទ្ធសាស្ត្រនារីរតនៈ។
- **គណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គមតម្លៃស្ត្រីនិងគ្រួសារខ្មែរ** ៖ គឺដឹកនាំដោយរដ្ឋមន្ត្រីនៃក្រសួងកិច្ចការនារី និងមានសមាជិកមកពីក្រសួងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល។ គណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រីនិងគ្រួសារខ្មែរដែលបានបង្កើតឡើងក្នុងគោលបំណងថែរក្សាការពារវប្បធម៌ជាតិដែលធានាដល់ការគោរពសីលធម៌សង្គម និងសុភមង្គលក្នុងគ្រួសារដោយលើកកម្ពស់ស្ថានភាពតួនាទីនិងសុខុមាលភាពស្ត្រីខ្មែរ។
- **គណៈកម្មាធិការដឹកនាំនិងសម្របសម្រួលអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី** ៖ គឺបានបង្កើតឡើងនៅក្នុងខែ តុលា ឆ្នាំ ២០១២ ក្នុងគោលបំណងសម្របសម្រួលនិងដឹកនាំការបង្កើតនិងអនុវត្តន៍អភិក្រមគ្រប់គ្រងទូទាំងកម្មវិធីដើម្បីឆ្ពោះទៅរកសមភាពយេនឌ័រដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងមានសមាជិកចំនួន១២រូប ជារដ្ឋលេខាធិការ ជាអគ្គនាយកនិងមានលេខាធិការដ្ឋានមួយដើម្បីគាំទ្រដល់ការងាររបស់ខ្លួន។ តួនាទីចម្បងគឺការទទួលខុសត្រូវរបស់គណៈកម្មាធិការនេះគឺរៀបចំអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី (PBA) សម្របសម្រួលកិច្ចសហការ ការកៀរគរធនធាននិងការអភិវឌ្ឍសមត្ថភាព។
- **គណៈកម្មាធិការយេនឌ័រនិងការប្រែប្រួលអាកាសធាតុ** ៖ គឺបង្កើតឡើងនៅខែ កញ្ញា ឆ្នាំ ២០១១ ដឹកនាំដោយរដ្ឋលេខាធិការមួយរូបនិងមានសមាជិកមកពីអគ្គនាយកដ្ឋាននិងនាយកដ្ឋានពាក់ព័ន្ធមួយចំនួន។ គណៈកម្មាធិការនេះបានបង្កើតឡើងក្នុងគោលបំណង៖

១. សម្របសម្រួលចែករំលែកព័ត៌មានបញ្ញាបយេនឌ័រ និងការប្រែប្រួលអាកាសធាតុជាមួយស្ថាប័នពាក់ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ មន្ទីរកិច្ចការនារីរាជធានី ខេត្ត និងការិយាល័យកិច្ចការនារី ក្រុង ស្រុក ខណ្ឌ។

២. សិក្សាស្រាវជ្រាវអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុគ្រោះមហន្តរាយផ្សេងៗចំពោះមនុស្សជាពិសេសផលប៉ះពាល់មកលើស្ត្រី កុមារនិងក្រុមជនងាយរងគ្រោះ។

៣. អភិវឌ្ឍន៍សមត្ថភាពក្រុមការងាររួមមាន៖ មន្ត្រីរបស់ក្រសួងកិច្ចការនារី និងក្រសួងស្ថាប័នពាក់ព័ន្ធទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដើម្បីយល់ដឹងអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុក្នុងការកាត់បន្ថយការបន្សាំនិងការប្រែប្រួលអាកាសធាតុ។

**ការចូលរួមសកម្មភាពរបស់ស្ត្រីនៅក្នុងថ្នាក់ក្រោមជាតិ**

មន្ទីរកិច្ចការនារីរាជធានី/ខេត្តនិងការិយាល័យកិច្ចការនារីក្រុង ស្រុក ខណ្ឌជារចនាសម្ព័ន្ធថ្នាក់ក្រោមជាតិនិងអង្គភាពចំណុះរបស់ក្រសួងកិច្ចការនារី។ អង្គភាពទាំងអស់ដែលធ្វើការជាមួយមន្ទីរការិយាល័យនិងអង្គភាពពាក់ព័ន្ធផ្សេងទៀតដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួននិងមានតួនាទីគាំទ្រសម្របសម្រួលនិងធ្វើការសិក្សាស្រាវជ្រាវដើម្បីផ្តល់ព័ត៌មានព្រមទាំងគាំទ្រដល់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដែលពាក់ព័ន្ធទៅលើបញ្ហាពាក់ព័ន្ធស្ត្រីកុមារ និងយុវវ័យនៅថ្នាក់មូលដ្ឋានរបស់ខ្លួន។

- **គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ** (គ.ក.ស.ក) គឺជាយន្តការថ្នាក់ក្រោមជាតិដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រីនិងកុមារ ដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។ គ.ក.ស.ក. មានមុខងារ និងភារកិច្ចនៅក្នុងការផ្តល់យោបល់និងផ្តល់អនុសាសន៍ជូនក្រុមប្រឹក្សាគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការផ្សេងទៀតទៅលើបញ្ហាដែលទាក់ទងនិងសមភាពយេនឌ័រនិងបញ្ហារបស់ស្ត្រី យុវវ័យនិងកុមារ។ នាពេលបច្ចុប្បន្ននេះនៅក្នុងក្របខ័ណ្ឌគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ក្រសួងកិច្ចការនារីមានតួនាទីភារកិច្ចជួយគាំទ្រដល់មន្ទីរកិច្ចការនារីរាជធានី ខេត្ត និងការិយាល័យកិច្ចការនារីថ្នាក់ក្រុង ស្រុក ខណ្ឌដែលបំពេញភារកិច្ចជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការនេះ។ ចំណែកក្រសួងមហាផ្ទៃគាំទ្រលើការអភិវឌ្ឍសមត្ថភាពនិងការបំពេញភារកិច្ចរបស់គណៈកម្មាធិការនេះជារួម។ គ.ក.ស.ក.នីមួយៗដឹកនាំដោយប្រធាន១ រូបដែលជាសមាជិកាក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមានអនុប្រធានដែលជាអភិបាលរងនៃគណៈអភិបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ និងអនុប្រធានចំនួន ៣ រូប ទៀតមកពីសមាជិកក្រុម

ប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលតំណាងមន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា និង តំណាងមន្ទីរកិច្ចការនារី ។

- **គណៈកម្មាធិការការទទួលបន្ទុកកិច្ចការនារីនិងកុមារ ឃុំ សង្កាត់** (គ.ក.ន.ក) ៖ ជាគណៈកម្មាធិការដែលទទួលបន្ទុកលើបញ្ហាស្ត្រីនិងកុមារដែលទទួលខុសត្រូវចំពោះបញ្ហាទាក់ទងនិងកិច្ចអភិវឌ្ឍន៍សង្គម រួមមានដូចជា៖ សុខភាពរបស់មាតា សិស្សមតេយ្យសិក្សា សហគមន៍ អនាម័យ ទឹកស្អាត សមភាពយេនឌ័រនិងកិច្ចការពារកុមារ។ សមាសភាពនៃ គ.ក.ន.ក មាន៖ មេឃុំ ឬ ចៅសង្កាត់ជាប្រធាន ជំទប់ទី២ ឬ ចៅសង្កាត់រងទី ២ ដែលជាអនុប្រធាននិងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់ជាសមាជិកអចិន្ត្រៃយ៍រួមទាំងតំណាងនគរបាលប៉ុស្តិ៍រដ្ឋបាល ឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ តំណាងសាលារៀន តំណាងមណ្ឌលសុខភាពនិងថ្នាក់ដឹកនាំភូមិជាសមាជិក។ អ្នកដែលទទួលបន្ទុកកិច្ចការនារីនិងកុមារ ឃុំ សង្កាត់ (អ.ក.ន.ក) ដែលជាប្រតិបត្តិករនិងជាតំណាងកិច្ចការស្ត្រីនិងកុមារនៅថ្នាក់ ឃុំ សង្កាត់។ ក្រុមប្រឹក្សាឃុំ សង្កាត់តែងតាំងសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ម្នាក់ដែលជានារីឱ្យទទួលបន្ទុកកិច្ចការនារី និងកុមារ។ ក្នុងករណីគ្មាននារីជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវជ្រើសតាំងនារីមួយរូបធ្វើជាជំនួយការទទួលបន្ទុកកិច្ចការនារីនិងកុមារ។[34]
- **ការបញ្ជ្រាបយេនឌ័រនៅក្នុងកម្មវិធីកំណែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល** ៖ ក្រសួងកិច្ចការនារីបានខិតខំធ្វើការងារបញ្ជ្រាបយេនឌ័រយ៉ាងសកម្មទៅក្នុងកម្មវិធីកំណែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាលមាន កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌។
- **គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**(គ.ជ.អ.ប) ក្នុងឆ្នាំ ២០០៩ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) បានបង្កើតឡើងគឺដើម្បីធ្វើការត្រួតពិនិត្យការអនុវត្តកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនៅឆ្នាំ ២០១០ គ.ជ.អ.ប បានបង្កើតកម្មវិធីជាតិ១០ឆ្នាំ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឆ្នាំ ២០១០-២០១៩។ កម្មវិធីជាតិនេះផ្តល់ទិសដៅសម្រាប់ការអនុវត្តរបៀបវារៈកំណែទម្រង់សម្រាប់១០ឆ្នាំបន្ទាប់។ កម្មវិធីជាតិ១០ឆ្នាំបានរៀបចំជាផែនការអនុវត្តបីឆ្នាំដំបូងហៅកាត់ថា"ផអ៣"។ ផ.អ.៣.មានអនុកម្មវិធីប្រាំមួយដែលមានក្រសួង ស្ថាប័ន

[34] សេចក្តីសង្ខេបសម្រាប់គោលនយោបាយ១៖ យេនដ័រការបញ្ជ្រាវយេនឌ័រ បរិបទគោលនយោបាយ ស្ថាប័ន និងភាពជាដៃគូ ការប៉ាន់ប្រមាណអំពីយេនឌ័រនៅកម្ពុជា២០១៤(ទំព័រ ៨ ៩ ១០ ១១ ១២ ១៣ ១៤ )

ចំនួនប្រាំពីរបានអនុវត្តន៍អនុកម្មវិធីទាំងនោះមានក្រសួងកិច្ចការនារីដើរតួនាទីជាអ្នកសម្របសម្រួល និង គាំទ្រការបញ្រ្ជាបយេនឌ័រនៅក្នុង ផ.អ.៣។ យេនឌ័របានបញ្ជ្រាបទាំងនៅក្នុងកម្មវិធីជាតិ ១០ ឆ្នាំ និង ផ.អ.៣។ កម្មវិធីជាតិ ១០ ឆ្នាំ និង ផ.អ.៣ បានផ្តោតលើការយកចិត្តទុកដាក់ក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រីនៅក្នុងអភិបាលកិច្ចល្អមូលដ្ឋានតាមរយៈការចូលរួមនិងការទទួលបានសិទ្ធិស្មើគ្នាសម្រាប់ស្ត្រីនិងបុរសដើម្បីទទួលបានមុខតំណែងជាអ្នកដឹកនាំនិងការធ្វើសេចក្តីសម្រេចផ្នែកនយោបាយ ធនធាននិងសេវាកម្ម។ នៅក្នុង ខែកុម្ភៈ ឆ្នាំ២០១៤ (គ.ជ.អ.ប) បានធ្វើសវនកម្មយេនឌ័រ ដែលបានត្រួតពិនិត្យឡើងវិញទៅលើស្ថាប័នគោលនយោបាយសំខាន់ៗនិងសមិទ្ធផលព្រមទាំងឧបសគ្គនានាក្នុងការបញ្ជ្រាបយេនឌ័រ។ សវនកម្មនេះបានផ្តល់ព័ត៌មានជាមូលដ្ឋានមួយសម្រាប់ការបញ្ជ្រាបយេនឌ័រនៅក្នុង.ផ.អ.៣.ជាបន្តបន្ទាប់ទៀត។ គ.ជ.អ.ប.គឺបានកំពុងសាកល្បងអនុវត្តន៍ក្របខ័ណ្ឌគណនេយ្យភាពសង្គមដើម្បីពង្រឹងអភិបាលកិច្ចល្អក្នុងវិស័យមួយចំនួនមានវិស័យអប់រំ វិស័យសុខាភិបាល និងការគ្រប់គ្រងដឹកនាំរបស់ក្រុមប្រឹក្សា ឃុំ សង្កាត់ការអនុវត្តនេះនិងផ្តល់ឱកាសជាយុទ្ធសាស្ត្រសម្រាប់មន្ទីរនិងការិយាល័យកិច្ចការនារីនៅថ្នាក់ក្រោមជាតិដើម្បីបង្កើនការផ្តល់សេវាការចូលរួមរបស់ស្ត្រីក្នុងការឆ្លើយតបនិងសមភាពយេនឌ័រ។[35]

[35] សេចក្តីសង្ខេបសម្រាប់គោលនយោបាយ១៖ យេនឌ័រការបញ្ជ្រាវយេនឌ័រ បរិបទគោលនយោបាយ ស្ថាប័ន និងភាពជាដៃគូ ការប៉ាន់ប្រមាណអំពីយេនឌ័រនៅកម្ពុជា ២០១៤(ទំព័រ ១៩,២០,២១ )

# ជំពូកទី៣
# ពិភាក្សាលើលទ្ធផលនៃការពង្រឹងសមត្ថភាពស្ត្រី

ជំពូកទី៣ នេះគឺយើងពិភាក្សាលើលទ្ធផលនៃការពង្រឹងសមត្ថភាពរបស់ស្ត្រីដែលទទួលបានពីការគាំពារពីច្បាប់ជាតិ ច្បាប់អន្តរជាតិ គោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលដែលបានផ្តល់សិទ្ធិសេរីភាពស្មើគ្នាក្នុងការចូលរួមរបស់ស្ត្រីនៅក្នុងសង្គមគ្រប់វិស័យ និងគ្រប់ជាន់ថ្នាក់ ។

## ៣.១.ពិភាក្សាលើសមិទ្ធផលនៃការពង្រឹងសមត្ថភាពស្ត្រីដែលឆ្លុះបញ្ចាំងតាមរយៈវិស័យអប់រំ

ទោះបីជាមានការអភិវឌ្ឍលើវិស័យអប់រំ និងសង្គមបានដើរទៅមុខយ៉ាងលឿនក៏ដោយតែក្មេងស្រីនៅកម្ពុជាក៏នូវតែមានបញ្ហាវិសមភាពលើវិស័យអប់រំដែលគឺដោយសារក្មេងស្រីមានឱកាសអប់រំតិចជាងក្មេងប្រុសបញ្ហាទាំងនេះគឺបានជំរុញឱ្យមានការតស៊ូមតិក្នុងចំណោមភាគីពាក់ព័ន្ធនានាដើម្បីធ្វើយ៉ាងណាឱ្យមានការលើកកម្ពស់ស្ត្រីកម្ពុជាឱ្យមានលទ្ធភាពគ្រប់គ្រាន់ដើម្បីសិក្សាឱ្យស្មើនិងបុរស។ បច្ចុប្បន្ននេះ ក្រសួងអប់រំយុវជននិងកីឡាបាន និងកំពុងគាំទ្រឱ្យមានការលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យអប់រំ និងវិស័យដែលពាក់ព័ន្ធនានាផងដែរ។ បើទោះបីជាមានកត្តាមករារាំងនូវការរីកចម្រើនសមត្ថភាពរបស់ស្ត្រីក៏ដោយចំពោះការខិតខំប្រឹងប្រែងនេះដោយបានសង្កេតឃើញថាបច្ចុប្បន្ននៅក្នុងគ្រួសារដែលមានជីវភាពរស់នៅខ្ពស់ មធ្យមបានបញ្ជូនក្មេងស្រីឱ្យទៅសាលារៀនបានគ្រប់ៗគ្នា និងមួយចំនួនបានទទួលការសិក្សាខ្ពស់ដល់អនុបណ្ឌិតបណ្ឌិតនៅតាមសកលវិទ្យាល័យល្បីៗនានាក្នុងប្រទេសនិងក្រៅប្រទេស។ ចំពោះការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលបានសម្រេចលទ្ធផលរួមមាន៖

(១) កុមារតូចដែលទទួលបានសេវាអប់រំមានចំនួន ៣៦៣,៦៨១ នាក់ ស្រីចំនួន ៥០,០៨ ភាគរយនៅឆ្នាំសិក្សា ២០១៩-២០២០។ ចំណែកឯកុមារអាយុ ៥ ឆ្នាំដែលទទួលសេវាអប់រំគ្រប់រូបភាពមានចំនួន ១៩៣,៨២៣ នាក់ ស្មើនិង ៦២,៩ ភាគរយ នៃចំនួនប្រជាជនអាយុ៥ ឆ្នាំ មានក្មេងស្រី ៦៣,៦ ភាគរយ ។[36]

(២) ថ្នាក់មធ្យមសិក្សាបឋមភូមិដែលមានសិស្សសរុបចំនួន ៦៥៥,០៥៥ នាក់ សិស្សស្រីមានចំនួនសរុប ៥២,៥ ភាគរយ (សិស្សស្រីនៅមធ្យមសិក្សាបឋមភូមិសាលារដ្ឋ ៥២,៦ ភាគរយ និងសាលាឯកជនមានចំនួន ៥១,៤ ភាគរយ)។ ចំពោះអត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិគឺសិស្សស្រីមានចំនួន ៥២,៥ ភាគរយ គឺមានន័យថាអត្រាបញ្ចប់ការសិក្សារបស់សិស្សស្រីប្រមាណចំនួន ២៤ ភាគរយដែលមានខ្ពស់ជាងអត្រារបស់សិស្សប្រុស។[37]

---

[36] ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំឆ្នាំ ២០២១-២០២៥(ទំព័រទី២)

[37] ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំឆ្នាំ ២០២១-២០២៥(ទំព័រទី៣)

(៣) ថ្នាក់មធ្យមសិក្សាទុតិយភូមិមានសិស្សសរុបចំនួន ៣៥៨,៥៥៣ នាក់ សិស្សស្រី ៥៤,៥ ភាគរយ នៅក្នុងនោះសិស្សស្រីនៅមធ្យមសិក្សាទុតិយភូមិសាលារដ្ឋមានចំនួន ៥៤,៨ ភាគរយ និងសាលាឯកជនមានសិស្សស្រីចំនួន ៥១,២ ភាគរយ។ នៅឆ្នាំ ២០១៩ បេក្ខជនប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិបានកើនដល់ ៧៩,០៥២ នាក់ ស្មើ ៦៨,៦២ ភាគរយ) សិស្សស្រី ៤៣,៧២៨ នាក់ស្មើនិង ៧៣,២១ ភាគរយ គឺមានចំនួនខ្ពស់ជាងបន្តិចនៅមធ្យមភាគថ្នាក់ជាតិ)។ បេក្ខជនប្រឡងជាប់និទ្ទេស A សរុប ៤៤៣ នាក់ មានសិស្សស្រី ២២៣ នាក់ ដែលស្មើនិង(៥០,៣ ភាគរយ) បេក្ខជនទទួលបាននិទ្ទេស B មាន ២,៤៣០ នាក់ មានសិស្សស្រីចំនួន ១,៣០៦ នាក់ ស្មើ ៥៣,៧ ភាគរយ និងបេក្ខជនទទួលបាននិទ្ទេស C មាន ៥,៨៤៧ នាក់ មានសិស្សស្រី ៣,៤១៤ នាក់ ស្មើចំនួន ៥៨,៤ ភាគរយ។[38]

(៤) ថ្នាក់កម្រិតឧត្តមសិក្សាសរុបចំនួន ២២២,៨៧៩ នាក់ សិស្សមានស្រី ១០៦,៩៥២ នាក់ស្មើនិងចំនួន ៤៨ ភាគរយ។ ចំពោះនិស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្ររងមានចំនួន ១៩,៥៧៥ នាក់ មានសិស្សស្រីចំនួន ៥២,៥ ភាគរយ នៅក្នុងនោះមាននិស្សិតអាហារូបករណ៍ចំនួន ២,៣៧៤ នាក់ មានសិស្សស្រី ៥៥,៧ ភាគរយ។ និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រ ១៧៩,២៥៨ នាក់ មានសិស្សស្រី ៥០,៧ ភាគរយ និងនិស្សិតអាហារូបករណ៍មាន ២៧,៣៣៨ នាក់ មានសិស្សស្រីចំនួន ៥១,៨ ភាគរយ។ ចំណែកនិស្សិតថ្នាក់បរិញ្ញាបត្រកំពុងសិក្សាលើមុខវិជ្ជា វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (ស្ទែម)មានចំនួន ២៨,៣ ភាគរយ មានស្រីចំនួន ១៦,៩ ភាគរយ)។ និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មាន ២៣,២៥៦ នាក់ មានស្រី ២៤,៤ ភាគរយនិងថ្នាក់បណ្ឌិតមានចំនួន ៧៩០ នាក់ មានស្រី ៧.៣ ភាគរយ។ សរុបមក ចំពោះអាត្រារួមនៃការសិក្សានៅថ្នាក់ឧត្តមសិក្សាគឺមានចំនួន ១២ ភាគរយ នៅក្នុងឆ្នាំសិក្សា ២០១៩-២០២០។[39]

(៥) ការអប់រំក្រៅប្រព័ន្ធអត្រាអក្ខរកម្មមនុស្សពេញវ័យអាយុ ១៥ ឆ្នាំឡើងបានកើនពី ៨០,៥ ភាគរយ (ស្រីមានចំនួន ៧៥ ភាគរយ) ដល់ ៨៧,៧ ភាគរយ (ស្ត្រីមានចំនួន ៨៤,៨ ភាគរយ) នៅឆ្នាំ២០១៩។ ចំណែកឯអត្រាអក្ខរកម្មនៅតំបន់ជនបទគឺមានចំនួន ៨៣,៨ ភាគរយ និងនៅទីប្រជុំជនមានចំនួន ៩៣,៣ ភាគរយ។ អត្រាអក្ខរភាពបុរសនិងស្ត្រីខុសគ្នាច្រើនតាមក្រុមអាយុនិងទីតាំងភូមិសាស្ត្រ ប៉ុន្តែអត្រារបស់ស្ត្រីខ្ពស់ជាងបុរសបន្តិចបន្តួចចំពោះក្រុមអាយុ ១៥-១៩ ឆ្នាំហើយអត្រារបស់ស្ត្រីទាបជាងខ្លាំងធៀបនិងអត្រារបស់បុរសមានអាយុ ៦០ ឆ្នាំឡើង។ អ្នកសិក្សាក្នុងកម្មវិធីអក្ខរកម្មវិជ្ជាជីវៈមានគឺ

[38] ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំឆ្នាំ២០២១-២០២៥ (ទំព័រទី៤)

[39] ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំឆ្នាំ២០២១-២០២៥ (ទំព័រទី៦)

ចំនួន ១៩,១០១ នាក់ មានចំនួនស្មើ ៦៥,៤ ភាគរយ។ អ្នកសិក្សាកម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធមាន ៦,៧៦០ នាក់ ស្រីមានចំនួន ៤៥,៩ ភាគរយ និងកម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធមានអ្នកសិក្សា ៣៧៤ នាក់ ស្រីមានចំនួន ៤២,៥ ភាគរយ។

(៦) ការអភិវឌ្ឍយុវជនក្រសួងបានធ្វើការបូកសរុបចលនាប្រឡងប្រណាំង ៣ល្អ "កូនល្អ សិស្សល្អ មិត្តល្អ" នៅថ្នាក់ជាតិមានអ្នកចូលរួមចំនួន ៤០១ នាក់ ស្រីមានចំនួន ៥១ ភាគរយ និងមន្ត្រីដឹកនាំ ២៥ នាក់ ស្រីមានចំនួន ២០ ភាគរយ ដើម្បីអភិវឌ្ឍន៍បំណិនយុវជននិងកុមារលើចលនាប្រឡងប្រណាំង ៣ ល្អ កូនល្អ សិស្សល្អ និងមិត្តល្អដើម្បីឱ្យក្លាយជាពលរដ្ឋល្អ។ ក្រុមប្រឹក្សាកុមារកម្ពុជាបានកំណត់ក្របខណ្ឌអនុវត្តន៍ចាប់ពីបឋមសិក្សាដល់មធ្យមសិក្សាបឋមភូមិគិតពីថ្នាក់ទី ៤ ដល់ថ្នាក់ទី៩។ ក្រុមប្រឹក្សាកុមារកម្ពុជាមាន ៨,៩៦៧ ក្រុម ដែលមានសមាជិក ១,៥៥២,៨៤០ នាក់ មានស្រីចំនួន ៧៨៨,៩០១ នាក់ស្មើនិង ៥០,៨ ភាគរយ។ ក្រុមប្រឹក្សាយុវជនកម្ពុជាបានកំណត់ក្របខណ្ឌអនុវត្តន៍នៅមធ្យមសិក្សាទុតិយភូមិ។ ក្រុមប្រឹក្សាយុវជនកម្ពុជាមាន ៥២៥ ក្រុម មានសមាជិក ៣២១,១៤៥ នាក់ មានស្រី ១៧១,៤៩៤ នាក់ ស្មើនិង ៥៣,៤ ភាគរយ។ ក្រុមប្រឹក្សាកុមារកម្ពុជានិងក្រុមប្រឹក្សាយុវជនកម្ពុជាមានសាខា អនុសាខានិងសមាជិកជាកុមារយុវជនកើនឡើងដោយមានកម្មវិធីស្ម័គ្រចិត្តកម្មវិធីអប់រំបំណិនជីវិតតាមមូលដ្ឋានកំណើគ្រឹះស្ថានសិក្សានិងការចូលរួមគាំទ្រពីគ្រប់អ្នកពាក់ព័ន្ធជាពិសេសជួយដល់ការងារស្វយ័ត ការគ្រប់គ្រងសាលារៀន ការគាំទ្រសកម្មភាពក្លឹប ការងារស្ម័គ្រចិត្ត និងជួយសិស្សប្រឡងថ្នាក់ទី១២។[40]

## ៣.២. ពិភាក្សាលើការពង្រឹងសមត្ថភាពស្ត្រីតាមរយៈវិស័យសាធារណៈ

### ក. ស្ថាប័នថ្នាក់ជាតិ

#### កម្រិតនយោបាយ

នៅក្នុងប្រទេសកម្ពុជាចំពោះវិសមភាពយេនឌ័រនៅតែជាបញ្ហាសំខាន់ទោះបីជាមានការរីកចម្រើនយ៉ាងឆាប់រហ័សផ្នែកសេដ្ឋកិច្ចសង្គម និងនយោបាយក្នុងប្រទេសយ៉ាងណាក៏ដោយខណៈពេលដែលកម្ពុជាកំពុងតែមានការរីកចម្រើនគួរឱ្យកត់សម្គាល់ផងដែរក្នុងការកាត់បន្ថយគម្លាតយេនឌ័រនៅក្នុងវិស័យជាច្រើន។ រាជរដ្ឋាភិបាលបានកំណត់ការផ្តល់អំណាចដល់ស្ត្រីដែលជាទិសដៅអាទិភាពនៅគ្រប់កំរិតទូទាំងប្រទេសហើយស្ត្រីក៏មានស្ថានភាពល្អប្រសើរជាងមុនហើយកម្ពុជាសម្រេចបានស្នាដៃគួរឱ្យកត់សម្គាល់ចាប់ពីនីតិកាលទី១នៃរដ្ឋសភាដល់នីតិកាលទី៦។

[40] ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំឆ្នាំ ២០២១-២០២៥ (ទំព័រទី៧,៨)

តាមរបាយការណ៍គម្លាតយេនឌ័រពិភពលោកឆ្នាំ ២០២០ ដែលចេញផ្សាយដោយវេទិការសេដ្ឋកិច្ចពិភពលោកគម្លាតយេនឌ័រកម្ពុជាស្ថិតនៅក្នុងលំដាប់ថ្នាក់ទី៨៩ ក្នុងចំណោមប្រទេសចំនួន ១៥៣ ក្នុងឆ្នាំ ២០១៩ តែក្រោយមកក្នុងរយៈពេល៦ឆ្នាំកន្លងមកនេះចំពោះការដោះស្រាយបញ្ហាវិសមភាពយេនឌ័រនៅកម្ពុជាបានទទួលលទ្ធផលជាវិជ្ជមានដោយកម្ពុជាធ្លាប់ជាប់ចំណាត់ថ្នាក់ទី១០៨។ យ៉ាងណាមិញ ការចូលរួមរបស់ស្ត្រីនៅក្នុងការពង្រឹងភាពអង់អាចខាងនយោបាយគឺឈរនៅលំដាប់ថ្នាក់ទី១១៩នៅក្នុងចំណោម ១៥៣ ប្រទេស ដែលទាមទារឱ្យក្រសួងស្ថាប័ននានាមានសមត្ថកិច្ចចូលរួមធ្វើការសហការគ្នាដើម្បីធ្វើឱ្យស្ថានភាពស្ត្រីកម្ពុជានៅក្នុងវិស័យនយោបាយល្អប្រសើរឡើងបន្ថែមទៀត។

ម្យ៉ាងទៀត ស្ត្រីនៅក្នុងនីតិកាលទី៤ (ឆ្នាំ ២០១៨-២០២៤) ចំនួនសមាជិកព្រឹទ្ធសភាសរុបមាន ៦២ រូប ក្នុងនោះមានព្រឹទ្ធសមាជិកស្ត្រីចំនួន ១០ រូប ចំនួនស្ត្រីនៅក្នុងព្រឹទ្ធសភាមានការកើនឡើង ១ ភាគរយ នៅក្នុងរយៈពេលពីរទសវត្សរ៍។ នៅក្នុងអាណត្តិទីមួយ (១៩៩៩-២០០៦) ស្ត្រីមានចំនួន ១៥ ភាគរយ ឯនៅអាណត្តិទី៤ (ឆ្នាំ ២០១៨-២០២៤) ស្ត្រីមានចំនួន ១៦ ភាគរយ។ ទិន្នន័យនេះអាចសន្និដ្ឋានបានថាចំនួនស្ត្រីនៅក្នុងព្រឹទ្ធសភានៅតែមិនទាន់មានការផ្លាស់ប្តូរដែលទំនងជាត្រូវធ្វើការពិនិត្យឡើងវិញទៅលើគោលនយោបាយ និងយន្តការដែលមានស្រាប់ក្នុងការជំរុញ និងទាក់ទាញស្ត្រីឱ្យចូលរួមកាន់តែច្រើននៅក្នុងស្ថាប័នព្រឹទ្ធសភា និងនៅក្នុងការបោះឆ្នោតនាអាណត្តិខាងមុខ។

នៅក្នុងនីតិកាលទី៦ នេះរដ្ឋសភាមានសមាជិកសរុបចំនួន ១២៥ រូប ក្នុងនោះមានស្ត្រីចំនួន ២៦ រូប។ ស្ថានភាពរបស់សមាជិកសភាស្ត្រីត្រូវបានបង្ហាញតាមរយៈទិន្នន័យបែងចែករវាងស្ត្រីនិងបុរស។ ចំនួនសមាជិករដ្ឋសភាស្ត្រីមានការកើនឡើងគួរឱ្យកត់សម្គាល់ប្រមាណជា ៦ ភាគរយ នៅក្នុងអាណត្តិទី១ កើនដល់ ២១ ភាគរយនៅក្នុងអាណត្តិទី៦។ គួរឱ្យកត់សម្គាល់ផងដែរចំនួនស្ត្រីកាន់តែច្រើនដែលកំពុងកាន់តួនាទីខ្ពស់នៅក្នុងរដ្ឋសភាបើប្រៀបធៀបទៅនិងអាណត្តិទី១។ ជាក់ស្តែងមានស្ត្រី១ រូប ជាអនុប្រធានរដ្ឋសភា ២ រូប ជាប្រធានគណៈកម្មការ និង ៤ រូប ជាអនុប្រធានគណៈកម្មការ។ ស្ថិតិដែលស្ត្រីនិងបុរសដែលបំពេញតួនាទីជាអនុរដ្ឋលេខាធិការឈរនៅលំដាប់ខ្ពស់ជាងគេបំផុតបើប្រៀបធៀបនិងមុខតំណែងផ្សេងៗទៀតមានស្ត្រីចំនួន ៥៥ ភាគរយនៅក្នុងចំណោមស្ត្រីទាំងអស់។ មុខតំណែងជារដ្ឋលេខាធិការគឺជាតំណែងខ្ពស់ទី ២ មានស្ត្រីចំនួន ៤២ ភាគរយក្នុងចំណោមស្ត្រីទាំងអស់។ បើយើងធ្វើការប្រៀបធៀបចំនួនស្ត្រីនិងបុរសដែលមានមុខតំណែងដូចគ្នានោះយើងនិងឃើញថាវាមានគម្លាតខ្លាំងហើយអត្រាស្ត្រីមានតិចជាង ២០ ភាគរយនៅក្នុងមុខតំណែងនីមួយៗបើធៀបទៅនិងបុរស។ ម្យ៉ាងទៀត ពុំទាន់មានស្ត្រីនៅក្នុងតំណែងជាទេសរដ្ឋមន្ត្រីនៅឡើយទេ។

**កម្រិតបច្ចេកទេស**

រដ្ឋាភិបាលដែលប្រកបដោយប្រជាធិបតេយ្យ និងមានលក្ខណៈជាតំណាងពិតប្រាកដមិនអាចបង្កើតឡើងដោយគ្មានការចូលរួមពីស្ត្រីឡើយដោយបានដឹងហើយថានៅក្នុងប្រព័ន្ធតុលាការកម្ពុជាបានចែកចេញជា ៣ កម្រិតគឺសាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល។ អាជ្ញាសាលានៅឆ្នាំ ២០១៩ ដែលមានចំនួនសរុប ២៧ រូប មានស្ត្រីចំនួន ២ រូប។ ទន្ទឹមនិងនេះ ចំនួនសារការីសរុបមាន ៦៦ រូប មាន ៨ រូប ជាស្ត្រីដែលស្មើនិង ១២ ភាគរយ។ ស្ត្រីមានតួនាទីដែលជាចៅក្រមមានចំនួន ១៤ ភាគរយ ក្នុងឆ្នាំ ២០១៣ និងមានការកើនឡើងដល់ ១៥ ភាគរយ ក្នុងឆ្នាំ ២០១៩។ ចំនួនស្ត្រីដែលមានតួនាទីជាព្រះរាជអាជ្ញាបានកើនឡើងពី ១០ ភាគរយ នៅក្នុងឆ្នាំ ២០១៣ កើនឡើងដល់ ១៤ ភាគរយ នៅឆ្នាំ ២០១៩។ រីឯចំនួនមេធាវីដែលជាស្ត្រីមានការកើនឡើងគួរឱ្យកត់សម្គាល់ផងដែរពីចំនួន ១៨ ភាគរយ ក្នុងឆ្នាំ ២០១៣ ដល់ ២២ ភាគរយ នៅក្នុងឆ្នាំ ២០១៩។ ដោយឡែកចំនួនមេធាវីសរុបមានការកើនឡើងខ្ពស់ជាងមុនទ្វេរដងពី ៨៦៦ នាក់ ក្នុងឆ្នាំ ២០១៣ ដល់ ២,០៥០ នាក់ ក្នុងឆ្នាំ ២០១៩។ បើប្រៀបធៀបទៅនិងវិជ្ជាជីវៈខាងលើតួនាទីជាក្រឡាបញ្ជីមានស្ត្រីច្រើនជាងគេប្រមាណជា ២២ ភាគរយក្នុងឆ្នាំ ២០១៣ និងចំនួន ២៣ ភាគរយ ក្នុងឆ្នាំ ២០១៩។ យើងអាចសន្និដ្ឋានបានថាការចូលរួមរបស់ស្ត្រីក្នុងស្ថាប័នតុលាការនៅមានកម្រិតទាបក្នុងរយៈពេល ៧ ឆ្នាំមកនេះដែលគួរតែត្រូវបានគិតគូរយកមកសិក្សាបន្ថែមទៀតនាពេលក្រោយ។

ចំណែកស្ត្រីនិងបុរសនៅថ្នាក់កណ្តាលដែលមានតួនាទីគិតចាប់ពីអនុប្រធានការិយាល័យឡើងទៅដល់អគ្គនាយក។ ទិន្នន័យនេះបានបង្ហាញឱ្យឃើញថាការចូលរួមរបស់ស្ត្រីនៅក្នុងតំណែងជាអ្នកគ្រប់គ្រងតាមក្រសួងស្ថានប័ន (ថ្នាក់កណ្តាល) នៅតែមានកម្រិតទាបបើប្រៀបធៀបទៅនិងបុរសក្នុងឆ្នាំ២០១៩។ ស្ត្រីកាន់តំណែងជាអគ្គនាយកមានចំនួន ១០ ភាគរយ និងអគ្គនាយករងមានចំនួនតិចជាង ១៤ ភាគរយ។ តែគួរឱ្យកត់សម្គាល់ផងដែរថាចំនួនស្ត្រីជាអគ្គាធិការមាន ១០ ភាគរយ អគ្គាធិការរងមានចំនួន ១៨ ភាគរយ។ ស្ថានភាពស្រដៀងគ្នាសម្រាប់ស្ត្រីក្នុងមុខតំណែងជាអធិការ។ ចំណែកតួនាទីជាប្រធាននាយកដ្ឋានមានស្ត្រីចំនួន ១១ ភាគរយ អនុប្រធាននាយកដ្ឋានមាន ២១ ភាគរយ និងអធិការរងមានស្ត្រីចំនួន ៣០ ភាគរយ។ ស្ត្រីដែលជាប្រធានការិយាល័យមានចំនួន ២៣ ភាគរយនិងអនុប្រធានការិយាល័យមានស្ត្រី ៣២ ភាគរយ។ ទិន្នន័យនេះបានបង្ហាញឱ្យឃើញថាស្ត្រីមានទំនោរកាន់តំណែងជាអនុប្រធានច្រើនជាង អគ្គនាយក អគ្គាធិការ អធិការ ប្រធាននាយកដ្ឋាន និងប្រធានការិយាល័យ។ យើងបានសង្កេតឃើញថាស្ត្រីភាគច្រើនមានតួនាទីជាអនុប្រធានការិយាល័យមានចំនួន ៥៤ ភាគរយ បើប្រៀបធៀបទៅនិងចំនួនស្ត្រីសរុបទាំងអស់ដែលជាមន្ត្រីរាជការ។ ជារួមគម្លាតរវាងបុរសនិងស្ត្រីនៅតែមានកម្រិតខ្ពស់ដដែលស្ត្រីមានចំនួន ២៥ ភាគរយតែប៉ុណ្ណោះក្នុងកម្រិតគ្រប់គ្រងរដ្ឋបាលថ្នាក់កណ្តាល។ ចំពោះស្ថានភាពស្ត្រីនិងបុរសនៅថ្នាក់ខេត្តក្រោមការ

ដឹកនាំរបស់រដ្ឋាភិបាលថ្នាក់កណ្តាល។ ស្ថានភាពរបស់ស្ត្រីនៅថ្នាក់ក្រោមជាតិគឺមិនខុសគ្នាខ្លាំងពីថ្នាក់កណ្តាលនោះទេ។ ប្រសិនបើយើងមើលទៅលើការបែងចែកតាមភេទដោយតំណែងជា នាយករដ្ឋបាល ប្រធានមន្ទីរខេត្ត សរុបមានស្ត្រីចំនួន ៩ ភាគរយ។ តួនាទីជានាយករងរដ្ឋបាល អនុប្រធានមន្ទីរសរុបមានស្ត្រី ១៩ ភាគរយ និងតួនាទីជាប្រធានការិយាល័យមន្ទីររាជធានី ខេត្ត សរុបមានស្ត្រី ២១ ភាគរយ។ មន្ត្រីរាជការស្ត្រីដែលចូលបម្រើការជាមន្ត្រីរាជការដោយត្រូវបញ្ចូលស្ត្រីប្រមាណពី ២០ ភាគរយ ទៅ ៥០ ភាគរយ នៅក្នុងការប្រឡងជ្រើសរើសមន្ត្រីរាជការប្រចាំឆ្នាំនៅតាមស្ថាប័នសាធារណៈ។[41] ដោយឡែកចំពោះវិស័យអប់រំក្នុងឆ្នាំ ២០២០ បុគ្គលិកអប់រំគ្រប់ប្រភេទក្របខណ្ឌមានគ្រូមត្តេយ្យសិក្សាមានចំនួន ៣,៧២១ នាក់ ស្រី ៣,៦១៧ នាក់ ស្មើ ៩៧,២០ ភាគរយ គ្រូបឋមសិក្សា ៥៤,៨៧០ នាក់ មានស្រី ចំនួន ២៨,៥០៦ នាក់ ស្មើនិង ៥១,៩៥ ភាគរយ។ ចំណែកឯគ្រូបង្រៀនកម្រិតមូលដ្ឋាន ៤,២៣៤៣ នាក់ មានស្រី ១,៨០៧១ នាក់ ដែលស្មើនិង ៤២,៦៧ ភាគរយ គ្រូបង្រៀនកម្រិតមូលដ្ឋាន (អប់រំកាយនិងកីឡា) ២,៣៥៧ នាក់ មានស្រី ៤៩៥ នាក់ ស្រីស្មើនិង ២១ ភាគរយ គ្រូបង្រៀនកម្រិតឧត្តម (បង្រៀននៅវិទ្យាល័យ) មាន ១៦,៥៨១ នាក់ ដែលមានស្រីចំនួន ៥,១០៥ នាក់ (៣០,៩០ ភាគរយ) គ្រូបង្រៀនកម្រិតឧត្តមដែលបម្រើការងារនៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈមានចំនួន ១,៦៣៦ នាក់ មានស្រី ៣៤៣ នាក់ ស្មើនិងចំនួន ២០,៩៦ ភាគរយ។ អ្នកគ្រប់គ្រងនៅថ្នាក់ជាតិ (ចាប់ពីអនុប្រធានការិយាល័យរហូតដល់អគ្គនាយក) មានចំនួន ១,៣៣៤ នាក់ មានស្រី ២៧២ នាក់ ស្មើនិង ២០.៣៩ ភាគរយ។ អ្នកគ្រប់គ្រងនៅថ្នាក់ក្រោមជាតិ (ចាប់ពីអនុប្រធានការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ រហូតដល់ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត) មាន ១,៣១៤ នាក់ មានស្រី ២០៥ នាក់ ស្មើ ១៦,៣៦ ភាគរយ។ ចំពោះមុខតំណែងជានាយក នាយិកា នាយករង នាយិការង គ្រឹះស្ថានសិក្សាបឋមសិក្សា និងមធ្យមសិក្សាសរុប ១២,៧២៣ នាក់ មានស្រីចំនួន ២,១២៧ នាក់ ស្មើនិង ១៦,៧២ ភាគរយ។[42]

**ខ.ថ្នាក់ក្រោមជាតិ**

ក្រឡេកមកមើលពីឋានៈនិងតួនាទីរបស់ស្ត្រីនៅថ្នាក់ក្រោមជាតិដោយគិតចាប់ពីតំណែងអភិបាលរហូតដល់សមាជិក ឃុំ សង្កាត់ រួមមានថ្នាក់អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ស្ត្រីមាន ៤១ ភាគរយ មាន១ រូប នៃមុខតំណែងអភិបាលខេត្តនៅក្នុងឆ្នាំ ២០១៩ និងមុខតំណែងជាអភិបាល ក្រុង ស្រុក ខណ្ឌ គឺមានចំនួន ៣ ភាគរយ ស្មើនិង ៦ រូប (អត្រាស្ត្រីហាក់មានចំនួនខ្ពស់ក្នុងមុខតំណែងទាប)។ តំណាងស្ត្រីជា

[41] ឯកសារស្រាវជ្រាវសង្កេតក្រុមសមាជិកាព្រឹទ្ធសភា៖ វឌ្ឍនភាពស្ត្រីក្នុងវិន័យនយោបាយ(២០១៦) (ទំព័រទី១,២)

[42] ក្រសួងអប់រំ ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំ ២០២១-២០២៥(ទំព័រ ១១-១៦)

អភិបាលសរុបជាភាគរយនៅក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានការកើនឡើងពី ៤ ភាគរយ (នៅឆ្នាំ ២០០៧) ដល់ ២០ ភាគរយ ក្នុងឆ្នាំ ២០១៩ ប្រៀបធៀបនិងងបុរស។

នៅក្នុងអាណត្តិទី ៥ ជាអាណត្តិនៃក្រុមប្រឹក្សានិងចាប់ផ្តើមពីថ្ងៃបោះឆ្នោតនិងចប់នៅថ្ងៃក្រុមប្រឹក្សាបានជ្រើសតាំងក្រុមប្រឹក្សាបោះឆ្នោតដោយប្រយោលជាសេរី និងស្មើភាពគ្នាដោយសម្ងាត់ការចូលរួមរបស់ស្ត្រីនិងបុរសជាក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នៅកំឡុងពេលបោះឆ្នោតឆ្នាំ ២០០៩-២០១៤ និងឆ្នាំ ២០១៩-២០២៤ ភាពជាតំណាងរបស់ស្ត្រីបានកើនឡើងយ៉ាងស្ដួចស្ដើងពីបំផុត ១២ ភាគរយ កើនឡើងទៅ ១៧ ភាគរយ។

ក្រុមប្រឹក្សា ឃុំ សង្កាត់ ត្រូវបានធ្វើការបោះឆ្នោតជារៀងរាល់ ៥ ឆ្នាំម្តង និងបោះឆ្នោតថ្ងៃជាមួយគ្នាទាំងអស់នៅក្នុងប្រទេសកម្ពុជាក្នុងឃុំមាន ១,៦៤៦ ឃុំ។ កាលបរិច្ឆេទពិតប្រាកដនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាត្រូវបានកំណត់ដោយនាយករដ្ឋមន្ត្រីដោយផ្អែកលើសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ នៅតាមឃុំ សង្កាត់នីមួយៗចាំបាច់ត្រូវមានក្រុមប្រឹក្សាមួយដែលត្រូវបានជ្រើសរើសតាមការបោះឆ្នោតរបស់ប្រជាពលរដ្ឋបោះឆ្នោតជាសកលនៅក្នុង ឃុំ សង្កាត់ ទាំងនោះ។ ចំពោះលទ្ធផលបោះឆ្នោតក្រុមប្រឹក្សា ឃុំ សង្កាត់ ឆ្នាំ ២០០២ និងឆ្នាំ ២០១៧ បានបង្ហាញថាស្ត្រីក្នុងតំណែងជាមេឃុំ និងចៅសង្កាត់កើនឡើងពីចំនួន ៣ ភាគរយ ក្នុងឆ្នាំ ២០០២ កើនឡើងដល់ ៨ ភាគរយ ក្នុងឆ្នាំ ២០១៧ និងតួនាទីជាជំទប់ទី១ កើនឡើងពីចំនួន ៤ ភាគរយ ក្នុងឆ្នាំ ២០០២ កើនឡើងដល់ ១៦ ភាគរយ ក្នុងឆ្នាំ ២០១៧។ ស្ត្រីជាសមាជិកា ឃុំ សង្កាត់ មានការកើនឡើងពី ៩ ភាគរយ នៅក្នុងឆ្នាំ ២០០២-២០០៧ បានកើនឡើងដល់ ១៤ ភាគរយ នៅឆ្នាំ ២០១៧-២០២២។

ចំពោះលទ្ធផលទាំងនេះគឺត្រូវបានតំណាងឱ្យសមិទ្ធិផលដ៏សំខាន់មួយដែលស្ត្រីត្រូវបានគេទទួលស្គាល់ថាជាអ្នកដឹកនាំនៅថ្នាក់ក្រោមជាតិ។ ចំពោះឥរិយាបទសាធារណៈទាក់ទងនិងតំណាងរបស់ស្ត្រីហាក់ដូចជាមានការផ្លាស់ប្តូរជាវិជ្ជមានជាពិសេសទាក់ទងនិងមុខតំណែងអភិបាលកិច្ចមូលដ្ឋាន។ ការសិក្សាក្នុងឆ្នាំ ២០១៤ របស់មូលនិធិអាស៊ីដែលបានបង្ហាញថាអ្នកឆ្លើយសំណួរ ៨៥ ភាគរយ ជឿថាស្ត្រីគួរតែសកម្មដូចបុរសនៅក្រុមប្រឹក្សា ឃុំសង្កាត់ និងការសិក្សា។ នៅឆ្នាំ ២០១៨ ស្តីពីការយល់ឃើញជាសាធារណៈរបស់ស្ត្រីក្នុងភាពជាអ្នកដឹកនាំនៅថ្នាក់ក្រោមជាតិបានរកឃើញថាមានចំនួន ៩៤.៥ ភាគរយ នៃអ្នកឆ្លើយតបបានគាំទ្រស្ត្រីជាអ្នកដឹកនាំនៅក្នុងវិស័យនយោបាយ។[43]

[43] អគ្គរដ្ឋលេខាធិការដ្ឋានរដ្ឋសភា ៖បញ្ហាប្រឈមរបស់ស្ត្រីក្នុងភាពជាអ្នកដឹកនាំៈលទ្ធផលស្រាវជ្រាវគន្លឹះនៃការវិភាគស្ថិតិយេនឌ័រ (ទំព័រ ៧-២០)

## ៣.៣. ពិភាក្សាលើការពង្រឹងសមត្ថភាពស្ត្រីក្នុងវិស័យឯកជន

ស្ថាប័នឯកជន និងដៃគូពាក់ព័ន្ធផ្សេងទៀតបានកំពុងបង្កើនការវិនិយោគក្នុងការពង្រឹងសក្តានុពលរបស់ស្ត្រីនៅក្នុងវិស័យសេដ្ឋកិច្ចឌីជីថលនិងសេដ្ឋកិច្ចបៃតងតាមរយៈការអភិវឌ្ឍសហគ្រិនភាពរបស់ស្ត្រី និងការលើកកម្ពស់សេដ្ឋកិច្ចគ្រួសាររបស់ស្ត្រី។ នៅក្នុងវិស័យឯកជនស្ត្រីក៏មានចំនួនកើនឡើងជាបន្តបន្ទាប់ដោយសារមានការផ្តល់តម្លៃទៅលើសមត្ថភាពរបស់ស្ត្រីដោយនិយោជកមានគំនិតចូលចិត្តស្ត្រីជាងបុរស បើនៅពេលពួកគេមានគោលដៅជ្រើសរើសស្ត្រីកាន់តែច្រើនដោយសារស្ត្រីចេះគ្រប់គ្រងហានិភ័យបានល្អ និងធ្វើការសម្រេចចិត្តបានឆាប់រហ័សបើធៀបនិងបុរសហើយពួកគេសម្រិតសម្រាំងក្នុងការបំពេញភារកិច្ចរបស់ខ្លួន។ បច្ចុប្បន្នស្ត្រីមានទំនុកចិត្តដូចបុរសពីព្រោះស្ត្រីទទួលបានការអប់រំកាន់តែប្រសើរ មានការគាំទ្រពីគ្រួសារ និងពីនិយោជក និងការទទួលបានបច្ចេកវិទ្យាកាន់តែទូលំទូលាយសម្រាប់សិក្សាស្ត្រីជាសហគ្រិនទាំងអស់មានប្រមាណ ៦១ ភាគរយ ដែលកំពុងទទួលបានការពង្រឹងបន្ថែមពីគោលការណ៍សហគ្រិនភាពស្ត្រីតាមរយៈគោលនយោបាយគាំពារគ្រួសារ និងគាំពារសង្គមក្រោមការបើកវេទិកាថ្នាក់ជាតិស្តីពីការលើកកម្ពស់សហគ្រិនភាពស្ត្រីនៅតំបន់អាស៊ានដែលមានការចូលរួមពីក្រសួងកិច្ចនារី និងអង្គការដៃគូពាក់ព័ន្ធផ្សេងៗទៀត។ ស្ត្រីដែលមានតួនាទីដឹកនាំសហគ្រាស ធុនតូច និងមធ្យមមានចំនួន ៦១ ភាគរយ។ សហគ្រាសធុនតូចនិងមធ្យម (SME) មានស្ត្រីប្រមាណ ៩៨ ភាគរយ នៃធុរកិច្ចទាំងអស់បានចូលរួមចំណែកដល់សេដ្ឋកិច្ចជាតិប្រមាណ ៥៨ ភាគរយ និងបានផ្តល់ការងារប្រមាណ ៧៣ ភាគរយ នៃការងារទាំងអស់។ ចំពោះសហគ្រាស ធុនមីក្រូតូចនិងមធ្យមមាន ៩៨ ភាគរយ នៃចំនួនសហគ្រាសសរុបដែលបានចូលរួមចំណែកដល់សេដ្ឋកិច្ចជាតិ និងបានផ្តល់ការងារដល់ប្រជាពលរដ្ឋដែលក្នុងនោះស្ត្រីគឺជាអ្នកបង្កើតនិងគ្រប់គ្រងការងារទាំងនោះដោយមានសហគ្រាសធុនមីក្រូតូចនិងមធ្យម។[44]

ជាក់ស្តែងដោយយោងតាមការផ្តល់បទសម្ភាសន៍របស់ស្ត្រីម្នាក់ដែលជានិយោជកដៃគូគ្រប់គ្រងក្រុមហ៊ុន HRINC (Cambodia) Co.Ltd ដែលបានផ្តល់បទសម្ភាសន៍ជាមួយអង្គភាពសារព័ត៌មានភ្នំពេញប៉ុស្តិ៍កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ដែលបានមានប្រសាសន៍ថាស្ត្រីដែលបំពេញការងារនៅកម្ពុជាកំពុងបង្ហាញអំពីការបំផុសគំនិត និងការចូលរួមនៅក្នុងសង្គម។ ស្ត្រីកំពុងជួយជំរុញកំណើនសេដ្ឋកិច្ចក៏ដូចជានាំមកនូវឥទ្ធិពលយ៉ាងធំធេងក្នុងទីផ្សារប្រើប្រាស់និងក្នុងសេដ្ឋកិច្ចសម័យទំនើបស្ត្រីទទួលបានប្រាក់ចំណូលកាន់តែខ្ពស់និងបង្កើតទ្រព្យសម្បត្តិកាន់តែប្រសើរ។ អ្នកស្រីបានបន្តប្រសាសន៍ថាខណៈពេលស្ត្រីបំពេញការងារមានកាន់តែច្រើនគឺវាបានធ្វើឱ្យទីផ្សារអ្នកប្រើប្រាស់ផ្លាស់ប្តូរ ពីព្រោះពួកគេមានអំណាចទិញកាន់តែច្រើន។ អ្នកស្រីបានឧទាហរណ៍,ស្ត្រីជាច្រើននៅក្នុងវិស័យ

---

[44] សៀវភៅ កម្ពុជាសម័យតេជោ វគ្គ ១៥« ស្ត្រី និងវិស័យនយោបាយ និងវិស័យឯកជន (គេហទំព័រ AKP ភ្នំពេញ ចេញផ្សាយថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០២៣)

កាត់ដេរនៅពេលដែលពួកគេធ្វើចំណាកស្រុកមកទីក្រុងពួកគេក៏ជួយជំរុញដល់ទីផ្សារអ្នកប្រើប្រាស់។ អ្នកស្រីបន្តថា ក្នុងនាមជាលោកស្រីដែលមានបទពិសោធន៍គ្រប់គ្រងក្រុមហ៊ុនជិត១៧ ឆ្នាំកន្លងមកហើយនោះបានថានៅក្នុងវិស័យឯកជន និយោជកចូលចិត្តស្ត្រីជាងបុរសខណៈពួកគេមានគោលដៅជ្រើសរើសស្ត្រីកាន់តែច្រើនដោយស្ត្រីចេះគ្រប់គ្រងហានិភ័យបានល្អប្រសើរ និងធ្វើការសម្រេចចិត្តបានឆាប់រហ័សបើធៀបនិងបុរសហើយពួកគេហ្មត់ចត់ក្នុងការបំពេញភារកិច្ចរបស់ខ្លួន។ អ្នកស្រីបន្តថានៅក្រុមហ៊ុន HRINC គឺមានបុគ្គលិកស្ត្រីច្រើនជាង ៦០ ភាគរយ ហើយស្ត្រីចំនួន ៧០ ភាគរយ នៃគណៈគ្រប់គ្រងនិងថ្នាក់ដឹកនាំគឺជាស្ត្រី។ សេវាកម្មជ្រើសរើសបុគ្គលិកបានជួយបេក្ខជនជាស្ត្រីកាន់តែច្រើនឱ្យទទួលបានការងារជាអ្នកគ្រប់គ្រងជាពិសេសផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ ផ្នែកលក់ ទំនាក់ទំនងការអភិវឌ្ឍអាជីវកម្ម ទីផ្សារ និងផ្នែកធនធានមនុស្ស។ អ្នកស្រីបន្តថាខ្លួនគាត់ផ្ទាល់គឺជាគំរូមួយនៃសហគ្រិនស្ត្រីជោគជ័យក្នុងនាមជានិយោជក១ រូប គាត់កំពុងរួមចំណែកដល់កំណើនកម្លាំងការងារជាស្ត្រីនិងបំណងប្រាថ្នារបស់ខ្ញុំគឺជួយមនុស្សឱ្យសម្រេចបាននូវសក្តានុពលដ៏ល្អបំផុតរបស់ពួកគេ ការផ្លាស់ប្តូរតូចមួយដែលធ្វើឱ្យមានភាពខុសគ្នាដ៏ធំវាគឺជាអ្វីដែលក្រុមហ៊ុនគួរតែសង្កេតមើលនិងផ្តល់ការគាំទ្រ។ ឧទាហរណ៍ ដូចជាម៉ោងធ្វើការដែលអាចបត់បែនបាននិងការសម្របខ្លួនបានយ៉ាងឆាប់រហ័សទៅនិងបរិយាកាសផ្លាស់ប្តូរគឺជាគន្លឹះដើម្បីទទួលបានជោគជ័យក្នុងអាជីពដែលពួកគេជ្រើសរើសនៅក្នុងទីផ្សារប្រកួតប្រជែងដែលមិនធ្លាប់មាន មានភាពរឹងមាំ និងវិធីសាស្ត្រយ៉ាងសកម្មក្នុងការកំណត់អត្តសញ្ញាណនិងការដោះស្រាយបញ្ហាគឺមានសារៈសំខាន់ណាស់។[45]

---

[45] ការផ្តល់ការសម្ភាសន៍នៅក្នុងគេហទំព័រ ភ្នំពេញប៉ុស្តិ៍៖ របស់ អ្នកស្រី ស៊ុយ សុខា ដៃគូគ្រប់គ្រងក្រុមហ៊ុន HRINC (Cambodia) Co. Ltd ,(២៨,២,២០២២)

# សេចក្តីសន្និដ្ឋាន

ជារួមការពង្រឹងសមត្ថភាពរបស់ស្ត្រីនៃយុគសម័យនីតិរដ្ឋតាមរយៈវិស័យអប់រំគឺពិតជាមានសារៈសំខាន់ណាស់សម្រាប់ស្ត្រីនាពេលបច្ចុប្បន្ន ពីព្រោះស្ត្រីជាចលករដ៏សំខាន់មួយក្នុងការអភិវឌ្ឍសម្រាប់សង្គមជាតិស្ត្រីជាធនធានមនុស្សដ៏មានតម្លៃសម្រាប់សង្គមស្ត្រីបានដើរតួយ៉ាងសំខាន់ក្នុងការចូលរួមអភិវឌ្ឍន៍លើកកម្ពស់សេដ្ឋកិច្ចប្រទេសជាតិឱ្យមានការរីកចម្រើនទៅមុខជាលំដាប់។ លើសពីនេះ រាជរដ្ឋាភិបាលក៏បានបង្កើតច្បាប់និងការទទួលអនុម័តច្បាប់មួយចំនួនដែលមានទាំងច្បាប់ជាតិនិងច្បាប់អន្តរជាតិយកមកអនុវត្តន៍ក្នុងគោលបំណងពង្រឹងសមត្ថភាពរបស់ស្ត្រីយ៉ាងយកចិត្តទុកដាក់លើគ្រប់វិស័យ ជាពិសេសគឺសិទ្ធិស្ត្រីក្នុងវិស័យអប់រំនេះតែម្តង។ បើទោះបីមានការរីកចម្រើនខាងច្បាប់និងការធ្វើគោលនយោបាយជាតិដើម្បីលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីនិងក្មេងស្រីក៏ដោយតែការអនុវត្តគោលនយោបាយផែនការការលើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រីយ៉ាងណាក៏ដោយប្រទេសកម្ពុជា និងបណ្តាប្រទេសដែលជាសមាជិកអាស៊ាននៅតែជាបញ្ហាប្រឈមមួយចំនួនក្នុងការលើកកម្ពស់សមភាពយេនឌ័រ ការផ្តល់ភាពអង់អាចដល់ស្ត្រីក្នុងការអប់រំ និងការលុបបំបាត់រាល់ទម្រង់នៃរើសអើងលើស្ត្រីនិងក្មេងស្រី។ ទោះបីមានគោលនយោបាយនិងផែនការជាច្រើនត្រូវបានរៀបចំឡើងដើម្បីគាំទ្រក្មេងស្រីឱ្យទៅសាលារៀនតែការអនុវត្តគោលនយោបាយនិងផែនការទាំងអស់នោះនៅមានចំណុចខ្វះខាតនៅឡើយ។ ជាក់ស្តែងបើទោះបីការអប់រំចំណេះទូទៅមិនតម្រូវឱ្យចំណាយថវិកាក្តីកុមារនៅតែត្រូវទទួលរងការចំណាយក្រៅផ្លូវការលើការអប់រំរបស់គេ។

ដើម្បីសម្រេចឱ្យបាននូវការលើកកម្ពស់ស្ត្រីគឺរាជរដ្ឋាភិបាលកម្ពុជាបានបង្កើតក្រសួងកិច្ចការនារីដែលជាយន្តការសម្រាប់ការលើកកម្ពស់សមភាពយេនឌ័រនិងការបញ្ជ្រាបយេនឌ័រនៅក្នុងក្រសួងស្ថាប័ន។ គោលនយោបាយនិងផែនការជាក់លាក់ត្រូវបានបង្កើតបន្ថែមទៅលើការផ្តល់សច្ចាប័នទៅលើសន្ធិសញ្ញាអន្តរជាតិផ្សេងៗដែលទាក់ទងនិងការលើកកម្ពស់សិទ្ធិនិងស្ថានភាពស្ត្រី។ ការអនុវត្តច្បាប់និងផែនការយុទ្ធសាស្ត្រទាំងនេះធ្វើឱ្យស្ថានភាពស្ត្រីកម្ពុជាល្អប្រសើរជាងមុន និងមានការផ្លាស់ប្តូរនូវផ្នត់គំនិតរបស់សង្គមបើមើលប្រវត្តិរបស់កម្ពុជាដែលធ្លាប់ជាប្រទេសដែលមានវប្បធម៌ពុំសូវឱ្យតម្លៃទៅលើស្ត្រី ហើយប្រកាន់ខ្ជាប់ពាក្យមួយឃ្លានេះគឺថា «ស្ត្រីវិលចង្ក្រានមិនជុំ»។

ក្រសួងកិច្ចការនារីក៏បានដើរតួទៅជាអ្នកបង្កើនគណនេយ្យភាពសង្គម និងលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិទទួលបានសេវានិងគាំពារសង្គមដល់ស្ត្រីនិងក្មេងស្រីព្រមទាំងពិនិត្យមើលពីលទ្ធភាពដែលពួកគេទទួលបានសេវាទាំងអស់នេះដែរ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាពត្រូវបានបង្កើតឡើងដោយមានការយកចិត្តទុកដាក់ជាពិសេសលើការពង្រឹងសមត្ថភាពមន្ត្រីក្រសួងកិច្ចការនារីដើម្បីបញ្ជ្រាបយេនឌ័រក្នុងវិស័យសំខាន់ៗមានការពង្រឹងសមត្ថភាពនាយកដ្ឋានបច្ចេកទេសដើម្បីគាំទ្រការត្រួតពិនិត្យពីដំណើរការបញ្ជ្រាប

យេនឌ័រ និងការអភិវឌ្ឍសមត្ថភាពរាជរដ្ឋាភិបាលយល់ច្បាស់ថាការលើកកម្ពស់ការយល់ដឹងស្ត្រី និងការចូលរួមរបស់ស្ត្រីគ្រប់វិស័យជាពិសេសការជំរុញលើកទឹកចិត្តស្ត្រីជាថ្នាក់ដឹកនាំក្នុងវិស័យសាធារណៈ នយោបាយ ការលុបបំបាត់ការរើសអើងលើស្ត្រីនិងក្មេងស្រីព្រមទាំងការបង្កើនកាលានុវត្តភាពនានាដល់ស្ត្រីពិតជាមានសារៈសំខាន់ខ្លាំងណាស់នៅក្នុងគោលដៅអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ចប្រកបដោយចីរភាព។

# អនុសាសន៍

ក្រោយពីបកស្រាយប្រធានបទខាងលើចប់ដោយយោងទៅតាមលិខិតបទដ្ឋានគតិយុត្ត និងតាមតួលេខជាក់ស្តែងរបស់ស្ត្រីកម្ពុជានាសម័យនីតិរដ្ឋ ការអភិវឌ្ឍសមត្ថភាពស្ត្រីនិងក្មេងស្រីនៅមានកម្រិតមិនទាន់ឆ្លើយតបនិងគោលការណ៍យេនឌ័រនៅឡើយទេ។ ឆ្លងតាមលទ្ធផលស្រាវជ្រាវខាងលើយើងខ្ញុំសូមចូលរួមជាអនុសាសន៍ដូចខាងក្រោម៖

១. រដ្ឋាភិបាលគួរតែបំផុសចលនា ឬ ផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយដល់ឪពុកម្តាយក្នុងការបញ្ជូនកូនស្រីទៅកាន់សាលារៀនឱ្យបានគ្រប់គ្នាៗនិងធ្វើការសហការគ្នាជាមួយមន្ត្រីគ្រប់ជាន់ថ្នាក់និងអង្គការក្រៅរដ្ឋាភិបាលពីព្រោះថាតាមការស្រាវជ្រាវខាងលើនៅតែក្មេងស្រីមួយចំនួនបានបាត់បង់ឱកាសចូលរៀនមិនដូចក្មេងប្រុសឡើយតាមការបកស្រាយខាងលើស្ត្រីនិងក្មេងស្រីដែលមានទទួលបានការសិក្សារៀនសូត្ររួមមាន៖ កុមារីតូចៗទទួលបានសេវាអប់រំមាន ៥០,៨ ភាគរយ ថ្នាក់មធ្យមសិក្សាបឋមភូមិមានសិស្សស្រី ៥២,៥ ភាគរយ ថ្នាក់មធ្យមសិក្សាទុតិយភូមិមានសិស្សស្រី ៥៤,៥ ភាគរយ កម្រិតឧត្តមសិក្សាមានស្រីចំនួន ៤៨ ភាគរយ និងការអប់រំក្រៅប្រព័ន្ធអត្រាអក្ខរភាពមនុស្សពេញវ័យអាយុ ១៥ ឆ្នាំឡើងស្ត្រីមាន ៨៤,៨ ភាគរយ នៅឆ្នាំ ២០១៩ បើធៀបនិងទៅចំនួនក្មេងស្រីនិងស្ត្រីសរុបនៅកម្ពុជាទៅតាមកម្រិតនៃការអប់រំគឺកម្រិតខ្លះមានការកើនឡើងខ្ពស់និងកម្រកម្រិតខ្លះទៀតនៅទាបនៅឡើយ។ ដូចនេះរដ្ឋាភិបាលគួរតែធ្វើការលើកកម្ពស់សមភាពយេនឌ័រតាមរយៈការបង្កើនការចុះឈ្មោះចូលរៀនរបស់ក្មេងស្រីនៅកម្រិតបឋមសិក្សា និងថ្នាក់មធ្យមសិក្សាដោយផ្តល់អាហារូបករណ៍ដល់សិស្ស-និស្សិតក្រីក្រ ជាពិសេសនារីដោយការបង្កើនគ្រឹះស្ថានសិក្សានៅមូលដ្ឋានការបង្កើនអន្តេវាសិកដ្ឋានដែលផ្តល់សេវាសមរម្យនិងសុវត្ថិភាពសម្រាប់សិស្សនិងនិស្សិតជានារី។

២. រដ្ឋាភិបាលគួរតែបន្តការផ្តល់ឱកាសឱ្យកាន់តែច្រើនឡើងដល់ឥស្សរជនជាស្ត្រីក្នុងជួរដឹកនាំដើម្បីឱ្យឆ្លើយតប និងយេនឌ័រពីព្រោះស្ត្រីជាថ្នាក់ដឹកនាំមាន ២០ ភាគរយ និងចំនួនស្ត្រីជាមន្ត្រីរាជការស៊ីវិលនៅតាមក្រសួងស្ថាប័ននានាចំនួនស្មើ ៤១ ភាគរយ មុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ២៥ ភាគរយនៅក្នុងឆ្នាំ២០១៨ ក្នុងចំណោមស្ត្រីសរុបបើធៀបនិងចំនួនបុរសស្ត្រីនៅតិចជាងបុរស។ ហេតុដូចនេះគួរតែមានការធានានូវការការពារសិទ្ធិរបស់ស្ត្រីព្រមទាំងការចូលរួមពេញលេញនិងស្មើភាពរបស់ស្ត្រីនិងលើកទឹកចិត្តស្ត្រីជាមន្ត្រីនៅគ្រប់កម្រិតឱ្យមានចំនួនស្មើគ្នានិងបុរស។

៣.ក្រសួងកិច្ចការនារីគួរតែពង្រឹងបន្ថែមពីទំនាក់ទំនងល្អជាមួយដៃគូពាក់ព័ន្ធទាំងអស់រួមទាំងបណ្តាញផ្សព្វផ្សាយព័ត៌មានអំពីការលើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងការទទួលបានការសិក្សាមួយដែលល្អប្រសើរដើម្បីពង្រឹងសមត្ថភាពដោយសារតែគម្រោងនៃកម្មវិធីការលើកកម្ពស់ដែលបានអនុវត្តន៍ពីមុនៗនូវមិនទាន់បានឆ្លើយតបគ្រប់គ្រាន់ឡើយទេ។ ដូចនេះក្រសួងកិច្ចការនារីគួរបង្កើនការយកចិត្តទុកដាក់លើការបញ្ជ្រាបយេនឌ័រទៅក្នុង

ក្រសួងស្ថាប័នពាក់ព័ន្ធ និងផ្តោតលើការវិភាគ ការរៀបចំគោលនយោបាយ ការអនុវត្តគម្រោង និងការផ្តល់សេវា នៅតាមថ្នាក់មូលដ្ឋានតាមរយៈការត្រួតពិនិត្យការរៀបចំផែនការ និងថវិកាការអនុវត្តគម្រោង និងតាមដានរបាយការណ៍យ៉ាងជាក់លាក់ពីលទ្ធផលដែលទទួលបានជោគជ័យ។

៤. ក្រសួងអប់រំ យុវជន និងកីឡា គួតែចូលរួមពង្រឹងបន្ថែមពីសកម្មភាពនៃការរៀបចំកម្មវិធីផ្នែកយេនឌ័រនិងកែលម្អពីគុណភាពនៃការអប់រំ និងការបណ្តុះបណ្តាលសម្រាប់ស្ត្រីនិងក្មេងស្រី និងការស្វែងរកការគាំទ្រអំពីការលើកកម្ពស់ការយល់ដឹង ដើម្បីលុបបំបាត់នូវផ្នត់គំនិតសង្គមដែលរើសអើងលើស្ត្រីនិងក្មេងស្រីដោយសហការជាមួយស្ថាប័ននានាតាំងពីថ្នាក់ជាតិរហូតដល់ថ្នាក់ក្រោមជាតិ និងអ្នកដែលពាក់ព័ន្ធផ្សេងៗទៀត៕

## ឯកសារពិគ្រោះ


- វចនានុក្រមសម្ដេចសង្ឃរាជ ជួន ណាត
- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣
- អនុសញ្ញា ស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ(CEDAW)
- សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស ១០,ធ្នូ,១៩៤៨
- ច្បាប់ស្ដីពីការងារ ១០,មករា,១៩៩៧ (ជស/រកម/០៣៩៧/០១/ )
- ច្បាប់ស្ដីពីវិសោធន៍កម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ,លេខនស/រកម/០៧១១/០១៣,០៤.កក្កដា.២០១១,
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៤-២០១៨
- ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំឆ្នាំ២០២១-២០២៥
- យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២
- យុទ្ធសាស្ត្រនារីរតនៈទី៤ (២០១៤ - ២០១៨)
- ស្ត្រីក្នុងភាពជាអ្នកដឹកនាំ របស់លោកបណ្ឌិត ទុយ យូឃីម និង លោកស្រីបណ្ឌិត ជា វណ្ណី នៃវិទ្យាស្ថានមនុស្សសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា
- អគ្គរដ្ឋលេខាធិការដ្ឋានរដ្ឋសភាៈបញ្ហាប្រឈមរបស់ស្ត្រីក្នុងភាពជាអ្នកដឹកនាំៈលទ្ធផលស្រាវជ្រាវគន្លឹះនៃការវិភាគស្ថិតិយេនឌ័រ
- សេចក្ដីសង្ខេបសម្រាប់គោលនយោបាយ១៖ យេនឌ័រការបញ្ជ្រាបយេនឌ័រ បរិបទគោលនយោបាយ ស្ថាប័ន និងភាពជាដៃគូ ការប៉ាន់ប្រមាណអំពីយេនឌ័រនៅកម្ពុជា ២០១៤


### គេហទំព័រ


- គេហទំព័រ ៖ https://eacnews.asia/home/details/12223 (ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០២២)
- គេហទំព័រ ៖ https://www.facebook.com/cambodiantemple/posts/ (ចេញផ្សាយថ្ងៃទី ២៧.៤.២០១៥)
- គេហទំព័រ ៖ រាជ្យបណ្ឌិតសភាកម្ពុជា (ចេញផ្សាយថ្ងៃទី ២២,៣,២០២០)
- វីឌីអូ ស្ត្រីខ្មែរសង្គមរាស្ត្រនិយម ១៩៥៨
- គេហទំព័រ ៖ https://km.m.wikipedia.org/ (ចេញផ្សាយថ្ងៃទី ២៧/៣/២០២៤)
- គេហទំព័រ ៖ Radio Veritas Asai KHMER ( ចេញផ្សាយថ្ងៃទី ២០,៣,២០២៣)
- ឯកសារ Institute of Humanities and Social Sciences (ចេញផ្សាយថ្ងៃទី ២៦/០៣/២០២០)

- កម្មវិធីយល់ដឹងផ្នែកច្បាប់ របស់អង្គភាពព័ត៌មាន Fresh News សហការជាមួយក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ (https://m.freshnewsasia.com/ )(ចេញផ្សាយថ្ងៃទី ២៩/៤/២០១៩)
- សៀវភៅ កម្ពុជាសម័យតេជោ វគ្គ ១៥« ស្ត្រី និងវិស័យនយោបាយ និងវិស័យឯកជន (គេហទំព័រ AKP ភ្នំពេញ ចេញផ្សាយថ្ងៃទី ២២  ខែកក្កដា ឆ្នាំ២០២៣)
- ការផ្តល់ការសម្ភាសន៍នៅក្នុងគេហទំព័រ ភ្នំពេញប៉ុស្តិ៍៖ របស់ អ្នកស្រី ស៊ុយ សុខា ដៃគូគ្រប់គ្រងក្រុមហ៊ុន HRINC (Cambodia) Co. Ltd, (២៨,២,២០២២)

## ឧបសម្ព័ន្ធ

ក.ច្បាប់ជាតិ និងច្បាប់អន្តជាតិ

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា



**មាត្រា ៣៥.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ ។

សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ ត្រូវបានទទួលការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ ។

រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយ ដែលអាចធ្វើឲ្យខូចដល់ការអប់រំ និង ការរៀនសូត្ររបស់កុមារ ឬ ដែលនាំអោយអន្តរាយដល់សុខភាព ឬ សុខុមាលភាពរបស់កុមារ ។

**មាត្រា ៣៦.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិជ្រើសរើសមុខរបរ សមស្រប តាមសមត្ថភាពរបស់ខ្លួន តាមសេចក្តីត្រូវការរបស់សង្គម ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នា ចំពោះការងារដូចគ្នា ។

**មាត្រា ៤៥.-**

ការរើសអើងគ្រប់ប្រភេទប្រឆាំងនឹងស្ត្រីភេទត្រូវបំបាត់ចោល។

ការធ្វើអាជីវកម្ម លើការងាររបស់ស្ត្រី ត្រូវហាមឃាត់ ។

បុរស និង ស្ត្រី មានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ ជាពិសេស ក្នុងអាពាហ៍ពិពាហ៍ និងគ្រួសារ ។

អាពាហ៍ពិពាហ៍ ត្រូវធ្វើតាមលក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ និង តាមគោលការណ៍ស្ម័គ្រចិត្ត ប្តីមួយប្រពន្ធមួយ ។

**មាត្រា ៤៨.-**

រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្តីពីកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្ម សេដ្ឋកិច្ច ឬកាមគុណ លើកុមារ។

**មាត្រា ៦៨.-**

រដ្ឋផ្តល់កិច្ចការអប់រំផ្នែកបឋម និងមធ្យមសិក្សានៅសាលារៀនសាធារណៈ សំរាប់ប្រជាពលរដ្ឋគ្រប់រូបដោយឥតបង់ថ្លៃ ។

ប្រជាពលរដ្ឋ ត្រូវបានទទួលការអប់រំយ៉ាងតិចប្រាំបួនឆ្នាំ ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

# ច្បាប់

## ស្តីពី

# ការងារ

១៨១៣

មាត្រា ១៨២.-

ក្នុងសហគ្រាសទាំងអស់ដែលមានរាប់ក្នុង *មាត្រា១* នៃច្បាប់នេះ ស្ត្រីទាំងឡាយត្រូវមានសិទ្ធិឈប់សំរាក កៅសិបថ្ងៃ ដើម្បីសំរាលកូន ។

ក្រោយពីឈប់សំរាលកូនមកក្នុងរយៈពេលពីរខែដែលបានចូលធ្វើការ ត្រូវឱ្យស្ត្រីនោះធ្វើតែការណាស្រាលៗ ។

ត្រូវហាមឃាត់មិនឱ្យនិយោជក បញ្ឈប់ស្ត្រីសំរាលកូន នៅពេលឈប់ឆ្លងទន្លេ ឬនៅថ្ងៃណាមួយក្នុងពេលឈប់សំរាលកូននេះ ទោះដោយវិធីឱ្យដំណឹងមុនក៏ដោយ ។

មាត្រា ១៨៣.-

ក្នុងពេលដែលឈប់សំរាកដូចមានចែងក្នុងមាត្រាខាងលើនេះ ស្ត្រីមានសិទ្ធិត្រូវបានប្រាក់ឈ្នួលពាក់កណ្តាល គិតទាំងប្រាក់បន្ទាប់បន្សំផង ដោយនិយោជកបើកឱ្យ ។

ស្ត្រី រក្សាសិទ្ធិខ្លួនទាំងស្រុងក្នុងការទទួលវត្ថុអំណោយផ្សេងទៀត ប្រសិនជាមាន ។

អនុសញ្ញារូមដែលផ្ទុយពីនេះ ត្រូវទុកជាមោឃៈដោយពេញច្បាប់ ។

ក៏ប៉ុន្តែ ការទទួលប្រាក់ឈ្នួលដូចមានចែងក្នុង កថាខ័ណ្ឌទី១ នៃមាត្រានេះ នឹងឱ្យបានតែចំពោះស្ត្រីណាដែលធ្វើការក្នុងសហគ្រាសបានយ៉ាងតិចមួយឆ្នាំរៀងមក ។

# ច្បាប់បោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ

## ច្បាប់
## ស្ដីពី
## ការបោះឆ្នោតជ្រើសតាំង
## តំណាងរាស្ត្រ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

២/៧១

# ជំពូកទី ២
# ប្រព័ន្ធបោះឆ្នោត និងការកំណត់អាសនៈ

## មាត្រា ៥.-

តំណាងរាស្ត្រត្រូវបានជ្រើសតាំងដោយការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ តាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។

ការបោះឆ្នោតត្រូវធ្វើតាមប្រព័ន្ធសមាមាត្រតាមរាជធានី ខេត្ត ដោយយករាជធានី ខេត្តជាមណ្ឌលបោះឆ្នោត ។

**ខ.ច្បាប់អន្តរជាតិ**

*ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនិងស្ត្រីភេទ (CEDAW)*



## មាត្រា ១

ដើម្បីបម្រើគោលដៅនៃអនុសញ្ញានេះ ពាក្យ "ការរើសអើងប្រឆាំងស្ត្រីភេទ" សំដៅដល់ការប្រកាន់ បែងចែក ការផាត់ចេញ ឬការរឹតត្បិតផ្អែកលើភេទ ដែលមានអានុភាព ឬមានបំណងធ្វើឱ្យខូចខាត ឬធ្វើឱ្យមោឃៈនូវការទទួលស្គាល់ ការអាស្រ័យផល ឬការប្រើប្រាស់ដោយស្ត្រី ដោយឥតគិតដល់ស្ថានភាពអាពាហ៍ពិពាហ៍របស់ស្ត្រី ផ្អែកលើមូលដ្ឋានសមភាពរវាងបុរស និងស្ត្រី នូវសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន ក្នុងវិស័យនយោបាយ ពលរដ្ឋ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ឬក្នុងវិស័យដទៃទៀត ។

## មាត្រា ២

រដ្ឋភាគី ផ្តន្ទាទោសការរើសអើងប្រឆាំងស្ត្រីភេទក្នុងគ្រប់ទម្រង់ ព្រមព្រៀងគ្នាអនុវត្តគោលនយោបាយ តាមមធ្យោបាយសមស្រប និងដោយឥតពន្យាពេល ដើម្បីឈានទៅលុបបំបាត់ការរើសអើងប្រឆាំងស្ត្រីភេទ ហើយក្នុងទិសដៅនេះ សន្យាថា៖

(ក) បញ្ចូលគោលការណ៍សមភាពរវាងបុរស និងស្ត្រី ទៅក្នុងរដ្ឋធម្មនុញ្ញ ឬច្បាប់ជាតិសមស្របឯទៀត ប្រសិនបើមិនទាន់បានបញ្ចូលនៅឡើយ និងធានាតាមផ្លូវច្បាប់ ឬមធ្យោបាយសមស្របដទៃទៀត ដើម្បីធ្វើឱ្យគោលការណ៍នេះ បានសម្រេចជាក់ស្តែង ។

(ខ) អនុម័តបទបញ្ញត្តិ និងវិធានការច្បាប់ និងវិធានការសមស្របផ្សេងៗ រួមមានទណ្ឌកម្មផងបើចាំបាច់ ដើម្បីហាមឃាត់ការរើសអើងទាំងអស់ប្រឆាំងនឹងស្ត្រី,

(គ) បង្កើតកិច្ចការពារសិទ្ធិរបស់ស្ត្រីតាមផ្លូវច្បាប់ ផ្អែកលើមូលដ្ឋានសមភាព

សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស



**មាត្រា ១**

មនុស្សទាំងអស់កើតមកមានសេរីភាពនិងសមភាពក្នុងផ្នែកសេចក្ដីថ្លៃថ្នូរនិងសិទ្ធិ។ មនុស្សមានវិចារណញ្ញាណ និងសតិសម្បជញ្ញៈជាប់ពីកំណើត ហើយគប្បីប្រព្រឹត្តចំពោះគ្នា

**មាត្រា ២៣**

១. មនុស្សគ្រប់រូប មានសិទ្ធិធ្វើការងារ ជ្រើសរើសការ-ងារដោយសេរី និងធ្វើការងារក្នុងល័ក្ខខ័ណ្ឌ ត្រឹមត្រូវនិងពេញចិត្ត ព្រមទាំងការពារប្រឆាំងនឹងភាពអត់ការងារធ្វើ។

២. មនុស្សគ្រប់រូប មានសិទ្ធិទទួលប្រាក់បៀវត្សស្មើគ្នាចំពោះការងារដូចគ្នា ដោយគ្មានការរើសអើង។

៣. អ្នកធ្វើការងារ មានសិទ្ធិទទួលបានលាភការដោយសមធម៌និងពេញចិត្ត ដើម្បីធានាអត្ថិភាពរស់នៅរបស់ខ្លួននិងគ្រួសារ ឱ្យសមស្របនឹងសេចក្ដីថ្លៃថ្នូរនៃមនុស្ស និងត្រូវបានបំពេញបន្ថែមទៀត តាមមធ្យោបាយផ្សេងៗនៃការការ-ពារផ្នែកសង្គមប្រសិនបើចាំបាច់។

៤. មនុស្សគ្រប់រូប មានសិទ្ធិបង្កើត និងចូលរួមសហជីពដើម្បីការពារផលប្រយោជន៍របស់ខ្លួន។

**មាត្រា ២៦**

១. មនុស្សគ្រប់រូប មានសិទ្ធិទទួលបានការអប់រំ ។ ការអប់រំត្រូវឥតបង់ថ្លៃ យ៉ាងហោចណាស់ សម្រាប់ការអប់រំបឋមសិក្សា និងអប់រំមូលដ្ឋាន ។ ការអប់រំបឋមសិក្សាគឺជាកាតព្វកិច្ច ។ ការអប់រំខាងបច្ចេក ទេសនិងវិជ្ជាជីវៈ ត្រូវរៀបចំឱ្យមានជាទូទៅ ។ ការអប់រំឧត្តមសិក្សា ត្រូវបើកឱ្យចូលរៀនស្មើភាពគ្នាដោយឈរលើមូលដ្ឋានសមត្ថភាព ។

២. ការអប់រំត្រូវសំដៅទៅរកការរីកលូតលាស់ពេញ-លេញនៃបុគ្គលិកលក្ខណៈរបស់មនុស្ស និងការពង្រឹងការគោរពសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋាន ។ ការអប់រំនេះត្រូវលើកកំពស់ការយល់ដឹងការអត់ឱន អធ្យាស្រ័យគ្នានិងមិត្តភាពរវាងប្រជាជាតិ និងក្រុមពូជសាសន៍ ឬក្រុមសាសនាទាំងអស់ ព្រមទាំងការអភិវឌ្ឍន៍សកម្មភាពរបស់សហ-ប្រជាជាតិ ក្នុងការថែរក្សាសន្តិភាព ។

៣. មាតាបិតា មានសិទ្ធិជាអាទិភាព ក្នុងការជ្រើសរើសប្រភេទនៃការអប់រំសម្រាប់បុត្រធីតារបស់ខ្លួន ។

ខ.គោលនយោបាយរបស់រាជរដ្ឋាភិបាល

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២

សុន្ទរកថា

របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ស្តីពី

«យុទ្ធសាស្ត្រចតុកោណ»

*ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព នៅកម្ពុជា*

ដំណាក់កាលទី ២

ថ្លែងនៅក្នុងអង្គប្រជុំគណៈរដ្ឋមន្ត្រីលើកទី ១

នីតិកាលទី ៤ នៃរដ្ឋសភា

NCDD Library
001057

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០៨

## *ចតុកោណទី ៤. ការកសាងសមត្ថភាព និង ការអភិវឌ្ឍធនធានមនុស្ស*

### *មុំទី១. ការពង្រឹងគុណភាពវិស័យអប់រំ*

**93.** រាជរដ្ឋាភិបាល សម្រេចបាននូវវឌ្ឍនភាពគួរជាទីមោទនៈ ក្នុងការអនុវត្ត យុទ្ធសាស្ត្រ *«អប់រំសម្រាប់ទាំងអស់គ្នា»* តាមរយៈការធានាសមធម៌ ក្នុងការអប់រំ មូលដ្ឋានរយៈពេល ៩ ឆ្នាំ សម្រាប់កុមារគ្រប់រូប ។ សមិទ្ធផលធំៗរួមមាន៖ ចំនួន សាលារៀន និង គ្រូបង្រៀន ព្រមទាំងអត្រាចុះឈ្មោះចូលរៀន នៅគ្រប់កម្រិត សិក្សានៃចំណេះទូទៅបានកើនឡើងជាលំដាប់ ពិសេសនៅតាមជនបទ ដោយឡែក អនុវិទ្យាល័យ ត្រូវបានបង្កើតឡើងនៅក្នុងស្ទើរគ្រប់ឃុំ សង្កាត់ទូទាំងប្រទេស ។ ចំនួនគ្រឹះស្ថានមធ្យមសិក្សាបច្ចេកទេស និង គ្រឹះស្ថានឧត្តមសិក្សា ព្រមទាំងចំនួន

**នារីរតនៈទី៤**


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
ក្រសួងកិច្ចការនារី
នារីរតនៈទី៤
ផែនការយុទ្ធសាស្ត្រដើម្បីសមភាពយេនឌ័រ
និងការបង្កើនភាពអង់អាចដល់ស្ត្រី
ឆ្នាំ២០១៤ - ២០១៨

ផ្នែកទី២

# គោលបំណង

ក្នុងគោលដៅដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី ក្នុងបរិបទកំណើនសេដ្ឋកិច្ច ការអភិវឌ្ឍសង្គម និងអភិបាលកិច្ច **នារីរតនៈទី៤** មានគោលបំណងសំខាន់ៗ ដូចខាងក្រោម÷

- ជំរុញឱ្យមានបរិកាសអំណោយផល ដើម្បីបង្កើនលទ្ធភាពដល់ស្ត្រីក្នុងការទទួលបាននូវជំនាញ ការងារ ធនធានផលិតកម្ម កិច្ចគាំពារសង្គម សម្លេង និងការធ្វើសេចក្តីសម្រេចក្នុងវិស័យសេដ្ឋកិច្ច ។
- បង្កើនលទ្ធភាពរបស់ស្ត្រី និងកុមារីក្នុងការទទួលបានសេវាអប់រំ តាមរយៈការលើកកម្ពស់ការចូលរួម ការយល់ដឹង និងការបង្កលក្ខណៈងាយស្រួលដល់ស្ត្រី និងក្មេងស្រី ក្នុងការទទួលបានសេវា ។
- លើកកម្ពស់សមភាពយេនឌ័រក្នុងការផ្តល់ និងការទទួលបានសេវាសុខាភិបាល ស្របតាមតម្រូវការជាក់ស្តែង ។
- ធានាសុវត្ថិភាពដល់ស្ត្រី និងក្មេងស្រីក្នុងគ្រួសារ និងសង្គម តាមរយៈការបង្កើនការយល់ដឹង និងការអនុវត្តផែនការសកម្មភាព និងច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធ ។
- ជំរុញការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចនៅគ្រប់កម្រិត តាមរយៈការបង្កើនចំនួនមន្ត្រីរាជការជាស្ត្រី ការពង្រឹងសមត្ថភាព និងតម្លើងឋានៈតួនាទីនៅគ្រប់កម្រិត ។
- បង្កើនប្រសិទ្ធភាពជំនួយ និងចីរភាពនៃកិច្ចអភិវឌ្ឍ តាមរយៈការពង្រឹងសមត្ថភាពស្ថាប័ន ភាពជាម្ចាស់ និងភាពជាដៃគូ ។



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# ក្របខ័ណ្ឌ
# គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា
# ឆ្នាំ២០១៦-២០៣០

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី
ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨

### ២.៣.៣- គោលដៅទី៣ : លើកកម្ពស់សមភាពយេនឌ័រនិងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី

ការអនុវត្តក្នុងគោលដៅទី៣ពាក់ព័ន្ធយេនឌ័រ គឺទទួលបានលទ្ធផលចម្រុះ។ នៅក្នុងវិស័យនេះ មានតែសូចនាករក្នុងចំណុចដៅ៣ប៉ុណ្ណោះ ហើយគ្មានប្រភពទិន្នន័យសម្រាប់គាំទ្រដល់សូចនាករស្តីពីអំពើហិង្សាក្នុងគ្រួសារទេ។ ទោះជាដូចនេះក្តី តាមរយៈតារាង ២.៤ បានបង្ហាញច្បាស់ថា មានតែសូចនាករមួយតែប៉ុណ្ណោះ(សមភាពក្នុងការអប់រំនិងអក្ខរកម្ម) ដែលសម្រេចបានតាមចំណុចដៅកំណត់។

**តារាង ២.៤ : ការអនុវត្តគោលដៅទី៣នៃ គ.អ.ស.ក.**

| ល.រ | សូចនាករ | | សមិទ្ធផល | | | | |
|---|---|---|---|---|---|---|---|
| | | ឯកតា | ២០០០ | ២០០៥ | ២០១០ | ២០១៥ ជាក់ស្តែង | ២០១៥ ចំណុចដៅ |
| (៣a) សម្រេចឲ្យបានសមភាពយេនឌ័រក្នុងវិស័យអប់រំនិងអក្ខរកម្ម | | | | | | | |
| 1 | អត្រាភេទ (ស្ត្រី/ប្រុស) នៅកម្រិតមធ្យមសិក្សាទុតិយភូមិ | % | ៤៨ (២០០១) | ៦០ | ៨២ | ១០០ | ១០០ |
| 2 | អត្រាភេទ (ស្ត្រី/ប្រុស) នៅកម្រិតឧត្តមសិក្សា | % | ៣៨ (២០០១) | ៤៥,៦ | ៨៦,៧ | ៨៥ | ៨៥ |
| 3 | អត្រាភេទ (ស្ត្រី/ប្រុស) អាយុ ១៥-២៤ឆ្នាំ នៃអក្ខរកម្ម | % | ៨៧ (១៩៩៨) | ៩០ | ៩៨,៣ | ១០០ | ១០០ |
| 4 | អត្រាភេទ (ស្ត្រី/ប្រុស) អាយុ ២៥-៤៤ឆ្នាំ នៃអក្ខរកម្ម | % | ៧៨ (១៩៩៨) | ៨០ | ៩៩ | ១០០ | ១០០ |
| (៣b) ផ្តល់សិទ្ធិអំណាចដល់ស្ត្រីក្នុងការងារទទួលបានប្រាក់ឈ្នួល | | | | | | | |
| 5 | ស្ត្រីធ្វើការងារមានបៀវត្សរ៍ក្នុងគ្រប់វិស័យ | % | - | - | ៤២,២ | - | ៥០ |
| 6 | សមាមាត្រស្ត្រីធ្វើការមានបៀវត្សរ៍ ក្នុងវិស័យកសិកម្ម | % | ៣៥,០ (១៩៩៨) | ៥២,៥ | ៥៣,០ | ៤៥,៧ (២០១៣) | ៥០ |
| 7 | សមាមាត្រស្ត្រីធ្វើការមានបៀវត្សរ៍ វិស័យឧស្សាហកម្ម | % | ៤៤ (១៩៩៨) | ៥៣,៣ | ៧៣,[illegible] | ៤៥,៤ | ៥០ |
| 8 | សមាមាត្រស្ត្រីធ្វើការមានបៀវត្សរ៍ វិស័យសេវាកម្ម | % | ២១,០ | ២៧,០ | [illegible] | [illegible] | [illegible] |

យេនដ័រការបញ្ជ្រាវយេនឌ័រ បរិបទគោលនយោបាយ ស្ថាប័ន និងភាពជាដៃគូ ការប៉ានប្រមាណអំពី យេនឌ័រនៅកម្ពុជា២០១៤



## គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប)

ក្នុងឆ្នាំ២០០៩គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)បានបង្កើតឡើងដើម្បីត្រួតពិនិត្យការអនុវត្តន៍កំណែទម្រង់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ នៅឆ្នាំ២០១០ គ.ជ.អ.ប បានបង្កើតកម្មវិធីជាតិ១០ឆ្នាំសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឆ្នាំ២០១០-២០១៩។ កម្មវិធីជាតិនេះផ្តល់ទិសដៅសម្រាប់ការអនុវត្តន៍របៀបវារៈកំណែទម្រង់សម្រាប់១០ឆ្នាំបន្ទាប់។ កម្មវិធីជាតិ១០ឆ្នាំបានរៀបចំជាផែនការអនុវត្តន៍បីឆ្នាំដំបូងដែលហៅកាត់ថា "ផអ៣" ។ ផអ៣ មានអនុកម្មវិធីប្រាំមួយ ដែលមានក្រសួង ស្ថាប័នចំនួនប្រាំពីរអនុវត្តអនុកម្មវិធីទាំងនោះ ដែលមានក្រសួងកិច្ចការនារីដើរតួនាទីជាអ្នកសម្របសម្រួល និងគាំទ្រការបញ្ជ្រាបយេនឌ័រនៅក្នុងផអ៣។

យេនឌ័របានបញ្ជ្រាបទាំងនៅក្នុងកម្មវិធីជាតិ១០ឆ្នាំ និងផអ៣។ កម្មវិធីជាតិ១០ឆ្នាំ[3] និងផអ៣[4]បានផ្តោតការយកចិត្តទុកដាក់ក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រីក្នុងអភិបាលកិច្ចមូលដ្ឋានតាមរយៈការចូលរួម និងការទទួលបានសិទ្ធិស្មើគ្នាសម្រាប់ស្ត្រីនិងបុរសដើម្បីទទួលបានមុខតំណែងជាអ្នកដឹកនាំ និងការធ្វើសេចក្តីសម្រេចផ្នែកនយោបាយ ធនធាននិងសេវាកម្ម។ នៅខែកុម្ភៈឆ្នាំ២០១៤ គ.ជ.អ.ប បានធ្វើសវនកម្មយេនឌ័រដែលបានត្រួតពិនិត្យឡើងវិញលើ ស្ថាប័នគោលនយោបាយសំខាន់ៗនិងសមិទ្ធផល ព្រមទាំងឧបសគ្គនានាក្នុងការបញ្ជ្រាបយេនឌ័រ។ សវនកម្មនេះបាន

---

[3] ផែនការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (២០១០-២០១៩) របស់រាជរដ្ឋាភិបាលកម្ពុជា

[4] ផែនការអនុវត្តន៍បីឆ្នាំដំបូង (២០១១-២០១៣) នៃផែនការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំឆ្នាំ២០២១-២០២៥



## ការអប់រំបឋមសិក្សា

បច្ចុប្បន្ន សាលាបឋមសិក្សាមានស្ទើរគ្រប់ទីតាំងភូមិសាស្ត្រ ដែលបានកើនពី ៧ ៤៤២ នៅឆ្នាំសិក្សា ២០១៥-២០១៦ ដល់ ៧ ៨៥៦ នៅឆ្នាំសិក្សា២០១៩-២០២០ និងបានធ្វើឱ្យមានភាពប្រសើរឡើងដល់ការធ្វើដំណើរទៅសាលារៀន និងបន្តការសិក្សារបស់សិស្ស គួបផ្សំជាមួយការផ្តល់អាហារូបករណ៍និងផ្តល់អាហារនៅតាមសាលារៀន ការកើនឡើងនៃហេដ្ឋារចនាសម្ព័ន្ធសាលារៀននិងកម្មវិធីលើកកម្ពស់សុខភាពសិក្សា ការអប់រំបរិយាបន្ន និងកម្មវិធីគាំទ្រផ្សេងៗទៀត។ ឆ្នាំសិក្សា២០១៩-២០២០ សាលាបឋមសិក្សាមានបង្គន់ ៩៩,៣ ភាគរយ ទឹកស្អាតសម្រាប់ទទួលទាន ៩០,៤ ភាគរយ កន្លែងលាងដៃ ៧៤,៧ ភាគរយ ជាពិសេសសាលាបឋមសិក្សាអនុវត្តស្តង់ដារអប្បបរមាទឹកស្អាតនិងអនាម័យ កម្រិត ១ មាន ៤០,៦ ភាគរយ។ បង្គន់អនាម័យ ត្រូវបានសាងសង់បន្ថែម និងបានដាក់ដាច់ដោយឡែកសម្រាប់សិស្សស្រី និងសិស្សប្រុស នៅតាមសាលារៀន ដើម្បីគាំទ្របរិស្ថានសិក្សាឱ្យសិស្សស្រីមករៀនកាន់តែទៀងទាត់ និងមានជំរាលសម្រាប់សិស្សមានពិការភាពផងដែរ។

ក្រសួងបាននិងកំពុងអនុវត្តគោលនយោបាយសាលាកុមារមេត្រីនៅតាមសាលាបឋមសិក្សា ដើម្បីកែលម្អបរិយាកាសនៃការរៀនសូត្រ និងធានានូវសុវត្ថិភាព សន្តិសុខសម្រាប់សិស្សស្របពេលដែលកំពុងបង្កើនការយល់ដឹងអំពីសារៈសំខាន់នៃការអប់រំសិស្សស្រីនៅក្នុងសហគមន៍។

ក្រសួងបាននិងកំពុងអនុវត្តការគ្រប់គ្រងតាមសាលារៀន ដោយមានការសហការពីអាជ្ញាធរមូលដ្ឋាន ពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល គណៈកម្មការគ្រប់គ្រងសាលារៀន លោកគ្រូ អ្នកគ្រូ មាតាបិតាសិស្ស និងសហគមន៍ ក្នុងការបង្កើនការចូលរៀននៅបឋមសិក្សា ក៏ដូចជាការកែលម្អគុណភាពអប់រំផងដែរ។

រាជរដ្ឋាភិបាលមានគោលនយោបាយផ្តល់អាហារូបករណ៍ដល់សិស្សពូកែ និងសិស្សក្រីក្រ ក្នុងនោះយ៉ាងហោចណាស់ត្រូវមានសិស្សស្រី ៦០ ភាគរយ។ អាហារូបករណ៍សម្រាប់សិស្សក្រីក្រដែលបានប្រើប្រាស់ថវិកាជាតិ បានគ្របដណ្តប់លើសាលាបឋមសិក្សា ៤ ៩៥១ មានសិស្ស ១១០ ១៥៦នាក់ ស្រី ៥៤ ភាគរយ។ សិស្សស្រីទទួលអាហារូបករណ៍ជាស្បៀងពីកម្មវិធីអង្គការស្បៀងអាហារពិភពលោក ៥៦ ភាគរយ។

ការចូលរៀននៅបឋមសិក្សា ក្នុងរយៈពេល ៥ឆ្នាំកន្លងមក សម្រេចបានអត្រាពិតនៃការសិក្សាក្នុងរង្វង់ ៩៨ ភាគរយ និងអត្រាបញ្ចប់ការសិក្សា ក្នុងរង្វង់ ៨០ ភាគរយ។ ឆ្នាំសិក្សា២០១៩-២០២០ សិស្សបឋមសិក្សាសរុប ២ ១៦៣ ១៤៣នាក់ ស្រី១ ០៣៩ ៩៣៦នាក់ (៤៨,១ ភាគរយ)។ សិស្សស្រីនៅសាលារដ្ឋមាន ៤៧,៩ ភាគរយ និងសាលាឯកជន ៤៩,៤ ភាគរយ។ សិស្សស្រីជនជាតិដើមភាគតិចក្នុងកម្មវិធីអប់រំពហុភាសាមាន ៤៨,៨ ភាគរយ និងសិស្សស្រីមានពិការភាព ៤០,៥ ភាគរយ។ អត្រាឡើងថ្នាក់នៅបឋមសិក្សាសម្រាប់សិស្សស្រីមាន ៨៩,៤ ភាគរយ និងសិស្សប្រុស ៨៤,៥ ភាគរយ អត្រាត្រួតថ្នាក់ (ស្រី៤,៧ ភាយរយ និងប្រុស ៧,៨ ភាគរយ) អត្រាបោះបង់ការសិក្សា (ស្រី ៥,៩ ភាគរយ និងប្រុស៧,៧ ភាគរយ) និងអត្រាបញ្ចប់ការសិក្សា (ស្រី ៩២,៧ ភាគរយ និងប្រុស ៨៤,១ ភាគរយ)។

វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងបាត់ដំបង ដោយបានបណ្តុះបណ្តាលគ្រូបង្រៀនតាមប្រព័ន្ធ ១២ បូក ៤ សម្រាប់បឋមសិក្សា និងកម្រិតអប់រំមូលដ្ឋាន

- ក្រសួងអប់រំ យុវជន និងកីឡាបានលើកទឹកចិត្ត និងបណ្តុះបណ្តាលគ្រូកម្រិតមូលដ្ឋានដែលបង្រៀននៅវិទ្យាល័យតាមប្រព័ន្ធពន្លឿនដើម្បីឱ្យក្លាយទៅជាគ្រូបង្រៀនកម្រិតឧត្តម ២ ៦៨៦នាក់ ស្រី ៩៣៤ នាក់ (៣៤,៧ ភាគរយ) និងបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋានឱ្យទទួលបានបរិញ្ញាបត្រអប់រំ ៩៦៥នាក់ ៧១៥នាក់ ស្រី ៣៨០នាក់ (៣៩,៤ ភាគរយ) ព្រមទាំងបណ្តុះបណ្តាលអធិការអប់រំថ្មី (ពីឆ្នាំ២០១៦-២០២០) បាន ៥ ជំនាន់ សរុប ២៤៧នាក់ ស្រី ២៥នាក់ (១០,១ ភាគរយ) និងអធិការអប់រំដែលមានស្រាប់ ៥១ នាក់ ស្រី ៥ នាក់ (៩,៨ ភាគរយ)។
- ក្រសួងអប់រំ យុវជន និងកីឡាបានសហការជាមួយដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីបន្តបង្កើនគុណភាពនៃការបង្រៀនបន្ថែមទៀត ជាពិសេស មុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រ មន្ទីរពិសោធន៍ វិទ្យាសាស្ត្រ កុំព្យូទ័រ ភាសាបរទេស និងបណ្ណាល័យ តាមរយៈកម្មវិធីសាកល្បងសាលារៀនជំនាន់ថ្មី នៅតាមសាលាមធ្យមសិក្សា ដែលបានជ្រើសរើសនៅទូទាំងប្រទេស
- ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញវិធានការកំណែទម្រង់ការគ្រប់គ្រងបុគ្គលិក ដើម្បីឆ្លើយតបទៅនឹងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល។ ក្នុងរយៈពេល៥ឆ្នាំកន្លងមក ការអនុវត្តកម្មវិធីជាតិ និងវិធានការកំណែទម្រង់បានធ្វើឱ្យបុគ្គលិកអប់រំនៅទូទាំងប្រទេស មានការពេញចិត្ត និងបន្តខិតខំបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាអប់រំនៅគ្រប់ភូមិសិក្សាជាមួយនឹងការទទួលបានការលើកទឹកចិត្តពីរាជរដ្ឋាភិបាល តាមគ្រប់រូបភាពជាអាទិ៍៖ ការបើកបៀវត្សមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាតាមប្រព័ន្ធធនាគារនិងបានទៀងទាត់នៅសប្តាហ៍ទី២ និងទី៤នៃខែនីមួយៗ បៀវត្សបុគ្គលិកអប់រំមានការកើនឡើង៣ដង គឺបៀវត្សអប្បបរមានៃបុគ្គលិកអប់រំកើនឡើងពី ៣១០ ០០០ រៀល ឆ្នាំ២០១៣ រហូតដល់ ១ ២០០ ០០០ រៀល នៅឆ្នាំ ២០១៩ ប្រាក់លើកកម្ពស់ជីវភាពបុគ្គលិកអប់រំនៅតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាកកើនឡើងទ្វេដង និងប្រាក់កម្រៃបង្រៀនបបម៉ោងបន្ថែមក៏មានការកើនឡើងទ្វេដងផងដែរ។ ប្រាក់ឧបត្ថម្ភមាតុភាពជូនមន្ត្រីរាជការ មន្ត្រីកម្មសិក្សា និងមន្ត្រីជាប់កិច្ចសន្យាជាស្ត្រីដែលសម្រាលកូនត្រូវបានដំឡើងពីចំនួន ៦០០ ០០០ រៀល ទៅចំនួន ៨០០ ០០០ រៀល។
- គោលនយោបាយជាតិស្តីពី សុខភាពសិក្សាត្រូវបានអនុម័តដោយរាជរដ្ឋាភិបាល ឆ្នាំ២០១៩
- ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ឱ្យអនុវត្តកម្មវិធីសិក្សាបំណិនជីវិតសម្រាប់កម្រិតបឋមសិក្សា (ថ្នាក់ទី៥-៦) សាលាមធ្យមសិក្សាបឋមភូមិ (ថ្នាក់ទី៧-៨) សាលាមធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី ១០-១១) និងសម្រាប់យុវជនក្រៅសាលា។ កម្មវិធីសិក្សានេះមាននៅគ្រប់កម្រិតសិក្សាទាំងអស់ រួមមាន ការអប់រំអំពីសុខភាពបន្តពូជ សុខភាពផ្លូវភេទកម្រិតមូលដ្ឋាន មេរោគអេដស៍/ជំងឺអេដស៍ អនាម័យ និងទស្សនៈយេនឌ័រ (ពីថ្នាក់ទី៥-៦) តួនាទីយេនឌ័រ លក្ខណៈភេទ ការសម្តែងចេញ

## ឯកសារផ្សេងៗ


បញ្ហាប្រឈមរបស់ស្ត្រីក្នុង
ភាពជាអ្នកដឹកនាំ: លទ្ធផល
ស្រាវជ្រាវគន្លឹះនៃការវិភាគ
ស្ថិតិយេនឌ័រ
បោះពុម្ពផ្សាយដោយ
អគ្គលេខាធិការដ្ឋានរដ្ឋសភា
ឯកសារវិភាគ
ស្ថិតិយេនឌ័រ

## III. ស្ថានភាពស្ត្រីនៅក្នុងវិស័យនយោបាយ និងក្នុងថ្នាក់ធ្វើសេចក្តីសម្រេច

កម្ពុជាសម្រេចបានស្នាដៃគួរឱ្យកត់សម្គាល់ចាប់ពីនីតិកាលទី១នៃរដ្ឋសភាដល់នីតិកាលទី៦។ យោងទៅតាមរបាយការណ៍គម្លាតយេនឌ័រពិភពលោកឆ្នាំ២០២០ ដែលចេញផ្សាយដោយវេទិការសេដ្ឋកិច្ចពិភពលោក គម្លាតយេនឌ័រកម្ពុជាស្ថិតនៅក្នុងលំដាប់ថ្នាក់ទី៨៩ក្នុងចំណោមប្រទេសចំនួន១៥៣ ក្នុងឆ្នាំ២០១៩។[vii] ក្នុងរយៈពេល៦ឆ្នាំកន្លងមកនេះ ការដោះស្រាយបញ្ហាវិសមភាពយេនឌ័រនៅកម្ពុជាបានទទួលលទ្ធផលជាវិជ្ជមាន ដោយកម្ពុជាធ្លាប់ជាប់ចំណាត់ថ្នាក់រហូតដល់ទី១០៨។[viii] ប៉ុន្តែយ៉ាងណាមិញ ការចូលរួមរបស់ស្ត្រីនៅក្នុងការពង្រឹងភាពអង់អាចខាងនយោបាយ គឺឈរនៅលំដាប់ថ្នាក់ទី ១១៩ ក្នុងចំណោម ១៥៣ ប្រទេស ដែលទាមទារឱ្យក្រសួង-ស្ថាប័នមានសមត្ថកិច្ចធ្វើការសហការគ្នាដើម្បីធ្វើឱ្យស្ថានភាពស្ត្រីនៅក្នុងវិស័យនយោបាយល្អប្រសើរឡើង។[ix]

### ១. ស្ត្រីនៅក្នុងស្ថាប័ននីតិប្បញ្ញត្តិ

សភាកម្ពុជាបានអនុម័តប្រព័ន្ធសភា២ដែលមានព្រឹទ្ធសភា និងរដ្ឋសភា។ រដ្ឋសភាជាស្ថាប័នជាប់ឆ្នោតដែលមានអាណត្តិ៥ឆ្នាំ រីឯព្រឹទ្ធសភាមានអាណត្តិ៦ឆ្នាំ។ យោងទៅតាមរដ្ឋធម្មនុញ្ញកម្ពុជា រដ្ឋសភាមានសមាជិកយ៉ាងតិច១២០រូប។[x] សមាជិករដ្ឋសភាទាំងអស់តំណាងឱ្យ

គ.គេហទំព័រ


ភ្នំពេញ ប៉ុស្តិ៍
ស្ត្រី គឺជាកម្លាំងការងារដ៏សំខាន់ ខណៈស្ត្រីជួយជំរុញកំណើនសេដ្ឋកិច្ច និងទីផ្សារប្រើប្រាស់
សេដ្ឋកិច្ច
កាលបរិច្ឆេទផ្សាយ:
២៨ កុម្ភៈ ២០២២ | ០៩:៥៦
អ្នកយកព័ត៌មាន: Sponsored
អត្ថបទច្រើនទៀត
30% OFF

ក្រសួងព័ត៌មាន

Download on the App Store

GET IT ON Google Play

## សៀវភៅ កម្ពុជាសម័យតេជោ វគ្គ ១៥« ស្ត្រី និងវិស័យនយោបាយ និងវិស័យឯកជន »

ចេញផ្សាយ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០២៣

**AKP** ភ្នំពេញ ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២៣--

សៀវភៅ«កម្ពុជា សម័យតេជោ»ជាស្នាដៃរបស់ ឯកឧត្តម ពៅ សុខ ទីប្រឹក្សាផ្ទាល់សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន និងជាសមាជិកក្រុមប្រឹក្សាភិបាលសមាគមអ្នកនិពន្ធខ្មែរ។

លោកស្រី អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី បានមានប្រសាសន៍ក្នុងវេទិកាថ្នាក់ជាតិ ស្តីពីការលើកកម្ពស់សហគ្រិនភាពរបស់ស្ត្រីនៅតំបន់អាស៊ាន តាមរយៈគោលនយោបាយ គាំពារគ្រួសារ និងសង្គមថ្ងៃទី៧ ខែតុលា ឆ្នាំ២០២២ ថា បច្ចុប្បន្ន ស្ត្រីដែលដឹកនាំសហគ្រាស ធុនតូច និងមធ្យមមានចំនួន៦១% ហើយសហគ្រាសធុនតូច និងមធ្យម(**SME**)ប្រមាណ៩៨% នៃធុរកិច្ចទាំងអស់បានចូលរួមចំណែកដល់សេដ្ឋកិច្ចជាតិប្រមាណ៥៨% និងបានផ្តល់ការងារប្រមាណ៧៣% នៃការងារទាំងអស់។




# លោក អ៊ុំ រាត្រី៖ ស្ត្រីដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច-សង្គមដ៏មានសារៈសំខាន់ក្នុងការអភិវឌ្ឍ

ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២២ ១៣:៤២ ដោយ Chanoutdam 2555

Aa | aA

បន្ទាយមានជ័យ៖ វឌ្ឍនភាពក្នុងការអនុវត្តគោលដៅអភិវឌ្ឍន៍សហសវត្ស ដែលផ្ដោតលើការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ជាលទ្ធផលបានបង្ហាញជាវិជ្ជមានជាច្រើនចំពោះប្រទេសជាតិ និងស្ត្រីកម្ពុជាក្នុងការផ្ដល់នូវសមភាពយេនឌ័រ និងផ្ដល់សិទ្ធិអំណាចដល់ស្ត្រីទាំងមូល ដែលបាននឹងកំពុងអនុវត្តសកម្មភាពតាមតួនាទីរៀងៗខ្លួន។



**Cambodian Temple**
27 Apr 2015 ·

ក្នុងសង្គមខ្មែរលទ្ធិមាតេយ្យការ(ការប្រកាន់យកខ្សែខាងម្ដាយ)បានចាក់យ៉ាងជ្រៅចូលទៅក្នុងចិត្តគំនិតខ្មែរ។ តាមកំណត់ត្រាប្រវត្តិសាស្ត្រចិនដែលរៀបរាប់ពីហ្វូណនមុនឥណ្ឌាមកដល់ស្ដេចខ្មែរជាស្ត្រី។ ក្រោយទទួលឥទ្ធិពលអារ្យធម៏ឥណ្ឌាលទ្ធិនេះហាក់សាបរលាបទៅ ក៏ប៉ុន្តែតួនាទីរបស់ស្ត្រីនៅតែចម្បងក្នុងសង្គមខ្មែរ មិនដូចសង្គមឥណ្ឌាឡើយ។ ពាក្យមួយចំនួនក្នុងភាសាខ្មែរជាសាក្សីនៃអាទិភាពនៃលទ្ធិមាតេយ្យការតួយ៉ាងពាក្យមេ មេកន្ទ្រាញ មេទ័ពមេដំបូលជាដើម។ និងពាក្យខ្មែរបុរាណ ថា "កុរុង" ដែលមានន័យថា "ស្ដេច" តែបើប្រែន័យមួយៗវិញ គឺ ស្ត្រីជាធំ ។ ពាក្យ "អ្នកខ្លោញ" ដែលមានន័យថា"ប្រពន្ធ" តែបើប្រែន័យមួយៗ គឺអ្នកធំ។ មូលហេតុខ្លះដែលនាំអោយស្ត្រីមានសារសំខាន់នោះដោយសារស្ត្រីជាម្ដាយនៃលោក ជាអ្នកអំណត់តស៊ូគ្មានទីបញ្ចប់ក៏ថាបាន។

ដូចក្នុងរូបភាពចម្លាក់លឹបមួយផ្ទាំងនៃប្រាសាទបាយ័នបានបង្ហាញពីគ្រួសារទ័ពដែលចេញទៅធ្វើចម្បាំងជាមួយចាមបទាំងគ្រួសារៗ។ រូបភាពបង្ហាញពីការទទួលខុសត្រូវដ៏ច្រើនរបស់នាង ដោយដៃម្ខាងកណ្ដៀតកូន

≡ វិគីភីឌា

# ស៊ីសុវត្ថិ កុសមៈ

文A

សម្តេចព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្នសេរីវឌ្ឍនា (៩ មេសា ១៩០៤ - ២៧ មេសា ១៩៧៥) គឺជាព្រះមហាក្សត្រិយានីនិងសម្តេចព្រះរាជអគ្គមហេសីនៃព្រះបាទសម្តេចព្រះនរោត្តម សុរាម្រិត ព្រះវររាជមាតានៃព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះរាជបុត្រីរបស់ព្រះករុណាព្រះបាទសសម្តេចព្រះ ស៊ីសុវត្ថិ មុនីវង្ស និង សម្តេចព្រះរាជអគ្គមហេសីនរោត្តម កានវិមាន នរល័ក្ខទេវី។[១] [២]ព្រះអង្គត្រូវបានគេស្គាល់ដោយសារការងារសប្បុរសធម៌ និងការខិតខំប្រឹងប្រែងរបស់ព្រះអង្គក្នុងការលើកកម្ពស់ការអប់រំ និងសុខុមាលភាពសង្គមនៅកម្ពុជា។ ព្រះអង្គក៏ជាអ្នកតស៊ូមតិដ៏រឹងមាំសម្រាប់សិទ្ធិស្រ្តី និងបានដើរតួនាទីយ៉ាងសកម្មក្នុងការលើកកម្ពស់ការអប់រំ និងការផ្តល់សិទ្ធិអំណាចដល់ស្រ្តី។